ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

របាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025
និង
របាយការណ៍របស់សវនករឯករាជ្យ

ព័ត៌មានអំពីធនាគារ

ធនាគារ	ធនាគារ អ៊ូរី (ខេមបូឌា) ម.ក
លេខចុះបញ្ជីពាណិជ្ជកម្ម	00005269
ទីស្នាក់ការចុះបញ្ជី	អគារលេខ 398 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ភាគទុនិក	*ភាគទុនិកពីមុន* ធនាគារ អ៊ូរី កូរ៉េ លោក Hong Ju Kim *ភាគទុនិកថ្មី (អនុម័តដោយ ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី29 ខែកក្កដា ឆ្នាំ 2025 និងបានដាក់តម្កល់នៅក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី25 ខែសីហា ឆ្នាំ2025)* ធនាគារ អ៊ូរី កូរ៉េ លោក Cheol Su SOHN

ក្រុមប្រឹក្សាភិបាល		
	លោក Changseok Ohk	ប្រធានក្រុមប្រឹក្សាភិបាល
	លោក Cheol Su Sohn	សមាជិកក្រុមប្រឹក្សាភិបាល
	លោក Dong Woo Shin	សមាជិកក្រុមប្រឹក្សាភិបាល
	អ្នកនាង Fiona Michelle Whyte	សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ
	លោក គី ប៊ុនទ្រាន	សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ
	លោក ដួង សារៈ	សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ
	លោក Jeoung Hoon Yoo	សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

គណៈគ្រប់គ្រង		
	លោក Cheol Su Sohn	អគ្គនាយកប្រតិបត្តិ (លាលែងពីតំណែង នៅថ្ងៃទី20 ខែមករា ឆ្នាំ2026)
	លោក Ju Sug Kang	អគ្គនាយកប្រតិបត្តិ (តែងតាំងនៅថ្ងៃទី2 ខែមីនា ឆ្នាំ2026)
	លោក Dong Woo Shin	អគ្គនាយកហិរញ្ញវត្ថុ
	លោក Chang You KIM	អគ្គនាយកឌីជីថល
	លោក ព្រាប ពិសិដ្ឋ	អគ្គនាយកប្រតិបត្តិការ

ព័ត៌មានអំពីធនាគារ (ត)

គណៈគ្រប់គ្រង (ត)	លោក Hyoseok Lee	អគ្គនាយកគាំទ្រប្រតិបត្តិការ (លាលែងពីតំណែង នៅថ្ងៃទី20 ខែមករាឆ្នាំ2026)
	លោក សុផល សុជាត	អគ្គនាយកឥណទាន
	លោក អ៊ាត ចិត្រាសូរិរង្ស	អគ្គនាយកព័ត៌មានវិទ្យា
	លោកស្រី តុប សុក្រសម្ភារ	អគ្គនាយិកាគ្រប់គ្រងហានិភ័យ
	កញ្ញា ហ៊ុន សុជាតិ	ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
	លោកស្រី ស៊ីវ ច័ន្ទវលក្ខណ៍	មន្ត្រីប្រតិបត្តិតាម
សវនករ	ខេភីអឹមជ្ជី ខេមបូឌា	

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

មាតិកា

		ទំព័រ
1.	របាយការណ៍របស់ក្រុមប្រឹក្សាភិបាល	1 – 6
2.	របាយការណ៍របស់សវនករឯករាជ្យ	7 – 10
3.	របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ	11 – 12
4.	របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ	13
5.	របាយការណ៍ស្តីពីបម្រែបម្រួលមូលធន	14
6.	របាយការណ៍លំហូរសាច់ប្រាក់	15 – 16
7.	កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ	17 – 131
	ព័ត៌មានអំពីធនាគារ	17 – 18
	មូលដ្ឋាននៃការរៀបចំ	18 – 19
	ការប្តូរូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល	20
	សាច់ប្រាក់ក្នុងដៃ	20 – 21
	ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា	22 – 23
	សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	24 – 25
	ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	26 – 28
	មូលបត្រវិនិយោគ	28
	ទ្រព្យ និងបរិក្ខារ	29 – 30
	ទ្រព្យសកម្មអរូបី	31
	សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	32
	ទ្រព្យសកម្មផ្សេងៗ	33
	ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	34 – 35
	ចំណូលពន្ធលើប្រាក់ចំណេញ	35 – 39

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

មាតិកា (ត)

	ទំព័រ
ប្រាក់កម្ចី	39 – 41
គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ	41 – 42
បំណុលភតិសន្យា	43 – 44
បំណុលផ្សេងៗ	45 – 46
ដើមទុន	46 – 47
ទុនបម្រុងតាមបទប្បញ្ញត្តិ	47
ចំណូលការប្រាក់	48
ចំណាយការប្រាក់	48
កម្រៃ និងចំណាយជើងសាសុទ្ធ	49
ការខាតបង់ឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ	49
ចំណូលផ្សេងៗ	50
ចំណាយលើបុគ្គលិក	50
ចំណាយលើរំលស់	50
ចំណាយប្រតិបត្តិការផ្សេងៗ	51
ការសន្យា និងយថាភាព	52 – 53
សម្ព័ន្ធញាតិ	54 – 56
ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ	57 – 94
តម្លៃសមស្របនៃឧបការណ៍ហិរញ្ញវត្ថុ	94 – 97
គោលនយោបាយគណនេយ្យសារវន្ត	97 – 127
ស្តង់ដាថ្មី ឬវិសោធនកម្ម និងការបកស្រាយមិនទាន់បានអនុវត្ត	127 – 129
ការទិញអាជីវកម្មក្រោមការគ្រប់គ្រងរួម និងទុនបម្រុងរួមបញ្ចូលគ្នា	129 – 131

WOORI BANK

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល (“អភិបាល”) មានសេចក្តីសោមនស្សរីករាយ សូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ហៅកាត់ថា “ធនាគារ”) ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025។

សកម្មភាពចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់សេវាកម្ម និងផលិតផលហិរញ្ញវត្ថុដូចជាប្រាក់បញ្ញើ ឥណទានរួមទាំងសេវាផ្ទេរប្រាក់ក្នុងស្រុក និងក្រៅប្រទេស សេវាធនាគារចល័ត សេវាទូទាត់សាច់ប្រាក់ សេវាកម្មម៉ាស៊ីនដកប្រាក់ និងដាក់ប្រាក់ដោយស្វ័យប្រវត្តិ លិខិតធានារបស់ធនាគារ សកម្មភាពអចលនទ្រព្យដែលមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនឬជួល និងសេវាកម្មធនាគារផ្សេងៗទៀត ដែលផ្តល់សេវាជូនប្រជាជនកម្ពុជា តាមរយៈការិយាល័យកណ្តាល និងសាខារបស់ខ្លួននៅក្នុងរាជធានីភ្នំពេញ និងសាខានៅតាមបណ្តាខេត្តផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ពុំមានការផ្លាស់ប្តូរជាសារវន្ត លើសកម្មភាពចម្បងរបស់ធនាគារ នៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 មានដូចខាងក្រោម៖

	2025		2024	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
ប្រាក់ខាតមុនដកពន្ធ	(6,791,532)	(27,240,834)	(4,554,507)	(18,541,397)
ចំណាលពន្ធលើប្រាក់ចំណេញ	1,160,413	4,654,417	1,597,842	6,504,815
ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ	(5,631,119)	(22,586,417)	(2,956,665)	(12,036,582)

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក | Woori Bank (Cambodia) Plc.
អាគារលេខ ៣៩៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
Building No. 398, Preah Monivong Blvd., Sangkat Boeng Keng Kang 1, Khan Boeng Keng Kang, Phnom Penh.
(+855) 23 963 333 | 81 331 333

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ភាគលាភ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានការប្រកាស ឬបែងចែកភាគលាភណាមួយឡើយ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 នេះដែរ (ឆ្នាំ2024៖ ពុំមាន)។

ដើមទុន

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ដើមទុនរបស់ធនាគារ មានចំនួន 275,895,100 ដុល្លារអាមេរិក (នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2024៖ មានចំនួន 275,895,100 ដុល្លារអាមេរិក)។ នាថ្ងៃទី29 ខែកក្កដា ឆ្នាំ2025 ធនាគារជាតិនៃកម្ពុជា បានអនុម័តការផ្ទេរភាគហ៊ុនចំនួន 1 ភាគហ៊ុនពីលោក Hong Ju Kim ទៅលោក Cheol Su Sohn។ វិសោធនកម្មលើអនុស្សរណៈ និងលក្ខន្តិកៈ ("MoA") បានដាក់តម្កល់នៅក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី25 ខែសីហា ឆ្នាំ2025។

ពុំមានការផ្លាស់ប្តូរផ្សេងពីនេះ លើភាគទុនិក និងរចនាសម្ព័ន្ធភាគហ៊ុនរបស់ធនាគារ នៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

ការលុបចោល និងសំវិធានធនសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ

នៅមុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីធ្វើឱ្យប្រាកដថាសកម្មភាពត្រូវបានធ្វើឡើងទាក់ទិននឹងការលុបចោលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានរំពឹងទុកថានឹងមិនអាចប្រមូលបានមកវិញនូវលំហូរសាច់ប្រាក់តាមកិច្ចសន្យាទាំងស្រុង ឬផ្នែកណាមួយរបស់វា និងការផ្តល់សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ ហើយជឿជាក់ថារាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលរំពឹងទុកថាមិនមានទទួលបានសាច់ប្រាក់មកវិញតាមកិច្ចសន្យា ត្រូវបានលុបចោល ហើយសំវិធានធនលើការខាតបង់ឥណទានដែលរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់។

គិតត្រឹមកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងអាចបណ្តាលឱ្យចំនួននៃសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុករបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្ម (លើកលែងតែចំណុល) ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ដែលទំនងជាមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានបន្ថយឱ្យនៅស្មើត្រឹមតម្លៃដែលរំពឹងថាអាចនឹងប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិនត្រឹមត្រូវជាសារវន្តណាមួយនោះឡើយ។

វិធីសាស្ត្រកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

បំណុលយថាភាព និងបំណុលផ្សេងៗទៀត

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ធនាគារ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគារ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារនោះឡើយ។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារដែលធនាគារត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែ បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ដែលអាចនឹងបង្កឱ្យមានផលប៉ះពាល់ ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់សងឡើយ។

ការប្រែប្រួលសភាពការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ពុំបានពិនិត្យឃើញសភាពការណ៍ណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវ ជាសារវន្តណាមួយនោះឡើយ។

ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនរងផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយដែលមានលក្ខណៈមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ ក្នុងការិយបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុនេះបានរៀបចំឡើងនោះទេ។

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការងារនៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅថ្ងៃដែលចេញរបាយការណ៍នេះរួមមាន៖

លោក Changseok Ohk	ប្រធានក្រុមប្រឹក្សាភិបាល
លោក Cheol Su Sohn	សមាជិកក្រុមប្រឹក្សាភិបាល
លោក Dong Woo Shin	សមាជិកក្រុមប្រឹក្សាភិបាល
អ្នកនាង Fiona Michelle Whyte	សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ
លោក គី ប៊ុនទ្រាន	សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ
លោក ដួង សារៈ	សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ
លោក Jeoung Hoon Yoo	សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ព័ត៌មានស្តីពីការកាន់កាប់ភាគហ៊ុនរបស់ធនាគារ និងក្រុមប្រឹក្សាភិបាលរបស់ខ្លួនគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 មានដូចខាងក្រោម៖

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 *ភាគរយនៃម្ចាស់កម្មសិទ្ធិ*
លោក Cheol Su Sohn	0.000009%

ក្រៅពីការបង្ហាញខាងលើនេះ ពុំមានអភិបាលផ្សេងណាដែលកាន់កាប់ភាគហ៊ុននៅក្នុងធនាគារ ឬនៅក្រុមហ៊ុនពាក់ព័ន្ធណាមួយឡើយ។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬសាជីវកម្មដទៃទៀតនោះឡើយ។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល (ត)

នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍នេះ ពុំមានអភិបាលណាម្នាក់របស់ធនាគារបានទទួល ឬមានសិទ្ធិទទួលបានន្ទវរត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុបដែលទទួលបាន ឬដល់កាលកំណត់ដែលត្រូវទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងធនាគារ ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិករបស់សាជីវកម្ម ឬក៏ជាមួយក្រុមហ៊ុនដែលមានអភិបាលជាសមាជិកដែលមានផលប្រយោជន៍ផ្អែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈធ្វើការរៈរាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនៅទំព័រទី11 ដល់ទី131 បានរៀបចំឡើងយ៉ាងត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(i) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្របនានា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

(ii) អនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”) ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(iii) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

(iv) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែគណៈគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(v) ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានារៈរាងថា បានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយថា បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ទ.ហ.អ.ក)។

ចុះហត្ថលេខាតំណាងឱ្យក្រុមប្រឹក្សាភិបាលដោយយោងទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលៈ

ព្រះរាជាណាចក្រកម្ពុជា
ធនាគារ អ៊ូរី (ខេមបូឌា) ម.ក
WOORI BANK (CAMBODIA) PLC.
KINGDOM OF CAMBODIA

ឈ្មោះ Ju Sug Kang

តួនាទី អគ្គនាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 26 ខែ មីនា ឆ្នាំ2026

KPMG Cambodia Ltd
GIA Tower, Sopheak Mongkul Street, Phum 14
Sangkat Tonle Bassac, Khan Chamkar Mon
Phnom Penh, Cambodia
+855 (17) 666 537 / +855 (81) 533 999 | kpmg.com.kh

របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិកនៃ
ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ហៅកាត់ថា "ធនាគារ") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសារវន្ត ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដូចបានបង្ហាញនៅទំព័រទី11 ដល់ទី131 (ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី *ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីធនាគារ ដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗទៀតស្របតាមលក្ខខណ្ឌតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលទទួលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី1 ដល់ទី6 និងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងថានឹងទទួលបានបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះឡើយ ហើយយើងខ្ញុំក៏មិនធ្វើការផ្តល់នូវអំណះអំណាង ណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ដែលអាចរកបានខាងលើ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានអសង្គតិភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬក៏ព័ត៌មានផ្សេងៗនេះបង្ហាញនូវកំហុសឆ្គងជាសារវន្តដែរឬទេ។

ប្រសិនបើផ្អែកទៅលើការអានព័ត៌មានផ្សេងៗ ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មអាចឱ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់គណៈគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

គណៈគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែគណៈគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុរបស់ធនាគារ។

ការទទួលខុសត្រូវរបស់សវនករ ចំពោះការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុស អាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងដោយឡែក ឬក៏រួមបញ្ចូលគ្នា អាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថា នឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្អែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈភាគនិយម ក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការគាក់តែង និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យនៃការរកមិនឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសដែលបណ្តាលមកពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចទាក់ទិននឹង ការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីគាក់តែងនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារឡើយ។
- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលធនាគារបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានា ដែលបានធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់គណៈគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតមានឡើង ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចបង្កឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរភាពអាជីវកម្មដែរ ឬទេ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌ នាពេលអនាគតអាចធ្វើឱ្យធនាគារបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។

- ធ្វើការវាយតម្លៃលើការបង្ហាញ ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មាន ក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្ត ដោយរួមបញ្ចូលទាំងចំណុចខ្វះខាតជាសារវន្ត ក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

ង៉ែ ហ៊ុយ

Senior Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី26 ខែមីនា ឆ្នាំ2026

ធនាគារ អ៊ីរី (ខេមបូឌា) ម.ក

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

	កំណត់សម្គាល់	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	4	14,471,927	58,075,843	17,960,933	72,292,755
ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា	5	279,943,012	1,123,411,307	213,529,427	859,455,944
ប្រាក់បញ្ញើនៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនានា	6	53,011,994	212,737,132	36,519,524	146,991,084
ឥណទាន និងបុរេប្រទាន ផ្តល់ដល់អតិថិជន	7	944,286,424	3,789,421,420	1,186,409,740	4,775,299,204
មូលបត្រវិនិយោគ	8	15,353	61,612	15,353	61,796
ទ្រព្យ និងបរិក្ខារ	9	15,523,217	62,294,670	18,846,552	75,857,372
ទ្រព្យសកម្មអរូបី	10	5,372,701	21,560,649	6,501,491	26,168,501
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	11	13,635,997	54,721,256	15,473,338	62,280,185
ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ	14ឃ	6,092,985	24,451,149	4,932,572	19,853,602
ឥណទានពន្ធលើប្រាក់ចំណេញ	14គ	3,867,930	15,522,003	2,443,302	9,834,291
ទ្រព្យសកម្មផ្សេងៗ	12	4,105,611	16,475,817	4,280,582	17,229,342
ទ្រព្យសកម្មសរុប		**1,340,327,151**	**5,378,732,858**	**1,506,912,814**	**6,065,324,076**
បំណុល និងមូលធនរបស់តាកុងនិក					
បំណុល					
ប្រាក់បញ្ញើរបស់អតិថិជន និង គ្រឹះស្ថានហិរញ្ញវត្ថុនានា	13	770,782,358	3,093,149,603	738,025,372	2,970,552,122
ប្រាក់កម្ចី	15	68,753,293	275,906,965	100,491,365	404,477,744
គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ	16	50,280,972	201,777,541	211,250,275	850,282,357
បំណុលភតិសន្យា	17	13,819,281	55,456,775	15,401,256	61,990,055
បំណុលផ្សេងៗ	18	6,911,250	27,734,846	6,333,430	25,492,056
បំណុលសរុប		**910,547,154**	**3,654,025,730**	**1,071,501,698**	**4,312,794,334**

ធនាគារ អ៊ីរី (ខេមបូដា) ម.ក

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ត)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

	កំណត់សម្គាល់	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
មូលធនរបស់តាកុនិក					
ដើមទុន	19	275,895,100	1,103,580,400	275,895,100	1,103,580,400
ទុនបម្រុងតាមបទប្បញ្ញត្តិ	20	21,375,934	85,858,913	6,440,786	25,924,164
ប្រាក់ចំណេញរក្សាទុក		126,552,463	517,788,623	147,118,730	600,309,789
ទុនបម្រុងរួមបញ្ចូលគ្នា	35	5,956,500	24,284,651	5,956,500	24,284,651
ទុនបម្រុងពីការប្តូរវិបិយប័ណ្ណ		-	(6,805,459)	-	(1,569,262)
មូលធនរបស់តាកុនិកសរុប		**429,779,997**	**1,724,707,128**	**435,411,116**	**1,752,529,742**
បំណុល និងមូលធនរបស់តាកុនិកសរុប		**1,340,327,151**	**5,378,732,858**	**1,506,912,814**	**6,065,324,076**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អ៊ីរី (ខេមបូឌា) ម.ក

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

		2025		2024	
	កំណត់សម្គាល់	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
ចំណូលការប្រាក់	21	144,080,381	577,906,408	169,909,101	691,699,950
ចំណាយការប្រាក់	22	(60,169,938)	(241,341,621)	(78,996,070)	(321,593,001)
ចំណូលការប្រាក់សុទ្ធ		**83,910,443**	**336,564,787**	**90,913,031**	**370,106,949**
កម្រៃ និងចំណូលជើងសា	23	842,150	3,377,864	844,800	3,439,181
កម្រៃ និងចំណាយជើងសា	23	(578,921)	(2,322,052)	(2,060,466)	(8,388,157)
ចំណូល/(ចំណាយ) កម្រៃជើងសាសុទ្ធ	23	**263,229**	**1,055,812**	**(1,215,666)**	**(4,948,976)**
ខាតលើឱនភាពនៃតម្លៃ លើឧបករណ៍ហិរញ្ញវត្ថុ	24	(43,945,597)	(176,265,790)	(39,891,301)	(162,397,486)
ចំណូលផ្សេងៗសុទ្ធ	25	12,678,249	50,852,457	6,922,478	28,181,408
ចំណាយលើបុគ្គលិក	26	(34,647,954)	(138,972,943)	(36,315,359)	(147,839,826)
ចំណាយលើរំលស់	27	(9,961,830)	(39,956,900)	(9,662,032)	(39,334,132)
ចំណាយប្រតិបត្តិការផ្សេងៗ	28	(15,088,072)	(60,518,257)	(15,305,658)	(62,309,334)
ប្រាក់ខាតមុនដកពន្ធ		**(6,791,532)**	**(27,240,834)**	**(4,554,507)**	**(18,541,397)**
ចំណូលពន្ធលើប្រាក់ចំណេញ	14ខ	1,160,413	4,654,417	1,597,842	6,504,815
ប្រាក់ខាតសុទ្ធសម្រាប់ ការិយបរិច្ឆេទ		**(5,631,119)**	**(22,586,417)**	**(2,956,665)**	**(12,036,582)**
លទ្ធផលលម្អិតផ្សេងៗ					
ធាតុដែលមិនត្រូវបានធ្វើចំណាត់ថ្នាក់ ឡើងវិញក្នុងរបាយការណ៍ ចំណេញ ឬខាត					
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(5,236,197)	-	(17,666,061)
លទ្ធផលលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ		**(5,631,119)**	**(27,822,614)**	**(2,956,665)**	**(29,702,643)**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

	ដើមទុន		ទុនបម្រុងតាមបទប្បញ្ញត្តិ		ប្រាក់ចំណេញរក្សាទុក		ទុនបម្រុងរួមបញ្ចូលគ្នា		ទុនបម្រុងពីការប្តូររូបិយប័ណ្ណ		សរុប	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
នាថ្ងៃទី1 ខែមករា ឆ្នាំ2025	275,895,100	1,103,580,400	6,440,786	25,924,164	147,118,730	600,309,789	5,956,500	24,284,651	-	(1,569,262)	435,411,116	1,752,529,742
ប្រតិបត្តិការទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន												
ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅ												
ទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់ 20)	-	-	14,935,148	59,934,749	(14,935,148)	(59,934,749)	-	-	-	-	-	-
លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ												
ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	(5,631,119)	(22,586,417)	-	-	-	-	(5,631,119)	(22,586,417)
លទ្ធផលខាតលម្អិតផ្សេង –												
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	-	-	(5,236,197)	-	(5,236,197)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	**275,895,100**	**1,103,580,400**	**21,375,934**	**85,858,913**	**126,552,463**	**517,788,623**	**5,956,500**	**24,284,651**	**-**	**(6,805,459)**	**429,779,997**	**1,724,707,128**
នាថ្ងៃទី1 ខែមករា ឆ្នាំ2024	175,895,100	703,580,400	-	-	156,516,181	638,270,535	5,956,500	24,284,651	-	16,096,799	338,367,781	1,382,232,385
ប្រតិបត្តិការទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន												
ការបង្កើនដើមទុន	100,000,000	400,000,000	-	-	-	-	-	-	-	-	100,000,000	400,000,000
ផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិទៅ												
ប្រាក់ចំណេញរក្សាទុក (កំណត់សម្គាល់ 20)	-	-	6,440,786	25,924,164	(6,440,786)	(25,924,164)	-	-	-	-	-	-
លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ												
ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	(2,956,665)	(12,036,582)	-	-	-	-	(2,956,665)	(12,036,582)
លទ្ធផលខាតលម្អិតផ្សេង –												
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	-	-	(17,666,061)	-	(17,666,061)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	**275,895,100**	**1,103,580,400**	**6,440,786**	**25,924,164**	**147,118,730**	**600,309,789**	**5,956,500**	**24,284,651**	**-**	**(1,569,262)**	**435,411,116**	**1,752,529,742**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អ៊ីរី (ខេមបូឌា) ម.ក

របាយការណ៍លំហូរសាច់ប្រាក់
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

		2025		2024	
	កំណត់សម្គាល់	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
ប្រាក់ខាតមុនដកពន្ធ		(6,791,532)	(27,240,834)	(4,554,507)	(18,541,397)
និយ័តភាពលើ៖					
ការខាតបង់ឱនភាពនៃតម្លៃសុទ្ធ លើឧបករណ៍ហិរញ្ញវត្ថុ	24	43,945,597	176,265,790	39,891,301	162,397,486
ចំណាយការប្រាក់	22	60,169,938	241,341,621	78,996,070	321,593,001
រំលស់	27	9,961,830	39,956,900	9,662,032	39,334,132
ចំណេញពីការលក់ទ្រព្យ និង បរិក្ខារ និងភតិសន្យា	25	(6,845)	(27,455)	-	-
ការលុបចោលទ្រព្យ និងបរិក្ខារ	28	-	-	37	151
ចំណូលការប្រាក់	21	(144,080,381)	(577,906,408)	(169,909,101)	(691,699,950)
ប្រាក់ខាតពីអត្រាប្តូរប្រេីយប័ណ្ណ ដែលមិនទាន់ទទួលស្គាល់		-	-	70,575	287,311
		(36,801,393)	(147,610,386)	(45,843,593)	(186,629,266)
បម្រែបម្រួលនៃ៖					
សមតុល្យនៅធនាគារជាតិនៃកម្ពុជា		9,983,490	40,043,778	8,255,580	33,608,466
ឥណទានផ្តល់ដល់អតិថិជន		214,618,570	860,835,084	(43,543,636)	(177,266,142)
ទ្រព្យសកម្មផ្សេងៗ		323,849	1,298,958	(1,176,206)	(4,788,335)
ប្រាក់បញ្ញើរបស់អតិថិជន		27,593,280	110,676,646	279,923,444	1,139,568,341
បំណុលផ្សេងៗ		575,968	2,310,208	(404,258)	(1,645,734)
សាច់ប្រាក់ទទួលបានពីប្រតិបត្តិការ		216,293,764	867,554,288	197,211,331	802,847,330
ការប្រាក់បានទទួល		127,649,990	512,004,110	170,656,875	694,744,138
ការប្រាក់បានបង់		(56,052,135)	(224,825,113)	(61,029,261)	(248,450,122)
ពន្ធលើប្រាក់ចំណេញបានបង់	14គ	(1,424,628)	(5,714,183)	(4,286,477)	(17,450,248)
សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពប្រតិបត្តិការ		**286,466,991**	**1,149,019,102**	**302,552,468**	**1,231,691,098**

របាយការណ៍លំហូរសាច់ប្រាក់ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

	កំណត់សម្គាល់	2025 ដុល្លារអាមេរិក	2025 ពាន់រៀល (កំណត់សម្គាល់ 3)	2024 ដុល្លារអាមេរិក	2024 ពាន់រៀល (កំណត់សម្គាល់ 3)
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
សាច់ប្រាក់ទទួលបានពី					
ការលក់ទ្រព្យ និងបរិក្ខារ		2,839	11,387	-	-
ការទិញទ្រព្យសកម្មអរូបី	10	(241,050)	(966,852)	(1,168,165)	(4,755,600)
ការទិញទ្រព្យ និងបរិក្ខារ	9	(1,671,496)	(6,704,370)	(5,338,212)	(21,731,861)
(ប្រាក់តម្កល់)/ប្រាក់ទទួលបានពី					
ធនាគារនានា		(33,018,338)	(132,436,554)	45,252,300	184,222,113
សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/					
ទទួលបានពីសកម្មភាពវិនិយោគ		**(34,928,045)**	**(140,096,389)**	**38,745,923**	**157,734,652**
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី	15	24,919,013	99,950,161	80,574,534	328,018,928
ការទូទាត់ប្រាក់កម្ចី	15	(56,860,267)	(228,066,531)	(92,500,000)	(376,567,500)
សាច់ប្រាក់ទទួលបានពីគណនី					
ទូទាត់ឱ្យសម្ព័ន្ធញាតិ	16	-	-	37,000,000	150,627,000
ការទូទាត់លើគណនី					
ទូទាត់ឱ្យសម្ព័ន្ធញាតិ	16	(160,000,000)	(641,760,000)	(369,700,000)	(1,505,048,700)
ការទូទាត់បំណុលភតិសន្យា	17	(3,200,756)	(12,838,232)	(2,986,247)	(12,157,012)
សាច់ប្រាក់ទទួលបានពី					
ការបោះភាគហ៊ុនថ្មី		-	-	100,000,000	407,100,000
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង					
សកម្មភាពហិរញ្ញប្បទាន		**(195,142,010)**	**(782,714,602)**	**(247,611,713)**	**(1,008,027,284)**
ការកើនឡើងសុទ្ធនៃសាច់ប្រាក់					
និងសាច់ប្រាក់សមមូល		**56,396,936**	**226,208,111**	**93,686,678**	**381,398,466**
សាច់ប្រាក់ និងសាច់ប្រាក់សមមូល					
នៅដើមការិយបរិច្ឆេទ		152,317,245	613,076,911	58,630,567	239,505,866
លម្អៀងពីការប្តូរប្រាក់		-	(1,715,014)	-	(7,827,421)
សាច់ប្រាក់ និងសាច់ប្រាក់សមមូល					
នៅចុងការិយបរិច្ឆេទ	4	**208,714,181**	**837,570,008**	**152,317,245**	**613,076,911**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

កំណត់សម្គាល់ទាំងនេះ គឺជាផ្នែកមួយដ៏សំខាន់ ហើយគួរតែត្រូវបានអានជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ។

1. ព័ត៌មានអំពីធនាគារ

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក (ហៅកាត់ថា "ធនាគារ") បានទទួលអាជ្ញាបណ្ណជាធនាគារពាណិជ្ជដែលមានប្រតិបត្តិការ និងចុះបញ្ជីក្នុង ព្រះរាជាណាចក្រកម្ពុជា។

ធនាគារ ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី19 ខែវិច្ឆិកា ឆ្នាំ2003 ក្រោមការចុះបញ្ជីលេខ 1846E/2003 ហើយបន្ទាប់មកបានប្តូរលេខចុះបញ្ជី 00005269 ចេញដោយក្រសួងពាណិជ្ជកម្ម ("MoC") នៅក្រោមឈ្មោះដើម វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី។ នៅថ្ងៃទី18 ខែឧសភា ឆ្នាំ2004 ធនាគារទទួលបានអាជ្ញាបណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា។ នៅថ្ងៃទី17 ខែកុម្ភៈ ឆ្នាំ2011 ធនាគារទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ក្នុងការធ្វើអាជីវកម្មសេវាកម្មទទួលប្រាក់បញ្ញើ ពីធនាគារជាតិនៃកម្ពុជា។

ធនាគារជាបុត្រសម្ព័ន្ធរបស់ វីសិនហ្វាន់ អន្តរជាតិ ដែលមានកម្មសិទ្ធិ 99.9998% ដែលជាក្រុមហ៊ុនចុះបញ្ជីនៅសហរដ្ឋអាមេរិក។ នៅថ្ងៃទី21 ខែឧសភា ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជា បានអនុម័តជាផ្លូវការទៅលើការផ្ទេរភាគហ៊ុន 100% របស់ធនាគារទៅឱ្យ ធនាគារ អ៊ូរី កូរ៉េ ដែលជាធនាគារបានបង្កើតឡើងនៅក្នុងសាធារណៈរដ្ឋកូរ៉េ ហើយបានប្តូរឈ្មោះធនាគារទៅជា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក។

នៅថ្ងៃទី22 ខែកក្កដា ឆ្នាំ2019 ធនាគារបានចុះកិច្ចព្រមព្រៀងរួមបញ្ចូលគ្នា ជាមួយគ្រឹះស្ថាន Woori Finance Cambodia Plc. ("WFC") ដែលមានម្ចាស់ភាគហ៊ុនតែមួយគត់ (ធនាគារ អ៊ូរី កូរ៉េ) ប្រតិបត្តិការអាជីវកម្មចម្បង ជាសេវាកម្មមីក្រូហិរញ្ញវត្ថុជូនប្រជាជន ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកម្ពុជា ក្នុងគោលបំណងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាជននៅតាមសហគមន៍ ដោយផ្តោតទៅលើការបង្កើនប្រាក់ចំណូលតាមរយៈការលើកកម្ពស់សកម្មភាពអាជីវកម្មរបស់អង្គភាពខ្នាតតូច និងមធ្យម ការធ្វើអាជីវកម្ម នៅតាមជនបទ និងវិស័យកសិកម្ម ដោយប្រើប្រាស់សេវាប្រាក់កម្ចី និងប្រាក់បញ្ញើ។ យោងតាមកិច្ចព្រមព្រៀងរួមបញ្ចូលគ្នា WFC នឹងត្រូវបានរំលាយបន្ទាប់ពីការរួមបញ្ចូលគ្នារួច។ ការរួមបញ្ចូលគ្នា និងការរំលាយ WFC នេះ មានប្រសិទ្ធភាពនៅថ្ងៃទី10 ខែកុម្ភៈ ឆ្នាំ2020 ដោយមានការអនុម័តពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម។ ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម បានអនុម័តលើការចុះបញ្ជីសកម្មភាពអាជីវកម្មបន្ថែម លើសកម្មភាពអាជីវកម្មអចលនទ្រព្យផ្ទាល់ខ្លួន ឬការជួល នៅថ្ងៃទី21 ខែវិច្ឆិកា ឆ្នាំ2024 និងថ្ងៃទី11 ខែធ្នូ ឆ្នាំ2024 រៀងគ្នា។

នៅថ្ងៃទី16 ខែវិច្ឆិកា ឆ្នាំ2021 និងនៅថ្ងៃទី2 ខែធ្នូ ឆ្នាំ2021 ក្រុមហ៊ុនដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក បានទទួលការអនុម័តជាផ្លូវការពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្មរៀងគ្នា ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មក្រោមឈ្មោះ "ធនាគារ អ៊ូរី (ខេមបូឌា) ម.ក"។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្មក៏បានអនុម័តក្នុងការផ្ទេរហ៊ុនចំនួន 1ហ៊ុនពីធនាគារ អ៊ូរី កូរ៉េ ទៅឱ្យលោក Hong Ju Kim ដែលជាជនជាតិកូរ៉េ។ ធនាគារបានប្រកាស និងបានចាប់ផ្តើមធ្វើប្រតិបត្តិការជាផ្លូវការក្នុងនាមជាធនាគារពាណិជ្ជ សាធារណៈ នៅថ្ងៃទី3 ខែមករា ឆ្នាំ2022។ នាថ្ងៃទី13 ខែវិច្ឆិកា ឆ្នាំ2024 ធនាគារជាតិនៃកម្ពុជា បានអនុម័តលើការតែងតាំងលោក Cheol Su Sohn ជាអគ្គនាយកប្រតិបត្តិរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

1. ព័ត៌មានអំពីធនាគារ (ត)

នាថ្ងៃទី29 ខែកក្កដា ឆ្នាំ2025 ធនាគារជាតិនៃកម្ពុជា បានអនុម័តការផ្ទេរភាគហ៊ុនចំនួន 1 ភាគហ៊ុន ពី លោក Hong Ju Kim ទៅ លោក Cheol Su Sohn។ វិសោធនកម្មលើអនុស្សរណៈ និងលក្ខន្តិក: ("MoA") បានដាក់តម្កល់នៅក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី25 ខែសីហា ឆ្នាំ2025។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់សេវាកម្ម និងផលិតផលហិរញ្ញវត្ថុដូចជាប្រាក់បញ្ញើ ឥណទាន រួមទាំងសេវាផ្ទេរប្រាក់ក្នុងស្រុក និងក្រៅប្រទេស សេវាធនាគារចល័ត សេវាទូទាត់សាច់ប្រាក់ សេវាកម្មម៉ាស៊ីនដក និងដាក់ប្រាក់ដោយស្វ័យប្រវត្តិ លិខិតធានារបស់ធនាគារ សកម្មភាពអចលនទ្រព្យដែលមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬជួលនិងសេវាកម្មធនាគារផ្សេងៗទៀតដែលផ្តល់សេវាជូនប្រជាជនកម្ពុជា តាមរយៈការិយាល័យកណ្តាល និងសាខារបស់ខ្លួននៅក្នុងរាជធានីភ្នំពេញ និងសាខាតាមបណ្តាខេត្តផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារ មានទីតាំងនៅអគារលេខ 398 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារ មានប្រតិបត្តិការចំនួន 25 ខេត្តក្រុង ដែលមានសាខាបណ្តាញចំនួន 140 សាខា (ឆ្នាំ2024៖ 143 សាខា)។

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ធនាគារមានបុគ្គលិកសរុបចំនួន 3,539 នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024៖ ចំនួន 3,884 នាក់)។

2. មូលដ្ឋាននៃការរៀបចំ

(ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហៅកាត់ថា ("ស.រ.ទ.ហ.អ.ក")។

ព័ត៌មានលម្អិត ទាក់ទងនឹងគោលនយោបាយគណនេយ្យសារវន្តរបស់ធនាគារ ត្រូវបានលាតត្រដាងក្នុងកំណត់សម្គាល់ 33។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាល និងភាទុនិកនៃធនាគារ នៅថ្ងៃទី26 ខែមីនា ឆ្នាំ2026។

(ខ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ដោយសារធនាគារធ្វើប្រតិបត្តិការ និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក គណៈគ្រប់គ្រងក៏បានកំណត់ថា ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយបណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រតិពត្តិការណ៍ និងកាលៈទេសៈរបស់ធនាគារ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ធនាគារ។ តួលេខទាំងអស់ត្រូវបានបង្គត់ចំនួនមួយដុល្លារអាមេរិកដែលជិតបំផុត លុះត្រាតែមានការបង្ហាញផ្សេងពីនោះ។

2. មូលដ្ឋាននៃការរៀបចំ (ត)

(គ) ការវិនិច្ឆ័យ និងការប៉ាន់ស្មាន

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ គណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យរបស់ធនាគារ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មាន ត្រូវបានទទួលស្គាល់តាមវិធីសាស្ត្រទស្សនៈវិស័យ។

(i) ការវិនិច្ឆ័យ

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានផលប៉ះពាល់ជាសារវន្ត លើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ដូចខាងក្រោម៖

- កំណត់សម្គាល់ 33គ(ii)៖ ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃគំរូអាជីវកម្មដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") លើចំនួនប្រាក់ដើមដែលនៅសល់។
- កំណត់សម្គាល់ 33គ(vii)៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូង ដោយកំណត់វិធីសាស្ត្រសម្រាប់បញ្ចូលព័ត៌មានទៅក្នុងការវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន ("ECL") និងការជ្រើសរើស និងការអនុម័តលើគំរូដែលប្រើដើម្បីវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន។

(ii) ការសន្មត និងការប៉ាន់ស្មានភាពមិនប្រាកដប្រជា

ព័ត៌មានអំពីភាពមិនប្រាកដប្រជានៃការសន្មត និងការប៉ាន់ស្មាន ដែលមានហានិភ័យជាសារវន្ត ដែលអាចធ្វើឱ្យមាននិយ័តភាពលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនាពេលបន្ទាប់ត្រូវបានបញ្ចូលទៅក្នុងកំណត់សម្គាល់ ដូចខាងក្រោម៖

- កំណត់សម្គាល់ 33គ(vii)៖ ឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ៖ ការកំណត់បញ្ចូលសមាសធាតុទៅក្នុងគំរូនៃការវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន រួមទាំងការសន្មតសំខាន់ៗដែលប្រើក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់ ដែលអាចប្រមូលមកវិញ និងការបញ្ចូលព័ត៌មាននៃការប្រមើលនាពេលអនាគត។
- កំណត់សម្គាល់ 33គ(vi)៖ ការកំណត់តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុដែលមិនមានទិន្នន័យដែលអាចអង្កេតបានជាសារវន្ត។

3. ការប្តូរូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលត្រូវជារូបិយប័ណ្ណមុខងាររបស់ធនាគារ។ ការប្តូរូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀលខ្មែរ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូរូបិយប័ណ្ណនេះធ្វើឡើងដោយអនុលោមទៅតាម ស.គ.អ.ក 21 – *ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរូបិយប័ណ្ណបរទេស*។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយគណនីមូលធន ត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្ត្រ។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរសាច់ប្រាក់ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ដែលអត្រានេះត្រូវបានចាត់ទុកថាមានលក្ខណៈសមស្រប ពីព្រោះអត្រាប្តូរប្រាក់នេះ មិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូរូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "ទុនបម្រុងពីការប្តូរូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ធនាគារប្រើប្រាស់អត្រាប្តូរូបិយប័ណ្ណដូចខាងក្រោម៖

			អត្រានាកាលបរិច្ឆេទ	
ការិយបរិច្ឆេទហិរញ្ញវត្ថុដែលបានបញ្ចប់			**រាយការណ៍**	**អត្រាមធ្យម**
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	1 ដុល្លារអាមេរិក	=	4,013 រៀល	4,011 រៀល
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	1 ដុល្លារអាមេរិក	=	4,025 រៀល	4,071 រៀល

ការប្តូរូបិយប័ណ្ណនេះ មិនគួរត្រូវបានយកមកបកស្រាយថាតួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

4. សាច់ប្រាក់ក្នុងដៃ

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
សាច់ប្រាក់ក្នុងដៃ	11,626,826	46,658,453	15,185,214	61,120,486
សាច់ប្រាក់នៅក្នុងម៉ាស៊ីន ATMs	2,845,101	11,417,390	2,775,719	11,172,269
	14,471,927	58,075,843	17,960,933	72,292,755

4. សាច់ប្រាក់ក្នុងដៃ (ត)

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
តាមរូបិយប័ណ្ណ៖				
ប្រាក់ដុល្លារអាមេរិក	9,763,241	39,179,886	12,086,409	48,647,796
ប្រាក់រៀលខ្មែរ	4,686,387	18,806,471	5,584,852	22,479,029
ប្រាក់បាតថៃ	22,299	89,486	289,672	1,165,930
	14,471,927	58,075,843	17,960,933	72,292,755

សម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសមមូលសាច់ប្រាក់មានដូចខាងក្រោម៖

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
សាច់ប្រាក់ក្នុងដៃ និងក្នុងម៉ាស៊ីន ATMs	14,471,927	58,075,843	17,960,933	72,292,755
ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា				
គណនីចរន្ត	140,281,304	562,948,873	114,579,160	461,181,119
គណនីទូទាត់	5,173,484	20,761,191	5,522,305	22,227,278
មូលបត្រអាចជួញដូរបាន ("NCD") ក្នុងរយៈពេល បីខែ ឬតិចជាងនេះ	11,005,803	44,166,287	-	-
សមតុល្យសាច់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា				
គណនីចរន្ត	18,637,467	74,792,155	5,772,726	23,235,222
គណនីសន្សំ	19,144,196	76,825,659	8,482,121	34,140,537
	208,714,181	837,570,008	152,317,245	613,076,911

5. ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
គណនីចរន្ត	140,281,304	562,948,873	114,579,160	461,181,119
គណនីទូទាត់	5,173,484	20,761,191	5,522,305	22,227,278
មូលបត្រអាចជួញដូរបាន ("NCD") ក	51,238,547	205,620,289	194,795	784,050
ប្រាក់តម្កល់ធានាលើដើមទុន ខ	27,590,000	110,718,670	27,590,000	111,049,750
ទុនបម្រុងកាតព្វកិច្ចលើ ប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់កម្ចីអនិវាសនជន គ	55,659,677	223,362,284	65,643,167	264,213,747
	279,943,012	1,123,411,307	213,529,427	859,455,944

ក. មូលបត្រអាចជួញដូរបាន ("NCD")

ធនាគារ ដាក់មូលបត្រអាចជួញដូរបាន ("NCD") ចំនួន 80,000 ដុល្លារអាមេរិក និង 200,000,000 រៀល នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024៖ 193,379 ដុល្លារអាមេរិក) ជាទ្រព្យបញ្ចាំទៅលើឥណទានវិបារូបន៍នៅធនាគារជាតិនៃកម្ពុជា ដែលទាក់ទងជាមួយនឹងសេវាប្រព័ន្ធធនាគារ Cambodian Shared Switch ("CSS")។ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ធនាគារមិនទាន់បានប្រើប្រាស់ឥណទានវិបារូបន៍លើការទូទាត់ណាមួយនៅឡើយទេ។ មូលបត្រអាចជួញដូរបានទទួលបាន ការប្រាក់ចន្លោះពី 1.03% ទៅ 1.30% គិតត្រឹមថ្ងៃ31 ខែធ្នូ ឆ្នាំ2025 (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024៖ 1.18% ទៅ 1.40%) ក្នុងមួយឆ្នាំ។

ខ. ប្រាក់តម្កល់ធានាលើដើមទុន

យោងតាមប្រកាសលេខ ធ7-01-136 ប្រ.ក ចុះ ថ្ងៃទី15 ខែតុលា ឆ្នាំ2001 ធនាគារតម្រូវឱ្យរក្សាទុកប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង 10% នៃដើមទុនដែលបានចុះបញ្ជី។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារបានឡើយ ប៉ុន្តែធនាគារអាចដកយកវិញបាន នៅពេលដែលធនាគារស្ម័គ្រចិត្តបញ្ចប់អាជីវកម្មរបស់ខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គ. ទុនបម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់កម្ចីអនិវាសនជន

ទុនបម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់កម្ចីអនិវាសនជន ត្រូវបានគណនាតាមអត្រា 8% សម្រាប់រូបិយប័ណ្ណខ្មែររៀល និងអត្រា 12.50% សម្រាប់រូបិយប័ណ្ណផ្សេងៗទៀតនៃចំនួនប្រាក់បញ្ញើរបស់អតិថិជនសរុប ធនាគារក្រៅប្រទេស និងប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ព្រមទាំងប្រាក់កម្ចីរបស់អនិវាសនជន។ ស្របតាមប្រកាសលេខ ធ7-018-282 ប្រ.ក របស់ធនាគារជាតិនៃកម្ពុជា ស្តីពីការតម្រូវឱ្យមានការរក្សាទុកនូវទុនបម្រុងសម្រាប់ទូទាត់ជាមួយប្រាក់តម្កល់ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ។ ទុនបម្រុងកាតព្វកិច្ចសម្រាប់រូបិយប័ណ្ណខ្មែររៀល និងរូបិយប័ណ្ណផ្សេងទៀតមិនមានការប្រាក់ឡើយចាប់តាំងពីថ្ងៃទី29 ខែសីហា ឆ្នាំ2018។

5. ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា (ត)

នៅថ្ងៃទី18 ខែមីនា ឆ្នាំ2020 ធនាគារជាតិនៃកម្ពុជា បានចេញផ្សាយនូវសេចក្តីណែនាំស្តីអំពីការកាត់បន្ថយអត្រាទុនបម្រុងកាតព្វកិច្ច ("RRR") មកត្រឹម7% សម្រាប់ទាំងប្រាក់បញ្ញើ និងប្រាក់កម្ចីរូបិយប័ណ្ណក្នុងស្រុក និងបរទេស។

យោងតាងប្រកាសលេខ ធ7-023-005 ប្រ.ក ស្តីពីទុនបម្រុងកាតព្វកិច្ច ចុះថ្ងៃទី9 ខែមករា ឆ្នាំ2023 សំដៅលើទុនបម្រុងអប្បបរមាដែលបានគណនាតាមអត្រា 7% សម្រាប់ប្រាក់រៀលខ្មែរ និង 9% សម្រាប់រូបិយប័ណ្ណផ្សេងទៀត (មានសុពលភាពពីថ្ងៃទី1 ខែមករា ឆ្នាំ2023 ដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023) និង 12.50% (មានសុពលភាពពីថ្ងៃទី1 ខែមករា ឆ្នាំ2024 តទៅ) នៃតម្លៃសរុបនៃប្រាក់បញ្ញើរបស់អតិថិជន ធនាគារអនិវាសនជន និងប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងប្រាក់កម្ចីអនិវាសនជន។

នៅថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2023 ធនាគារជាតិនៃកម្ពុជាបានប្រកាសតាមរយៈលិខិតលេខ ធ7-023-438 ដើម្បីពន្យារពេលក្នុងការអនុវត្តតម្រូវការទុនបម្រុងកាតព្វកិច្ច សម្រាប់សមតុល្យប្រាក់កម្ចីជាមធ្យមប្រចាំថ្ងៃ រហូតដល់ថ្ងៃទី1 ខែកញ្ញា ឆ្នាំ2023។

នៅថ្ងៃទី16ខែសីហា ឆ្នាំ2023 សមាគមធនាគារនៅកម្ពុជា បានដាក់លិខិតស្នើសុំលេខ 194/2023 ទៅកាន់ធនាគារជាតិនៃកម្ពុជា សម្រាប់ការពន្យារពេលមួយផ្សេងទៀត ក្នុងការអនុវត្តទុនបម្រុងកាតព្វកិច្ចធៀបនឹងប្រាក់កម្ចីនៅសមតុល្យមធ្យមប្រចាំថ្ងៃរហូតដល់ចុងខែមិថុនា ឆ្នាំ2024។ នៅថ្ងៃទី23ខែវិច្ឆិកា ឆ្នាំ2023 ធនាគារជាតិនៃកម្ពុជាបានឆ្លើយតបទៅសមាគមធនាគារនៅកម្ពុជា តាមរយៈលិខិតលេខ ធ7-023-2621 ឆ.ត អនុញ្ញាតឱ្យស្តាប់នរក្សាទុនបម្រុងកាតព្វកិច្ចក្នុងអត្រា 7%រហូតដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ហើយការរក្សាទុនបម្រុងកាតព្វកិច្ចនេះនឹងត្រូវបន្តក្នុងអត្រា 7%រហូតដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ស្របតាមប្រកាសលេខ ធ7-024-1718 ឆ.ត ចុះថ្ងៃទី 21 ខែសីហា ឆ្នាំ2024។

នាថ្ងៃទី5 ខែមករា ឆ្នាំ2026 ធនាគារជាតិនៃកម្ពុជា បានចេញលិខិតលេខ ធ30-026-013 អនុញ្ញាតឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុរក្សាទុកទុនបម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសក្នុងអត្រា 7%រហូតដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2026។

ឃ. អត្រាការប្រាក់ (ក្នុងមួយឆ្នាំ)

អត្រាការប្រាក់ប្រចាំឆ្នាំសម្រាប់សមតុល្យ នៅធនាគារជាតិនៃកម្ពុជា នាចុងការិយបរិច្ឆេទ មានដូចខាងក្រោម៖

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024
មូលបត្រអាចជួញដូរបាន("NCD")	0.19% - 1.30%	1.18% - 1.40%
ប្រាក់តម្កល់ធានាលើដើមទុន	1.03%	1.31%
គណនីចរន្ត	ពុំមាន	ពុំមាន
គណនីទូទាត់	ពុំមាន	ពុំមាន
ទុនបម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់ អតិថិជន និងប្រាក់កម្ចីអនិវាសនជន	ពុំមាន	ពុំមាន

6. សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា តាមរំលស់ថ្លៃដើម				
គណនីចរន្ត	18,637,467	74,792,155	5,772,726	23,235,222
គណនីសន្សំ	19,144,196	76,825,659	8,482,121	34,140,537
ប្រាក់បញ្ញើមានកាលកំណត់	15,294,904	61,378,450	22,314,515	89,815,923
	53,076,567	212,996,264	36,569,362	147,191,682
ដក៖ សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ	(64,573)	(259,132)	(49,838)	(200,598)
	53,011,994	212,737,132	36,519,524	146,991,084

ធនាគារប្រឈមមុខនឹងហានិភ័យឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖

- ហានិភ័យឥណទាន
- ហានិភ័យទីផ្សារ
- ហានិភ័យសន្ទនីយភាព និង
- ហានិភ័យប្រតិបត្តិការ

កំណត់សម្គាល់នេះ បង្ហាញពីព័ត៌មានស្តីពី ហានិភ័យនីមួយៗខាងលើរបស់ធនាគារ ដែលមានគោលដៅ គោលការណ៍ណែនាំ និងវិធានការរបស់ធនាគារ ដើម្បីវាស់វែង និងគ្រប់គ្រងនូវហានិភ័យដែលកើតឡើង និង ការគ្រប់គ្រងនូវដើមទុនរបស់ធនាគារ។

មុខងារគ្រប់គ្រងហានិភ័យ និងរចនាសម្ព័ន្ធអភិបាលកិច្ច

ក្រុមប្រឹក្សាភិបាលរបស់ធនាគារមានទំនួលខុសត្រូវរួមសម្រាប់ការបង្កើត និងត្រួតពិនិត្យក្របខ័ណ្ឌគ្រប់គ្រង ហានិភ័យរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការក្រុមប្រឹក្សាភិបាលហានិភ័យ ("BRC") ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យគោលនយោបាយគ្រប់គ្រងហានិភ័យរបស់ធនាគារ និងធានានូវការអនុវត្ត សមស្របនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ រួមទាំងការអនុលោមតាមបទប្បញ្ញត្តិ។

គោលនយោបាយគ្រប់គ្រងហានិភ័យរបស់ធនាគារ ត្រូវបានបង្កើតឡើងដើម្បីកំណត់លក្ខណៈ និងវិភាគ ហានិភ័យដែលធនាគារបានប្រឈម ដើម្បីកំណត់ និងគ្រប់គ្រងកម្រិតហានិភ័យឱ្យបានសមស្រប និងតាមដាន ហានិភ័យ និងការប្រកាន់ខ្ជាប់នូវដែនកំណត់។ គោលនយោបាយ និងប្រព័ន្ធគ្រប់គ្រងហានិភ័យ ត្រូវបាន ពិនិត្យឡើងវិញជាប្រចាំដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារ និងសកម្មភាពរបស់ធនាគារ។ ធនាគារ តាមរយៈស្តង់ដានៃការបណ្តុះបណ្តាល ការគ្រប់គ្រង និងនីតិវិធីគ្រប់គ្រងរបស់ខ្លួន មានគោលបំណងបង្កើតនូវ វិន័យ និងការត្រួតពិនិត្យស្ថានភាព ដែលបុគ្គលិកទាំងអស់យល់ពីតួនាទី និងកាតព្វកិច្ចរបស់ពួកគេ។

គណៈកម្មការសវនកម្មរបស់ធនាគារ ត្រួតពិនិត្យពីរបៀបគណៈគ្រប់គ្រង ដោយអនុលោមតាមគោលការណ៍ និង នីតិវិធីគ្រប់គ្រងហានិភ័យរបស់ធនាគារ និងពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់នៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ទាក់ទងនឹងហានិភ័យដែលធនាគារបានប្រឈមមុខ។ គណៈកម្មការសវនកម្មរបស់ធនាគារ ដើរតួនាទីក្នុងការ ជួយត្រួតពិនិត្យសវនកម្មផ្ទៃក្នុងរបស់ខ្លួន។ សវនកម្មផ្ទៃក្នុង អនុវត្តទាំងការត្រួតពិនិត្យជាប្រចាំ និងលក្ខណៈ ពិសេសនៃការគ្រប់គ្រងហានិភ័យ និងនីតិវិធីដែលលទ្ធផល ត្រូវបានរាយការណ៍ជូនទៅគណៈកម្មការសវនកម្ម របស់ធនាគារ។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ក. សេចក្តីផ្តើម និងទិដ្ឋភាពទូទៅ (ត)

ចំណាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ធនាគារមានតម្លៃដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលវាស់វែងតាមរំលស់ថ្លៃដើមដូចខាងក្រោម៖

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
ទ្រព្យសកម្មហិរញ្ញវត្ថុ				
ទ្រព្យសកម្មហិរញ្ញវត្ថុតាម តម្លៃសមស្របតាមរយៈOCIៈ				
ការវិនិយោគក្នុងមូលបត្រកម្មសិទ្ធិ	15,353	61,612	15,353	61,796
ទ្រព្យសកម្មហិរញ្ញវត្ថុ តាមរំលស់ថ្លៃដើមៈ				
សាច់ប្រាក់ក្នុងដៃ	14,471,927	58,075,843	17,960,933	72,292,755
ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា	279,943,012	1,123,411,307	213,529,427	859,455,944
ប្រាក់បញ្ញើនៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនានាសុទ្ធ	53,076,567	212,996,264	36,569,362	147,191,682
ឥណទាន និងបុរេប្រទាន ផ្តល់ដល់អតិថិជន	1,027,657,892	4,123,991,121	1,223,915,775	4,926,260,994
ទ្រព្យសកម្មផ្សេងៗ (*)	2,051,588	8,233,023	2,212,746	8,906,303
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	1,377,216,339	5,526,769,170	1,494,203,596	6,014,169,474
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើរបស់អតិថិជន និង គ្រឹះស្ថានហិរញ្ញវត្ថុនានា	770,782,358	3,093,149,603	738,025,372	2,970,552,122
ប្រាក់កម្ចី	68,753,293	275,906,965	100,491,365	404,477,744
គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ	50,280,972	201,777,541	211,250,275	850,282,357
បំណុលភតិសន្យា	13,819,281	55,456,775	15,401,256	61,990,055
បំណុលផ្សេងៗ (**)	6,406,098	25,707,671	5,637,605	22,691,360
បំណុលហិរញ្ញវត្ថុសរុប	**910,042,002**	**3,651,998,555**	**1,070,805,873**	**4,309,993,638**

(*) ទ្រព្យសកម្មផ្សេងទៀតរួមមានប្រាក់កក់ដែលអាចដកវិញជាសាច់ប្រាក់ និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតដែលមិនរាប់បញ្ចូលការបង់ប្រាក់ជាមុន។

(**) បំណុលផ្សេងទៀតមិនរាប់បញ្ចូលពន្ធដែលត្រូវបង់ ដែលមិនត្រូវបានចាត់ទុកថាជាបំណុលហិរញ្ញវត្ថុទេ។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន

'ហានិភ័យឥណទាន' គឺជាហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ធនាគារ ប្រសិនបើអតិថិជន ឬភាគីម្ខាងទៀត មិនមានលទ្ធភាពបំពេញកាតព្វកិច្ចទៅតាមកិច្ចសន្យា ហើយហានិភ័យជាចម្បងនេះ គឺកើតចេញតាមរយៈការផ្តល់ឥណទាន និងបុរេប្រទានដល់អតិថិជន ធនាគារនានា និងការវិនិយោគលើមូលបត្របំណុល។ សម្រាប់គោលបំណងរាយការណ៍អំពីការគ្រប់គ្រងហានិភ័យ ធនាគារធ្វើការពិចារណា និងដាក់រួមបញ្ចូលនូវធាតុទាំងអស់នៃហានិភ័យឥណទានដែលប្រឈម - ឧទាហរណ៍ ហានិភ័យតាមកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ ហានិភ័យតាមវិស័យ និងវិស័យនានា។

ហានិភ័យឥណទាន គឺជាការខាតបង់ចំណូល និងការខាតបង់ប្រាក់ដើម កើតឡើងពីឥណទាន និងបុរេប្រទាន និងកិច្ចសន្យាកម្ចី ដោយសារអ្នកខ្ចី ឬសមភាគីខកខានមិនទូទាត់សង។

(i). ការគ្រប់គ្រងហានិភ័យឥណទាន

គណៈកម្មាធិការឥណទានរបស់ធនាគារ រួមជាមួយនឹងការិភាគ និងការអនុម័តឥណទាន គោលនយោបាយប្រាក់កម្ចី ការស្តារប្រាក់កម្ចី ការត្រួតពិនិត្យប្រាក់កម្ចី ការអភិវឌ្ឍន៍អាជីវកម្ម ការគ្រប់គ្រងហានិភ័យ និងនាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ ទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារដោយ៖

- ធនាគារមានការអនុវត្តហានិភ័យឥណទានសមស្រប រួមទាំងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ដើម្បីកំណត់ឱ្យបានជាប់លាប់នូវប្រាក់ឧបត្ថម្ភគ្រប់គ្រាន់ស្របតាមគោលនយោបាយ និងនីតិវិធីដែលបានបញ្ជាក់របស់ធនាគារ CIFRS និងការណែនាំអំពីការត្រួតពិនិត្យពាក់ព័ន្ធ។
- ការកំណត់អត្តសញ្ញាណ វាយតម្លៃ និងវាស់វែងហានិភ័យឥណទាននៅទូទាំងធនាគារ ពីឧបករណ៍បុគ្គលរហូតដល់កម្រិតផលប័ត្រ។
- ការបង្កើតគោលនយោបាយឥណទានដើម្បីការពារធនាគារប្រឆាំងនឹងហានិភ័យដែលបានកំណត់ រួមទាំងតម្រូវការដើម្បីទទួលបានវត្ថុបញ្ចាំពីអ្នកខ្ចី ដើម្បីធ្វើការវាយតម្លៃឥណទានដែលកំពុងដំណើរការដ៏រឹងមាំរបស់អ្នកខ្ចី និងដើម្បីតាមដានការប្រឈមមុខនឹងកម្រិតហានិភ័យផ្ទៃក្នុង។
- ការកំណត់ការប្រមូលផ្តុំនៃការប៉ះពាល់ដោយប្រភេទនៃទ្រព្យសកម្ម សមភាគី ឧស្សាហកម្ម ចំណាត់ថ្នាក់ឥណទាន ទីតាំងភូមិសាស្ត្រ។
- ការបង្កើតក្របខណ្ឌការត្រួតពិនិត្យដ៏រឹងមាំមួយទាក់ទងនឹងរចនាសម្ព័ន្ធការអនុញ្ញាតសម្រាប់ការអនុម័ត និងការបន្តឡើងវិញនូវកន្លែងផ្តល់ឥណទាន។
- ការបង្កើតនិងរក្សាចំណាត់ថ្នាក់ហានិភ័យរបស់ធនាគារ ដើម្បីចាត់ថ្នាក់ការប៉ះពាល់ដោយយោងទៅតាមកម្រិតនៃហានិភ័យនៃការខកខាន។ ចំណាត់ថ្នាក់ហានិភ័យគឺស្ថិតនៅក្រោមការត្រួតពិនិត្យជាប្រចាំ។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(i). ការគ្រប់គ្រងហានិភ័យឥណទាន (ត)

- បង្កើត និងថែរក្សាដំណើរការរបស់ធនាគារសម្រាប់ការវាស់វែង ECL រួមទាំងការត្រួតពិនិត្យហានិភ័យឥណទាន ការដាក់បញ្ចូលព័ត៌មានដែលមើលទៅអនាគត និងវិធីសាស្ត្រដែលប្រើដើម្បីវាស់ ECL។
- ធានាថាធនាគារមានគោលនយោបាយ និងនីតិវិធីក្នុងការរក្សាបានត្រឹមត្រូវ និងធ្វើឱ្យមានសុពលភាពគំរូដែលប្រើដើម្បីវាយតម្លៃ និងវាស់វែង ECL។
- ការបង្កើតដំណើរការវាយតម្លៃគណនេយ្យហានិភ័យឥណទាន និងដំណើរការវាស់វែងដែលផ្តល់ឱ្យវានូវមូលដ្ឋានរឹងមាំសម្រាប់ប្រព័ន្ធទូទៅ ឧបករណ៍ និងទិន្នន័យដើម្បីវាយតម្លៃហានិភ័យឥណទាន និងគណនីសម្រាប់ ECL។ ការផ្តល់ដំបូន្មាន ការណែនាំ និងជំនាញឯកទេសដល់អង្គភាពអាជីវកម្ម ដើម្បីលើកកម្ពស់ការអនុវត្តល្អបំផុតនៅទូទាំងធនាគារក្នុងការគ្រប់គ្រងហានិភ័យឥណទាន។

ការបញ្ចូលព័ត៌មានរំពឹងទុកនៅពេលអនាគត

ការរំពឹងទៅលើការរិភាគធនាគារនៅថ្ងៃអនាគត ដោយប្រើប្រាស់គំរូតំរែតំរង់ស្ថិតិសម្រាប់ការវាយតម្លៃដើម្បីកំណត់ថាតើហានិភ័យឥណទាននៃឧបករណ៍មួយបានកើនឡើងយ៉ាងខ្លាំងចំពោះការវាស់វែងរបស់ ECL ដែរឬទេ។

ព័ត៌មានរំពឹងទុកនៅពេលអនាគត ត្រូវបានប្រើប្រាស់សម្រាប់តែការគណនា PD ប៉ុណ្ណោះ។ សម្រាប់ LGD ព័ត៌មានរំពឹងទុកនៅពេលអនាគត មិនត្រូវបានរាប់បញ្ចូលការខកខាតមិនសងបំណុលក្នុងត្រីមាសដំបូង ព្រោះវាមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលអាចទុកចិត្តបានដើម្បីធ្វើការរិភាគស្ថិតិដែលរំពឹងទុកនៅពេលអនាគត។

ធនាគារបង្កើតសេណារីយ៉ូសេដ្ឋកិច្ចចំនួនបី៖ សេណារីយ៉ូជាមូលដ្ឋាន គឺសេណារីយ៉ូមធ្យមតាងដោយ 65% នៃប្រូបាប៊ីលីតេដែលកើតឡើង និងសេណារីយ៉ូពីរទៀតដែលមិនទំនងនឹងកើតឡើងគឺ 25% សម្រាប់សេណារីយ៉ូល្អ និង 10% សម្រាប់សេណារីយ៉ូអាក្រក់។

ធនាគារបានកំណត់ និងកត់ត្រាចំណុចសំខាន់ៗដែលជាចលករនៃហានិភ័យឥណទាន និងការបាត់បង់ឥណទានសម្រាប់នីតិកម្មហិរញ្ញវត្ថុប្រភេទនីមួយៗ ដោយប្រើការរិភាគទិន្នន័យប្រវត្តិសាស្ត្រ។

សេណារីយ៉ូសេដ្ឋកិច្ចនៃផលប័ត្ររបស់ធនាគារ ដែលបានប្រើប្រាស់រួមមានសូចនាករសំខាន់ៗរបស់ប្រទេសកម្ពុជា ចាប់ពីឆ្នាំ2025 ដូចខាងក្រោម៖

សេណារីយ៉ូ	2025	2026	2027	2028	ទៅមុខទៀត
មូលដ្ឋាន	1.20%	1.20%	1.22%	1.25%	1.27%
ល្អ	0.32%	0.32%	0.33%	0.33%	0.34%
អាក្រក់	4.17%	4.19%	4.25%	4.32%	4.41%

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(i). *ការគ្រប់គ្រងហានិភ័យឥណទាន (ត)*

ការបញ្ចូលព័ត៌មានព្រឹងទុកនៅពេលអនាគត (ត)

ទំនាក់ទំនងដែលបានព្យាករណ៍រវាងសូចនាករសំខាន់ៗ ការបាត់បង់ និងអត្រាបាត់បង់លើផលប័ត្រផ្សេងៗនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយផ្អែកលើការវិភាគទិន្នន័យប្រវត្តិសាស្ត្ររយៈពេល 7ឆ្នាំ មកធ្វើការវិភាគ។

ការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន

ធនាគារតាមដានរាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលស្ថិតក្រោមលក្ខខណ្ឌតម្រូវនៃការចុះខ្សោយ ដើម្បីវាយតម្លៃថាតើមានការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង។ ប្រសិនបើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន ធនាគារនឹងវាស់វែងប្រាក់ឧបត្ថម្ភការខាតបង់ដោយផ្អែកលើអាយុកាលជាជាង ECL រយៈពេល 12ខែ។

ធនាគារប្រើចំនួនថ្ងៃដែលហួសកំណត់ជាធាតុចូលចម្បងក្នុងការកំណត់រចនាសម្ព័ន្ធពាក្យរបស់ PD សម្រាប់ការបង្ហាញ។ ធនាគារប្រមូលព័ត៌មានអំពីការអនុវត្ត និងលំនាំដើមអំពីការប្រឈមមុខនឹងហានិភ័យឥណទានដែលត្រូវបានវិភាគដោយវិស័យអាជីវកម្មរបស់អ្នកខ្ចីរបស់ខ្លួន។

ធនាគារធ្វើការកំណត់ការកើនឡើងនៃហានិភ័យឥណទានជាសារវន្ត ជាការកើតឡើងមិនយឺតជាងពេលដែលទ្រព្យសកម្មលើសពី ឬស្មើនឹង 30 ថ្ងៃហួសកាលកំណត់សងសម្រាប់ហ្វាស៊ីលីធីរយៈពេលវែង ឬក៏ស្មើ ឬលើសពី 15ថ្ងៃ ហួសកាលកំណត់សងសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី។ ថ្ងៃដែលផុតកំណត់សង ត្រូវបានកំណត់តាមរយៈការរាប់ចំនួនថ្ងៃចាប់តាំងពីកាលបរិច្ឆេទមិនបានសងមុនគេបង្អស់ ពេលចំនួនទឹកប្រាក់មិនត្រូវបានទទួលគ្រប់ចំនួនតាមកិច្ចសន្យា។ ថ្ងៃផុតកំណត់សងត្រូវបានកំណត់ដោយមិនគិតពីរយៈពេលអនុគ្រោះណាមួយសម្រាប់អ្នកខ្ចីឡើយ។

ធនាគារមាននិតិវិធីត្រួតពិនិត្យ ដើម្បីប្រាកដថាលក្ខណៈវិនិច្ឆ័យដែលប្រើដើម្បីកំណត់ការកើនឡើងជាសារវន្តនៃឥណទានមានប្រសិទ្ធភាព មានន័យថា ការកើនឡើងជាសារវន្តនៃហានិភ័យឥណទានត្រូវបានកំណត់មុនពេលការប៉ះពាល់ត្រូវបានលុបចោល ឬនៅពេលដែលទ្រព្យសកម្មលើសពី 30 ថ្ងៃហួសកាលកំណត់សម្រាប់ហ្វាស៊ីលីធីរយៈពេលវែង ឬច្រើនជាង ឬស្មើ 15 ថ្ងៃហួសកាលកំណត់សងសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី។

ធនាគារមានការគ្រប់គ្រង និងនីតិវិធីក្នុងការកំណត់អត្តសញ្ញាណនៅពេលដែលហានិភ័យឥណទាននៃទ្រព្យសកម្មមានភាពប្រសើរឡើង ហើយនិយមន័យនៃការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទានមិនត្រូវបានបំពេញទៀតទេ។ នៅពេលនេះជាករណី ទ្រព្យសកម្មអាចត្រូវបានផ្លាស់ទីត្រឡប់ទៅដំណាក់កាលទី1 វិញពីដំណាក់កាលទី2 ដោយតម្រូវឱ្យការទូទាត់សងទាន់ពេលវេលា និងលទ្ធភាពរបស់អ្នកខ្ចីក្នុងការទូទាត់នាពេលអនាគតទាន់ពេល។

ធនាគារ អ៊ីរី (ខេមបូឌា) ម.ក

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(i). ការគ្រប់គ្រងហានិភ័យឥណទាន (ត)

ការវាស់វែង ECL

សមាសធាតុសំខាន់ៗដែលប្រើសម្រាប់វាស់វែង ECL គឺ៖

- លទ្ធភាពនៃការខកខានសង ("PD");
- ការបាត់បង់ដែលបណ្តាលមកពីការខកខានសង ("LGD"); និង
- ទំហំនៃការខកខានសង ("EAD")។

តួលេខទាំងនេះជាទូទៅបានមកពីគំរូស្ថិតិដែលបានអភិវឌ្ឍខាងក្នុង និងទិន្នន័យប្រវត្តិសាស្ត្រផ្សេងទៀត។

ការសន្មតគណនា ECL ត្រូវបានតាមដាន និងត្រួតពិនិត្យជាប្រចាំខែ។

PD គឺជាការប៉ាន់ប្រមាណអំពីលទ្ធភាពដែលអតិថិជននឹងមិនអាចបំពេញកាតព្វកិច្ចបំណុលរបស់ខ្លួនឬខកខានសងតាមពេលវេលាជាក់លាក់ណាមួយ។ ទ្រព្យសកម្មហិរញ្ញវត្ថុក្នុងវិធីសាស្ត្រទូទៅតម្រូវឱ្យមានដំណាក់កាលសម្រាប់ទាំង 12-ខែ PD និងការប៉ាន់ប្រមាណ PD ពេញមួយជីវិត យោងទៅតាមទិន្នន័យប្រវត្តិសាស្ត្រដោយប្រើវិធីសាស្ត្រ migration។

LGD គឺជាការប៉ាន់ប្រមាណនៃការបាត់បង់ដែលកើតឡើងតាមរយៈការខកខានមិនបានសងបំណុល។ LGD ត្រូវគិតជាភាគរយនៃការប៉ះពាល់ដែលធនាគារអាចបាត់បង់ក្នុងករណីដែល អតិថិជនខកខានមិនបានសងបំណុល។ ការខាតបង់ទាំងនេះជាធម្មតាត្រូវបានបង្ហាញជាភាគរយនៃ EAD ហើយអាស្រ័យទៅលើប្រភេទ និងចំនួនវត្ថុបញ្ចាំ ក៏ដូចជាប្រភេទនៃអតិថិជន និងការសងត្រលប់ដែលរំពឹងទុកពីអតិថិជន។ ជាមួយនឹងប្រភេទវត្ថុបញ្ចាំត្រឹមត្រូវ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពពីមួយពេលទៅមួយពេល ធនាគារអាចពិចារណាដើម្បីយកវត្ថុបញ្ចាំទៅក្នុងការគណនា LGD សម្រាប់ការគណនា ECL ។ ក្នុងករណីមានវត្ថុបញ្ចាំមានតម្លៃលើសអត្រា LGD ទាបជាងគេនឹងត្រូវយកអនុវត្តសម្រាប់ការគណនា ECL។ ការគណនាគឺនៅលើមូលដ្ឋានលំហូរសាច់ប្រាក់អប្បហារដែលលំហូរសាច់ប្រាក់ត្រូវបានអប្បហារដោយ EIR ដើមនៃប្រាក់កម្ចី។

EAD គឺជាការប៉ាន់ប្រមាណនៃការប៉ះពាល់នៅកាលបរិច្ឆេទលំនាំដើមនាពេលអនាគត ដោយគិតគូរពីការផ្លាស់ប្តូរដែលរំពឹងទុកនៅក្នុងការប៉ះពាល់បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ រួមទាំងការសងប្រាក់ដើម និងការប្រាក់ និង ការដកប្រាក់ដែលរំពឹងទុកលើមធ្យោបាយដែលបានសន្យា។ វិធីសាស្ត្រគំរូរបស់ធនាគារសម្រាប់ EAD ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលរំពឹងទុក នៅក្នុងសមតុល្យដែលនៅសល់ក្នុងរយៈពេលពេញមួយជីវិតនៃការប៉ះពាល់ប្រាក់កម្ចីដែលត្រូវបានអនុញ្ញាតដោយលក្ខខណ្ឌនៃកិច្ចសន្យាបច្ចុប្បន្ន ដូចជាទម្រង់រំលោះការសងប្រាក់មុន ឬការទូទាត់លើសការផ្លាស់ប្តូរការប្រើប្រាស់ការសន្យាដែលមិនបានដកចេញ និងសកម្មភាពកាត់បន្ថយឥណទានមុនពេលបាត់បង់។ ធនាគារប្រើគំរូ EAD ដែលឆ្លុះបញ្ចាំងពីលក្ខណៈនៃផលប័ត្រ។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(i). ការគ្រប់គ្រងហានិភ័យឥណទាន (ត)

ការវាស់វែង ECL (ត)

ធនាគារវាស់វែង ECL ដោយពិចារណាលើហានិភ័យនៃការខកខានក្នុងរយៈពេលកិច្ចសន្យាអតិបរមាដែលអង្គភាពត្រូវបានប៉ះពាល់នឹងហានិភ័យឥណទាន និងមិនមែនជារយៈពេលវែងជាងនេះ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដូចជា បរិក្ខារឥណទានបង្វិល ដែលរួមមានទាំងប្រាក់កម្ចី និងសមាសភាគការប្តេជ្ញាចិត្តដែលមិនទាន់បានទាញ សមត្ថភាពក្នុងកិច្ចសន្យារបស់ធនាគារក្នុងការទាមទារការទូទាត់សង និងលុបចោលការសន្យាដែលមិនបានដកចេញ មិនកំណត់ការប្រឈមមុខនឹងការបាត់បង់ឥណទានរបស់ធនាគារចំពោះរយៈពេលជូនដំណឹងតាមកិច្ចសន្យានោះទេ។ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុបែបនេះ ធនាគារវាស់វែង ECL ក្នុងរយៈពេលដែលវាប្រឈមនឹងហានិភ័យឥណទាន ហើយ ECL នឹងមិនត្រូវបានកាត់បន្ថយដោយសកម្មភាពគ្រប់គ្រងហានិភ័យឥណទាន បើទោះបីជារយៈពេលនោះលាតសន្ធឹងលើសពីរយៈពេលកិច្ចសន្យាអតិបរមាក៏ដោយ។ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះមិនមានរយៈពេលកំណត់ ឬរចនាសម្ព័ន្ធនៃការសងវិញទេ ហើយមានរយៈពេលខ្លី នៃការលុបចោលកិច្ចសន្យា។ ទោះយ៉ាងណាក៏ដោយ ធនាគារមិនអនុវត្តក្នុងការគ្រប់គ្រងប្រចាំថ្ងៃធម្មតានៃសិទ្ធិកិច្ចសន្យាក្នុងការលុបចោលឧបករណ៍ហិរញ្ញវត្ថុទាំងនេះទេ។ នេះគឺដោយសារតែឧបករណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានគ្រប់គ្រងលើមូលដ្ឋានសមូហភាព ហើយត្រូវបានលុបចោលលុះត្រាតែធនាគារបានដឹងអំពីការកើនឡើងនៃហានិភ័យឥណទាននៅកម្រិតមូលដ្ឋាន។ រយៈពេលវែងជាងនេះត្រូវបានប៉ាន់ប្រមាណដោយគិតគូពីសកម្មភាពគ្រប់គ្រងហានិភ័យឥណទានដែលធនាគាររំពឹងថានឹងចាត់វិធានការដើម្បីកាត់បន្ថយ ECL ឧទាហរណ៍ ការកាត់បន្ថយដែនកំណត់ ឬលុបចោលការសន្យាឥណទាន។

ការគណនា ECL សម្រាប់គោលបំណងគណនេយ្យគឺខុសពីការគណនា ECL សម្រាប់គោលបំណងនិយតកម្ម ទោះបីជាធាតុបញ្ចូលជាច្រើនដែលប្រើគឺស្រដៀងគ្នាក៏ដោយ។ ធនាគារបានធានាថាវិធីសាស្ត្រសមស្របត្រូវបានប្រើប្រាស់នៅពេលគណនា ECL សម្រាប់គោលបំណងគណនេយ្យ និងបទប្បញ្ញត្តិ។ ភាពខុសគ្នាសំខាន់រវាងវិធីសាស្ត្រដែលប្រើដើម្បីវាស់ ECL ស្របតាម CIFRS 9 ធៀបនឹងវិធីដែលត្រូវបានអនុវត្តសម្រាប់គោលបំណងបទប្បញ្ញត្តិគឺ៖

- ភាគរយនៃការផ្តល់ដោយការចាត់ថ្នាក់ដោយផ្អែកលើប្រាក់កម្ចីរយៈពេលខ្លី/វែង
- ចំនួនថ្ងៃដែលហួសកំណត់
- ការសម្លឹងទៅមុខនៃកត្តាម៉ាក្រូសេដ្ឋកិច្ច
- ប្រូបាប៊ីលីតេនៃការបាត់បង់ និងអត្រាប្រមូលបានមកវិញពីគ្រាមុនៗ

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(i). ការគ្រប់គ្រងហានិភ័យឥណទាន (ត)

ការវាស់វែង ECL (ត)

ការវាស់វែងនៃ ECL គឺផ្អែកលើប្រូបាប៊ីលីតេទម្ងន់នៃការបាត់បង់ឥណទានជាមធ្យម។ ជាលទ្ធផល ការវាស់វែងនៃប្រាក់ឧបត្ថម្ភការខាតបង់គួរតែដូចគ្នា ដោយមិនគិតពីថាតើវាត្រូវបានវាស់វែងលើមូលដ្ឋានបុគ្គល ឬមូលដ្ឋានសមូហភាព (ទោះបីជាការវាស់វែងលើមូលដ្ឋានសមូហភាព គឺជាក់ស្តែងជាងសម្រាប់ផលប័ត្រធំនៃវត្ថុ)។ ទាក់ទងទៅនឹងការវាយតម្លៃថាតើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន វាអាចចាំបាច់ក្នុងការអនុវត្តការវាយតម្លៃលើមូលដ្ឋានសមូហភាព។

សំវិធានធនបន្ថែមពីគណៈគ្រប់គ្រង

ធនាគារបន្ថែមសំវិធានធនលើ ECL សម្រាប់ឥណទានរៀបចំឡើងវិញ និងវិស័យដែលងាយរងគ្រោះ ឬអតិថិជនដែលសន្មតថាមានហានិភ័យខ្ពស់ក្នុងការសងបង្វែរត្រលប់មកវិញ និងអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងសារាចរណែនាំស្តីពីការចាត់ថ្នាក់ និងបទប្បញ្ញត្តិការលើឥណទានរៀបចំឡើងវិញដែលចេញដោយ NBC ចុះថ្ងៃទី28 ខែធ្នូ ឆ្នាំ2021 ដូច្នេះ ការបន្ថែមលើ ECL កំពុងត្រូវបានវាយតម្លៃដោយការចាត់ថ្នាក់ឥណទានដែលបានរៀបចំឡើងវិញទាំងនេះ និងអតិថិជនដែលងាយរងគ្រោះទៅជាដំណាក់កាលហានិភ័យខ្ពស់ជាងហានិភ័យដើម។ ជាងនេះទៅទៀត ធនាគារបានកំណត់ការបន្ថែមលើ ECL លើការចុះខ្សោយនៃ ផលប័ត្រ ដោយសារការកើនឡើងសាវន្តនៃហានិភ័យឥណទាន និងអត្រាលំហូរខ្ពស់នៃផលប័ត្រប្រាក់កម្ចី ដោយគិតពីស្ថានភាពបច្ចុប្បន្ន និងការព្យាករណ៍។

ការដាក់ជាក្រុមដោយផ្អែកលើលក្ខណៈហានិភ័យរួមគ្នា

ធនាគារបានកំណត់ផ្នែកសំខាន់ៗចំនួនប្រាំពីរសម្រាប់ការគណនា PD ដែលមានអាកប្បកិរិយាហានិភ័យស្រដៀងគ្នាដោយផ្អែកលើការវិភាគនៃអត្រាវិលជុំ ដូចបានបង្ហាញក្នុងតារាងខាងក្រោម។ ផ្នែកទាំងនេះគឺ៖

- កសិកម្ម
- គ្រួសារ
- ការផលិត
- សេវាកម្ម
- ជំនួញ និងពាណិជ្ជកម្ម
- ការដឹកជញ្ជូន
- ផ្សេងៗ

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(i). ការគ្រប់គ្រងហានិភ័យឥណទាន (ត)

ការដាក់ជាក្រុមដោយផ្អែកលើលក្ខណៈហានិភ័យរួមគ្នា (ត)

ការដាក់ជាក្រុមត្រូវបានត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថាក្រុមនីមួយៗមានការបង្ហាញភាពដូចគ្នា។

ការវាយតម្លៃហានិភ័យឥណទានត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើមូលដ្ឋានប្រចាំឆ្នាំ ហើយនៅក្នុងព្រឹត្តិការណ៍នៃ (i) ការផ្លាស់ប្តូរលក្ខខណ្ឌកម្ចី រួមទាំងការពន្យារពេល (ii) ភាពមិនប្រក្រតីនៃការទូទាត់សង ឬភាពយឺតយ៉ាវ និង (iii) ព័ត៌មានមិនល្អទាក់ទងនឹងអ្នកខ្ចី ឬប្រតិបត្តិការ។

ធនាគារប្រើគោលនយោបាយ និងការអនុវត្តជាច្រើន ដើម្បីគ្រប់គ្រងហានិភ័យឥណទាន។ ទំនៀមទំលាប់បំផុតនៃការទាំងនេះ គឺការយកទ្រព្យធានាជាវត្ថុបញ្ចាំសម្រាប់ប្រាក់កម្ចីដល់អតិថិជន ដែលជាការអនុវត្តទូទៅ។ ធនាគារអនុវត្តគោលការណ៍ណែនាំស្តីពីភាពអាចទទួលយកបាននៃប្រភេទជាក់លាក់នៃវត្ថុបញ្ចាំ ឬការកាត់បន្ថយហានិភ័យឥណទាន។ ប្រភេទវត្ថុបញ្ចាំសំខាន់ៗដែលធានាសម្រាប់ប្រាក់កម្ចីដល់អតិថិជនរួមមាន ដី ផ្ទះអគារ និងអចលនវត្ថុផ្សេងៗទៀត។ គោលនយោបាយរបស់ធនាគារគឺផ្តល់មូលនិធិរហូតដល់ 75% នៃតម្លៃវត្ថុបញ្ចាំ។ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ឥណទាន និងបុរេប្រទាន ផ្តល់ដល់អតិថិជន ដែលដាក់ទ្រព្យបញ្ចាំមានចំនួនប្រមាណ 99.20% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024: 99.03%)។ មិនមានការផ្លាស់ប្តូរនៅក្នុងគោលនយោបាយវត្ថុបញ្ចាំរបស់ធនាគារក្នុងអំឡុងឆ្នាំនោះទេ។

(ii). ការប្រមូលផ្តុំហានិភ័យ

ធនាគារប្រតិបត្តិ និងផ្តល់ប្រាក់កម្ចី និងបុរេប្រទានដល់បុគ្គល ឬសហគ្រាសក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារគ្រប់គ្រងដែនកំណត់ និងគ្រប់គ្រងការប្រមូលផ្តុំហានិភ័យឥណទាននៅពេលណាដែលពួកគេត្រូវបានកំណត់អត្តសញ្ញាណ។

តារាងខាងក្រោម បង្ហាញពីហានិភ័យអតិបរមារបស់ធនាគារចំពោះហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុនៅលើតារាងតុល្យការ និងក្រៅសមតុល្យ ដោយមិនគិតពីវត្ថុបញ្ចាំណាមួយដែលកាន់កាប់ ឬបង្កើនឥណទានផ្សេងទៀត។ សម្រាប់ទ្រព្យសកម្មនៅលើតារាងតុល្យការ ការប្រឈមនឹងហានិភ័យឥណទានស្មើនឹងចំនួនសរុបរបស់ពួកគេ។ សម្រាប់បំណុលដែលជាប់ពាក់ព័ន្ធ ការប្រឈមមុខនឹងហានិភ័យឥណទានជាអតិបរមាដែលធនាគារនឹងត្រូវបង់ ប្រសិនបើកាតព្វកិច្ចនៃឧបករណ៍ដែលបានចេញត្រូវបានទាមទារ។ សម្រាប់ការប្តេជ្ញាចិត្តលើឥណទាន ការប៉ះពាល់អតិបរមាចំពោះហានិភ័យឥណទានគឺជាចំនួនពេញលេញនៃកន្លែងឥណទានដែលមិនបានទាញយកដែលបានផ្តល់ដល់អតិថិជន។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(ii). ការប្រមូលផ្តុំហានិភ័យ (ត)

ការប្រឈមនឹងប្រភេទហានិភ័យឥណទាន

ការវិភាគតាមប្រភេទនៃការប្រឈមនឹងហានិភ័យឥណទានតាមមូលដ្ឋានដុលមានដូចខាងក្រោម៖

	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា ដុល្លារអាមេរិក	ការប្រឈមនឹងហានិភ័យឥណទានអតិបរមា ពាន់រៀល (កំណត់សម្គាល់ 3)	ការដាក់ទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន %	ផ្នែកខ្លះនៃទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន %	មិនមានការធានា និងគ្មានទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន %
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025					
ធាតុក្នុងតារាងតុល្យការ					
ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា	279,943,012	1,123,411,307	0.00%	0.05%	99.95%
ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	53,076,567	212,996,264	0.00%	28.26%	71.74%
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	1,027,657,892	4,123,991,121	0.00%	99.20%	0.80%
ទ្រព្យសកម្មផ្សេងៗ	2,051,588	8,233,023	0.00%	49.20%	50.80%
	1,362,729,059	5,468,631,715			
ធាតុក្រៅតារាងតុល្យការ					
សមតុល្យរបស់ឥណទានវិបារូបន៍មិនទាន់បានប្រើប្រាស់	301,590	1,210,281	0.00%	15.55%	84.45%
ការអនុវត្ត និងការធានារបស់ធនាគារ	1,490,145	5,979,952	100%	0.00%	0.00%
	1,791,735	7,190,233			

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(ii). ការប្រមូលផ្តុំហានិភ័យ (ត)

ការប្រឈមនឹងប្រភេទហានិភ័យឥណទាន (ត)

ការវិភាគតាមប្រភេទនៃការប្រឈមនឹងហានិភ័យឥណទានតាមមូលដ្ឋានដុលមានដូចខាងក្រោម៖ (ត)

	ការប្រឈម នឹងហានិភ័យ ឥណទានអតិបរមា ដុល្លារអាមេរិក	ការប្រឈម នឹងហានិភ័យ ឥណទានអតិបរមា ពាន់រៀល (កំណត់សម្គាល់ 3)	ការដាក់ទ្រព្យបញ្ចាំ/ ការពង្រឹងឥណទាន %	ផ្នែកខ្លះនៃទ្រព្យបញ្ចាំ/ ការពង្រឹងឥណទាន %	មិនមានការធានា និងគ្មានទ្រព្យបញ្ចាំ/ ការពង្រឹងឥណទាន %
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024					
ធាតុក្នុងតារាងតុល្យការ					
ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា	213,529,427	859,455,944	0.00%	0.09%	99.91%
ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	36,569,362	147,191,682	0.00%	60.16%	39.84%
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	1,223,915,775	4,926,260,994	0.00%	99.03%	0.97%
ទ្រព្យសកម្មផ្សេងៗ	2,212,746	8,906,303	0.00%	38.91%	61.09%
	1,476,227,310	5,941,814,923			
ធាតុក្រៅតារាងតុល្យការ					
សមតុល្យរបស់ឥណទានវិបារូបន៍មិនទាន់បានប្រើប្រាស់	229,731	924,667	0.00%	21.76%	78.24%
ការអនុវត្ត និងការធានារបស់ធនាគារ	999,550	4,023,189	100.00%	0.00%	0.00%
	1,229,281	4,947,856			

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(ii). ការប្រមូលផ្តុំហានិភ័យ (ត)

ការប្រមូលផ្តុំហានិភ័យវិភាគតាមវិស័យអាជីវកម្ម

ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	សាច់ប្រាក់សមមូលនៅធនាគារនានា និងគ្រឹះស្ថានហិរញ្ញវត្ថុ ដុល្លារអាមេរិក	ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន ដុល្លារអាមេរិក	ទ្រព្យសកម្មផ្សេងៗ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
គ្រឹះស្ថានហិរញ្ញវត្ថុ	53,076,567	-	-	53,076,567
កសិកម្ម	-	202,998,201	-	202,998,201
ជំនួញ និងពាណិជ្ជកម្ម	-	193,306,297	-	193,306,297
ការផលិត	-	8,720,794	-	8,720,794
សេវាកម្ម	-	147,283,059	-	147,283,059
គ្រួសារ	-	443,655,668	-	443,655,668
ការដឹកជញ្ជូន	-	31,524,710	-	31,524,710
ផ្សេងៗ	-	169,163	2,051,588	2,220,751
សរុប (ដុល្លារអាមេរិក)	53,076,567	1,027,657,892	2,051,588	1,082,786,047
សរុប (ពាន់រៀល – កំណត់សម្គាល់ 3)	212,996,264	4,123,991,121	8,233,023	4,345,220,407

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(ii). ការប្រមូលផ្តុំហានិភ័យ (ត)

ការប្រមូលផ្តុំហានិភ័យវិភាគតាមវិស័យអាជីវកម្ម (ត)

ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	សាច់ប្រាក់សមមូលនៅធនាគារនានា និងគ្រឹះស្ថានហិរញ្ញវត្ថុ ដុល្លារអាមេរិក	ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន ដុល្លារអាមេរិក	ទ្រព្យសកម្មផ្សេងៗ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
គ្រឹះស្ថានហិរញ្ញវត្ថុ	36,569,362	-	-	36,569,362
កសិកម្ម	-	254,790,536	-	254,790,536
ជំនួញ និងពាណិជ្ជកម្ម	-	224,518,293	-	224,518,293
ការផលិត	-	9,501,849	-	9,501,849
សេវាកម្ម	-	168,682,594	-	168,682,594
គ្រួសារ	-	528,127,395	-	528,127,395
ការដឹកជញ្ជូន	-	38,157,347	-	38,157,347
ផ្សេងៗ	-	137,761	2,212,746	2,350,507
សរុប (ដុល្លារអាមេរិក)	36,569,362	1,223,915,775	2,212,746	1,262,697,883
សរុប (ពាន់រៀល – កំណត់សម្គាល់ 3)	147,191,682	4,926,260,994	8,906,303	5,082,358,979

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(ii). ការប្រមូលផ្តុំហានិភ័យ (ត)

ការប្រមូលផ្តុំហានិភ័យវិភាគតាមនិវាសនដ្ឋាន ទំនាក់ទំនង ការប្រឈមទៅនឹងហានិភ័យធំៗ និងសម្បទាន សម្រាប់ឥណទាន និងបុរេប្រទាន៖

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
តាមនិវាសនដ្ឋាន៖				
និវាសជន	1,027,657,892	4,123,991,121	1,223,915,775	4,926,260,994
អនិវាសជន	-	-	-	-
	1,027,657,892	4,123,991,121	1,223,915,775	4,926,260,994
តាមទំនាក់ទំនង៖				
អតិថិជនខាងក្រៅ	1,024,221,250	4,110,199,877	1,218,915,277	4,906,133,990
ឥណទានបុគ្គលិក	3,436,642	13,791,244	5,000,498	20,127,004
	1,027,657,892	4,123,991,121	1,223,915,775	4,926,260,994
តាមហានិភ័យ៖				
ហានិភ័យធំៗ (*)	-	-	-	-
មិនមែនជាហានិភ័យធំៗ	1,027,657,892	4,123,991,121	1,223,915,775	4,926,260,994
	1,027,657,892	4,123,991,121	1,223,915,775	4,926,260,994
តាមការធ្វើសម្បទាន៖				
ការរៀបចំឡើងវិញ (**)	281,044,998	1,127,833,577	183,080,051	736,897,205
មិនបានរៀបចំឡើងវិញ	746,612,894	2,996,157,544	1,040,835,724	4,189,363,789
	1,027,657,892	4,123,991,121	1,223,915,775	4,926,260,994

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(ii). ការប្រមូលផ្តុំហានិភ័យ (ត)

ការប្រមូលផ្តុំហានិភ័យវិភាគតាមនិវាសនដ្ឋាន ទំនាក់ទំនង ការប្រឈមទៅនឹងហានិភ័យធំៗ និងសម្បទាន សម្រាប់ឥណទាន និងបុរេប្រទានៈ (ត)

(*) "ហានិភ័យធំៗ" ត្រូវបានកំណត់ដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ថាជាហានិភ័យដុលនៃសមតុល្យសរុបនៃឥណទាន និងបុរេប្រទានជាមួយអត្ថគាហកតែមួយដែលមានចំនួនលើសពី 10% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ ផលប៉ះពាល់នេះ គឺជាទំហំណាមួយដែលខ្ពស់ជាងរវាងឥណទាន ឬកិច្ចសន្យាដែលនៅសល់ និងឥណទាន ឬកិច្ចសន្យាដែលបានអនុម័ត។

(**) "ឥណទានដែលបានរៀបចំឡើងវិញ" គឺជាឥណទានដែលមានលក្ខខណ្ឌនៃកិច្ចសន្យាដើមត្រូវបានកែប្រែដើម្បីផ្តល់សម្បទានដល់អ្នកខ្ចី ដែលមានផលលំបាកផ្នែកហិរញ្ញវត្ថុជាបណ្តោះអាសន្ន។

(iii). ទ្រព្យបញ្ចាំ

ខណៈពេលដែលការប្រឈមនឹងហានិភ័យឥណទានអតិបរមារបស់ធនាគារ គឺជាតម្លៃយោងរបស់ទ្រព្យសកម្ម ឬក្នុងករណីឧបករណ៍ហិរញ្ញវត្ថុនៅក្រៅរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺចំនួនទឹកប្រាក់ដែលបានធានា ការសន្យាផ្តល់ឱ្យ ការទទួលយក ឬការយល់ព្រម ហានិភ័យទាំងនោះ ទំនងអាចទាបជាងដោយសារតែការកាត់កងទ្រព្យបញ្ចាំ ការធានាឥណទាន និងសកម្មភាពផ្សេងទៀតដើម្បីកាត់បន្ថយហានិភ័យរបស់ធនាគារ។

ការពិពណ៌នាអំពីទ្រព្យបញ្ចាំសម្រាប់ប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុនីមួយៗ ត្រូវបានបង្ហាញដូចខាងក្រោម។

សាច់ប្រាក់ និងសាច់ប្រាក់សមមូល ប្រាក់តម្កល់តាមបទប្បញ្ញត្តិ ប្រាក់បញ្ញើជាមួយធនាគារជាតិនៃកម្ពុជា និងធនាគារនានា និងទ្រព្យសកម្មផ្សេងៗ

ទ្រព្យបញ្ចាំជាទូទៅមិនត្រូវបានតម្រូវ សម្រាប់ទ្រព្យសកម្មទាំងនេះទេ។

ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន បំណុលយថាភាព និងការសន្យា

ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន បំណុលយថាភាព លិខិតធានា ការសន្យា និងកិច្ចសន្យា ជាធម្មតាត្រូវមានដាក់ជាទ្រព្យបញ្ចាំក្នុងកម្រិតណាមួយ។ ជាពិសេសហានិភ័យលើឥណទានគេហដ្ឋាន ជាទូទៅត្រូវបានធានាទាំងស្រុងដោយអចលនទ្រព្យ។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(ii). ទ្រព្យបញ្ចាំ (ត)

តារាងខាងក្រោមនេះសង្ខេបអំពីការធានាលើទ្រព្យសកម្មហិរញ្ញវត្ថុរបស់ធនាគារ៖

	ទ្រព្យបញ្ចាំ/ការពង្រឹងឥណទាន				
	ទ្រព្យ ដុល្លារអាមេរិក	ប្រាក់បញ្ញើមានកាលកំណត់ ដុល្លារអាមេរិក	ឥណទានពុំមានការធានា ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក	សរុប រៀល (កំណត់សម្គាល់ 3)
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025					
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	1,018,992,180	419,480	8,246,232	1,027,657,892	4,123,991,121
កិច្ចសន្យា និងការធានា	-	1,537,029	254,706	1,791,735	7,190,233
	1,018,992,180	1,956,509	8,500,938	1,029,449,627	4,131,181,354
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024					
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	1,211,460,961	628,079	11,826,735	1,223,915,775	4,926,260,994
កិច្ចសន្យា និងការធានា	50,000	1,053,583	125,698	1,229,281	4,947,856
	1,211,510,961	1,681,662	11,952,433	1,225,145,056	4,931,208,850

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(v). គុណភាពឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល

ដោយអនុលោមតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7.017.344 ចំណាត់ថ្នាក់ឥណទាននីមួយៗ យោងទៅតាមគុណភាពឥណទានមានដូចខាងក្រោម៖

ឥណទានធម្មតា

ឥណទានដែលនៅសល់ ត្រូវបានទូទាត់សងទាន់ពេលវេលា និងមិនជាប់សង្ស័យសម្រាប់ការទូទាត់សងនាពេលអនាគត។ ការទូទាត់សង ត្រូវបានធ្វើឡើងតាមកិច្ចសន្យា ហើយអតិថិជនមិនបង្ហាញពីភាពទន់ខ្សោយនៃលទ្ធភាពក្នុងការទូទាត់សង អាជីវកម្ម លំហូរសាច់ប្រាក់ និងស្ថានភាពហិរញ្ញវត្ថុរបស់សមភាគីនោះឡើយ។

ឥណទានឃ្លាំមើល

ឥណទានដែលនៅក្នុងចំណាត់ថ្នាក់នេះ ត្រូវបានការពារនាពេលបច្ចុប្បន្ន ហើយប្រហែលជាមិនអាចហួសកាលកំណត់ទេ ប៉ុន្តែវាបង្ហាញពីភាពទន់ខ្សោយដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការទូទាត់សងរបស់កូនបំណុលនៅកាលបរិច្ឆេទនាពេលអនាគត ប្រសិនបើមិនបានកែតម្រូវឱ្យបានទាន់ពេលវេលា និងយកចិត្តទុកដាក់ពីគ្រឹះស្ថាន។

ភាពទន់ខ្សោយនេះរាប់បញ្ចូល ប៉ុន្តែមិនត្រូវបានកំណត់ចំពោះនិន្នាការថយចុះនៃប្រតិបត្តិការអាជីវកម្មរបស់ដៃគូរភាគី ឬស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន និងស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌទីផ្សារដែល អាចប៉ះពាល់ដល់ប្រាក់ចំណេញ និងលទ្ធភាពទូទាត់សងនាពេលអនាគតរបស់ខ្លួន ឬស្ថានភាពកាន់តែយ៉ាប់ឃឺននៃទ្រព្យបញ្ចាំ។ ចំណាត់ថ្នាក់នេះមានសនិទានភាពផ្ទាល់ខ្លួនយ៉ាងច្បាស់លាស់ ហើយមិនគួរប្រើជាការសម្របសម្រួលរវាងឥណទានធម្មតា និងឥណទានក្រោមស្តង់ដាទេ។

ឥណទានក្រោមស្តង់ដា

ឥណទានដែលបានចាត់ថ្នាក់នៅក្នុងចំណាត់ថ្នាក់នេះ បង្ហាញពីភាពទន់ខ្សោយគួរឱ្យកត់សម្គាល់ ហើយមិនត្រូវបានការពារគ្រប់គ្រាន់ដោយអាជីវកម្មបច្ចុប្បន្ន ឬស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពសងរបស់កូនបំណុលទេ។ និយាយឱ្យចំទៅ ប្រភពដើមនៃការសងបំណុល គឺមិនគ្រប់គ្រាន់ដើម្បីទូទាត់បំណុលនោះទេ ដោយមិនគិតពីប្រាក់ចំណូលដែលបានមកពីប្រភពបន្ទាប់បន្សំដូចជាលក់ទ្រព្យបញ្ចាំជាដើម។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(v). គុណភាពនៃឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល (ត)

ឥណទានក្រោមស្តង់ដា (ត)

កត្តាដែលនាំឱ្យមានចំណាត់ថ្នាក់ឥណទានក្រោមស្តង់ដារួមមាន៖

- សមភាគីគ្មានលទ្ធភាពដើម្បីបំពេញតាមលក្ខខណ្ឌនៃការទូទាត់សងប្រាក់តាមកិច្ចសន្យា
- ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារមិនអំណោយផល ដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់អាជីវកម្ម និងប្រាក់ចំណេញរបស់ដៃគូរភាគីនាពេលអនាគត
- ស្ថានភាពហិរញ្ញវត្ថុទន់ខ្សោយ និង/ឬ អសមត្ថភាពរបស់ដៃគូភាគីដើម្បីបង្កើតលំហូរសាច់ប្រាក់គ្រប់គ្រាន់ដើម្បីបំពេញការទូទាត់សង
- ភាពលំបាកដែលបានជួបប្រទះដោយដៃគូភាគី ក្នុងការទូទាត់សងឥណទានផ្សេងទៀត ដែលផ្តល់ដោយគ្រឹះស្ថាន ឬដោយស្ថាប័នផ្សេងៗទៀត នៅពេលមានព័ត៌មានអាចប្រើប្រាស់បាន និង
- ការបំពានលើកិច្ចព្រមព្រៀងហិរញ្ញវត្ថុដោយដៃគូភាគី។

ឥណទានជាប់សង្ស័យ

ឥណទានដែលបានចាត់ថ្នាក់នៅក្នុងប្រភេទនេះ បង្ហាញពីភាពទន់ខ្សោយធ្ងន់ធ្ងរជាងចំណាត់ថ្នាក់ឥណទានក្រោមស្តង់ដាដែលការប្រមូលបានមកវិញគ្រប់ចំនួន ផ្អែកលើមូលដ្ឋាននៃដំណើរហេតុដែលមានស្រាប់លក្ខខណ្ឌ ឬតម្លៃនៃទ្រព្យបញ្ចាំមានការសង្ស័យខ្ពស់ ឬមិនអាចអាចប្រមូលបានវិញ។ ការរំពឹងទុកថានឹងបាត់បង់គឺខ្ពស់ទោះបីជាចំនួនពិតប្រាកដនៅមិនទាន់បានកំណត់សម្រាប់ពេលនេះក៏ដោយ។

ឥណទានខាតបង់

ឥណទានដែលត្រូវបានចាត់ថ្នាក់ថាជាការបាត់បង់ គឺនៅពេលដែលវាមិនអាចប្រមូលបានមកវិញ ហើយការទូទាត់សងវិញអាចមានចំនួនតិចតួច ឬមិនអាចប្រមូលបានសោះពីសមភាគីនូវចំនួនដែលនៅសល់។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(ម). គុណភាពឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល (ត)

ការទទួលស្គាល់ការខាតបង់ឥណទានរំពឹងទុក

ធនាគារអនុវត្តវិធីសាស្ត្រ 3 ដំណាក់កាល ដោយផ្អែកលើការផ្លាស់ប្តូរគុណភាពឥណទានចាប់តាំងពីមានការទទួលស្គាល់ដំបូង៖

វិធីសាស្ត្រ 3 ដំណាក់កាល	ដំណាក់កាលទី1	ដំណាក់កាលទី2	ដំណាក់កាលទី3
	ដំណើរការ	ក្រោមដំណើរការ	មិនដំណើរការ
ការទទួលស្គាល់ការខាតបង់ឥណទានរំពឹងទុក	រំពឹងថាឥណទាននឹងបាត់បង់រយៈពេល 12ខែ	រំពឹងថាឥណទាននឹងបាត់បង់ពេញអាយុកាល	រំពឹងថាឥណទាននឹងបាត់បង់ពេញអាយុកាល
លក្ខណៈវិនិច្ឆ័យ	មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ	ហានិភ័យឥណទានដែលបានកើនឡើងជាសារវន្ត	ឥណទានដែលមានឱនភាពនៃតម្លៃលើទ្រព្យសកម្ម
មូលដ្ឋាននៃការគណនាចំណូលពីការប្រាក់	តម្លៃយោងដុល	តម្លៃយោងដុល	តម្លៃយោងសុទ្ធ

ធនាគារបានវាស់វែង ECL ដោយប្រើវិធីសាស្ត្រទូទៅ។ វិធីសាស្ត្រទូទៅមានការបែងចែកអតិថិជនជាបីដំណាក់កាលផ្សេងគ្នា យោងទៅតាមលក្ខណៈវិនិច្ឆ័យដំណាក់កាលដោយការវាយតម្លៃហានិភ័យឥណទាន។ ECL រយៈពេល 12ខែនឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី1 ខណៈពេលដែល ECL ពេញមួយជីវិតនឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី2 និងដំណាក់កាលទី3 ។ នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារនឹងវាយតម្លៃហានិភ័យឥណទាននៃគណនីនីមួយៗធៀបនឹងកម្រិតហានិភ័យនៅកាលបរិច្ឆេទដើម។

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(v). គុណភាពឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល (ត)

ការទទួលស្គាល់លើការរំពឹងទុកលើការខាតបង់ឥណទាន (ត)

ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)

ដំណាក់កាល	ស្ថានភាពហានិភ័យឥណទាន	ចំណាត់ថ្នាក់	ចំនួនថ្ងៃហួសកាលកំណត់	សូចនាករណ៍នៃការយឺតយ៉ាវ
1	មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ	ឥណទានធម្មតា	0 ដល់ 29ថ្ងៃ	ដំណើរការ
2	ហានិភ័យឥណទានបានកើនឡើងជាសារវន្ត	ឥណទានឃ្លាំមើល	30 ដល់ 89ថ្ងៃ	ក្រោមដំណើរការ
3	ឥណទានដែលមានឱនភាពនៃតម្លៃលើទ្រព្យសកម្ម	ឥណទានក្រោមស្តង់ដា	90 ដល់ 179ថ្ងៃ	មិនដំណើរការ
		ឥណទានជាប់សង្ស័យ	180 ដល់ 359ថ្ងៃ	
		ឥណទានខាតបង់	ចាប់ពី 360ថ្ងៃ	

ឥណទានរយៈពេលខ្លី (1ឆ្នាំ ឬតិចជាង)

ដំណាក់កាល	ស្ថានភាពហានិភ័យឥណទាន	ចំណាត់ថ្នាក់	ចំនួនថ្ងៃហួសកាលកំណត់	សូចនាករណ៍នៃការយឺតយ៉ាវ
1	មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ	ឥណទានធម្មតា	0 ដល់ 14ថ្ងៃ	ដំណើរការ
2	ហានិភ័យឥណទានបានកើនឡើងជាសារវន្ត	ឥណទានឃ្លាំមើល	15 ដល់ 30ថ្ងៃ	ក្រោមដំណើរការ
3	ឥណទានដែលមានឱនភាពនៃតម្លៃលើទ្រព្យសកម្ម	ឥណទានក្រោមស្តង់ដា	31 ដល់ 60ថ្ងៃ	មិនដំណើរការ
		ឥណទានជាប់សង្ស័យ	61 ដល់ 90ថ្ងៃ	
		ឥណទានខាតបង់	ចាប់ពី 91ថ្ងៃ	

ធនាគារនឹងប្រើប្រាស់ព័ត៌មានថ្ងៃជុតកំណត់ ("DPD") និងការចាត់ថ្នាក់របស់ NBC សម្រាប់លក្ខណៈវិនិច្ឆ័យដំណាក់កាល។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(ii). គុណភាពឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល (ត)

ការទទួលស្គាល់លើការរំពឹងទុកលើការខាតបង់ឥណទាន (ត)

តារាងខាងក្រោមសង្ខេបពីគុណភាពឥណទាននៃហិរញ្ញប្បទានដុលរបស់ធនាគារ ដោយយោងតាមចំណាត់ថ្នាក់ខាងលើ។

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025			
	ដំណាក់កាលទី1 ដុល្លារអាមេរិក	ដំណាក់កាលទី2 ដុល្លារអាមេរិក	ដំណាក់កាលទី3 ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនតាមរំលស់ថ្លៃដើម				
ឥណទានធម្មតា	804,894,464	6,796,076	1,947,977	813,638,517
ឥណទានឃ្លាំមើល	10,478,325	16,859,356	441,481	27,779,162
ឥណទានក្រោមស្តង់ដា	5,962,181	32,701,739	38,792,768	77,456,688
ឥណទានជាប់សង្ស័យ	1,201,946	1,896,415	55,893,164	58,991,525
ឥណទានខាតបង់	243,135	90,290	49,458,575	49,792,000
	822,780,051	58,343,876	146,533,965	1,027,657,892
សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ (*)	(4,267,165)	(14,366,069)	(64,735,548)	(83,368,782)
តម្លៃយោង (ដុល្លារអាមេរិក)	818,512,886	43,977,807	81,798,417	944,289,110
តម្លៃយោង (ពាន់រៀល) - (កំណត់សម្គាល់ 3)	3,284,692,212	176,482,939	328,257,047	3,789,432,198

(*) ចំនួនទឹកប្រាក់នេះ មិនត្រូវបានរាប់បញ្ចូលការខាតបង់លើការខាតបង់សម្រាប់តារាងតុល្យការទេ។ សូមមើលខាងក្រោម ដូចបង្ហាញ៖

កិច្ចសន្យាឥណទាននិងកិច្ចសន្យាធានាហិរញ្ញវត្ថុ				
ធម្មតា	1,791,735	-	-	1,791,735
សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ	(2,686)	-	-	(2,686)
តម្លៃយោង (ដុល្លារអាមេរិក)	1,789,049	-	-	1,789,049
តម្លៃយោង (ពាន់រៀល) – (កំណត់សម្គាល់ 3)	7,179,454	-	-	7,179,454

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(ស). គុណភាពឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល (ត)

ការទទួលស្គាល់លើការរំពឹងទុកលើការខាតបង់ឥណទាន (ត)

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024			
	ដំណាក់កាលទី1 ដុល្លារអាមេរិក	ដំណាក់កាលទី2 ដុល្លារអាមេរិក	ដំណាក់កាលទី3 ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនតាមរំលស់ថ្លៃដើម				
ឥណទានធម្មតា	1,090,650,298	79,896	791,149	1,091,521,343
ឥណទានឃ្លាំមើល	18,199,833	8,061,190	32,859	26,293,882
ឥណទានក្រោមស្តង់ដា	12,438,058	51,782,983	11,246,151	75,467,192
ឥណទានជាប់សង្ស័យ	3,304,770	3,719,338	20,582,895	27,607,003
ឥណទានខាតបង់	859,198	544,217	1,622,940	3,026,355
	1,125,452,157	64,187,624	34,275,994	1,223,915,775
សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ (*)	(4,282,483)	(17,043,539)	(16,179,116)	(37,505,138)
តម្លៃយោង (ដុល្លារអាមេរិក)	1,121,169,674	47,144,085	18,096,878	1,186,410,637
តម្លៃយោង (ពាន់រៀល) – (កំណត់សម្គាល់ 3)	4,512,707,938	189,754,942	72,839,934	4,775,302,814

(*) ចំនួនទឹកប្រាក់នេះ មិនត្រូវបានរាប់បញ្ចូលការខាតបង់លើការខាតបង់សម្រាប់តារាងតុល្យការទេ។ សូមមើលខាងក្រោមដូចបង្ហាញ៖

កិច្ចសន្យាផ្តល់ឥណទាន និងការធានាលើហិរញ្ញបទាន				
ធម្មតា	1,229,281	-	-	1,229,281
ឱនភាពនៃតម្លៃ	(897)	-	-	(897)
សមតុល្យយោង (ដុល្លារអាមេរិក)	1,228,384	-	-	1,228,384
តម្លៃយោង (ពាន់រៀល) – (កំណត់សម្គាល់ 3)	4,944,246	-	-	4,944,246

ការដាក់បញ្ចូលព័ត៌មានលើការប្រមើលមើលនាពេលអនាគត

ធនាគារដាក់បញ្ចូលព័ត៌មានលើការប្រមើលមើលអនាគត ដោយវាយតម្លៃ ថាតើហានិភ័យឥណទានរបស់ឧបករណ៍ហិរញ្ញវត្ថុបានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់ដំបូង និងការវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(iv). គុណភាពឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនដុល (ត)

ការដាក់បញ្ចូលព័ត៌មានលើការប្រមើលមើលនាពេលអនាគត (ត)

ព័ត៌មានខាងក្រៅដែលត្រូវបានពិចារណារួមមានទិន្នន័យសេដ្ឋកិច្ច និងការព្យាករណ៍ដែលបានបោះពុម្ពផ្សាយដោយស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធរប្រតិបត្តិការ ដែលមានអង្គការអន្តរជាតិធំៗ ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ និងវិស័យឯកជន និងការសិក្សារបស់អ្នកព្យាករណ៍។

ធនាគារបានកំណត់ និងចងក្រងឯកសារគន្លឹះនៃហានិភ័យឥណទាន និងឥណទានខាតបង់សម្រាប់ផលបត្រឧបករណ៍ហិរញ្ញវត្ថុ ស្របតាមប្រទេសនីមួយៗ ហើយប្រើការវិភាគទិន្នន័យប្រវត្តិសាស្ត្រ បានប៉ាន់ស្មានទំនាក់ទំនងរវាងអថេរម៉ាក្រូសេដ្ឋកិច្ច និងហានិភ័យឥណទាន និងឥណទានខាតបង់។

(v). ចំនួនកើតឡើងពីការខាតបង់ឥណទានរំពឹងទុក

សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ

តារាងខាងក្រោម បង្ហាញពីការផ្ទៀងផ្ទាត់លើសំវិធានធនលើឱនភាពនៃតម្លៃតាមការចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុនាដើម និងចុងការិយបរិច្ឆេទ។

	2025			
	ដំណាក់កាលទី1 ដុល្លារអាមេរិក	ដំណាក់កាលទី2 ដុល្លារអាមេរិក	ដំណាក់កាលទី3 ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនតាមរំលស់ថ្លៃដើម				
ថ្ងៃទី1 ខែមករា	1,125,452,157	64,187,624	34,275,994	1,223,915,775
- ផ្ទេរទៅដំណាក់កាលទី1	1,517,927	(1,064,022)	(453,905)	-
- ផ្ទេរទៅដំណាក់កាលទី2	(24,040,518)	24,268,830	(228,312)	-
- ផ្ទេរទៅដំណាក់កាលទី3	(54,428,645)	(35,084,911)	89,513,556	-
ទ្រព្យសកម្មហិរញ្ញវត្ថុថ្មី	44,894,510	14,577,092	25,833,794	85,305,396
ទ្រព្យសកម្មហិរញ្ញវត្ថុដែលឈប់ទទួលស្គាល់	(270,615,380)	(8,540,737)	(2,372,388)	(281,528,505)
ការលុបចោល	-	-	(34,774)	(34,774)
ថ្ងៃទី31 ខែធ្នូ (ដុល្លារអាមេរិក)	822,780,051	58,343,876	146,533,965	1,027,657,892
ថ្ងៃទី31 ខែធ្នូ (ពាន់រៀល) - កំណត់សម្គាល់ 3	3,301,816,345	234,133,974	588,040,802	4,123,991,121

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(v). ចំនួនកើតឡើងពីការខាតបង់ឥណទានរំពឹងទុក (ត)

សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ (ត)

	2024			
	ដំណាក់កាលទី1 ដុល្លារអាមេរិក	ដំណាក់កាលទី2 ដុល្លារអាមេរិក	ដំណាក់កាលទី3 ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
សំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទាន ដល់អតិថិជនតាមតម្លៃរំលស់ថ្លៃដើម				
ថ្ងៃទី1 ខែមករា	1,161,704,190	11,988,508	42,481,848	1,216,174,546
- ផ្ទេរទៅដំណាក់កាលទី1	1,611,948	(1,008,777)	(603,171)	-
- ផ្ទេរទៅដំណាក់កាលទី2	(6,925,182)	7,034,411	(109,229)	-
- ផ្ទេរទៅដំណាក់កាលទី3	(24,049,411)	(1,239,004)	25,288,415	-
ទ្រព្យសកម្មហិរញ្ញវត្ថុថ្មី	366,832,694	57,015,737	6,940,866	430,789,297
ទ្រព្យសកម្មហិរញ្ញវត្ថុដែលឈប់ទទួលស្គាល់	(373,722,082)	(9,603,251)	(2,579,959)	(385,905,292)
ការលុបចោល	-	-	(37,142,776)	(37,142,776)
ថ្ងៃទី31 ខែធ្នូ (ដុល្លារអាមេរិក)	1,125,452,157	64,187,624	34,275,994	1,223,915,775
ថ្ងៃទី31 ខែធ្នូ (ពាន់រៀល) - កំណត់សម្គាល់ 3	4,529,944,932	258,355,187	137,960,876	4,926,260,994

	2025			
	ដំណាក់កាលទី1 ដុល្លារអាមេរិក	ដំណាក់កាលទី2 ដុល្លារអាមេរិក	ដំណាក់កាលទី3 ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
សំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទាន ដល់អតិថិជនតាមតម្លៃរំលស់ថ្លៃដើម				
ថ្ងៃទី1 ខែមករា	4,283,380	17,043,539	16,179,116	37,506,035
- ផ្ទេរទៅដំណាក់កាលទី1	467,307	(268,015)	(199,292)	-
- ផ្ទេរទៅដំណាក់កាលទី2	(105,500)	203,506	(98,006)	-
- ផ្ទេរទៅដំណាក់កាលទី3	(251,556)	(9,541,347)	9,792,903	-
ការវាស់វែងឡើងវិញនៃឱនភាព	15,921	5,479,604	34,538,600	40,034,125
ទ្រព្យសកម្មហិរញ្ញវត្ថុថ្មី	862,398	3,656,434	3,568,975	8,087,807
ទ្រព្យសកម្មហិរញ្ញវត្ថុដែលឈប់ទទួលស្គាល់	(1,004,785)	(2,207,652)	(985,219)	(4,197,656)
ការកត់ត្រាបង្គរឡើងវិញនូវតម្លៃអប្បហារូច នៅលើការប្រាក់នៃឥណទាននៅក្នុងដំណាក់កាលទី3	-	-	1,973,245	1,973,245
ការលុបចោល	-	-	(34,774)	(34,774)
ក្រៅតារាងតុល្យការ	2,686	-	-	2,686
ថ្ងៃទី31 ខែធ្នូ (ដុល្លារអាមេរិក)	4,269,851	14,366,069	64,735,548	83,371,468
ថ្ងៃទី31 ខែធ្នូ (ពាន់រៀល) - កំណត់សម្គាល់ 3	17,134,912	57,651,035	259,783,754	334,569,701

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ខ. ហានិភ័យឥណទាន (ត)

(v). ចំនួនកើតឡើងពីការខាតបង់ឥណទានរំពឹងទុក (ត)

សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ (ត)

	2024			
	ដំណាក់កាលទី1 ដុល្លារអាមេរិក	ដំណាក់កាលទី2 ដុល្លារអាមេរិក	ដំណាក់កាលទី3 ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
សំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទាន ដល់អតិថិជនតាមតម្លៃរំលស់ថ្លៃដើម				
ថ្ងៃទី1 ខែមករា	6,787,727	2,811,670	25,722,015	35,321,412
- ផ្ទេរទៅដំណាក់កាលទី1	590,393	(235,801)	(354,592)	-
- ផ្ទេរទៅដំណាក់កាលទី2	(41,407)	106,509	(65,102)	-
- ផ្ទេរទៅដំណាក់កាលទី3	(144,963)	(290,525)	435,488	-
ការវាស់វែងឡើងវិញនៃឧនភាព	(2,619,762)	1,631,507	11,370,285	10,382,030
ទ្រព្យសកម្មហិរញ្ញវត្ថុថ្មី	1,891,223	15,273,435	38,699,807	55,864,465
ទ្រព្យសកម្មហិរញ្ញវត្ថុដែលឈប់ទទួលស្គាល់	(2,180,728)	(2,253,256)	(23,065,101)	(27,499,085)
ការកត់ត្រាបង្គរឡើងវិញនូវតម្លៃអប្បហារូច នៅលើការប្រាក់នៃឥណទាននៅក្នុង ដំណាក់កាលទី3	-	-	579,092	579,092
ការលុបចោល	-	-	(37,142,776)	(37,142,776)
ក្រៅតារាងតុល្យការ	897	-	-	897
ថ្ងៃទី31 ខែធ្នូ (ដុល្លារអាមេរិក)	4,283,380	17,043,539	16,179,116	37,506,035
ថ្ងៃទី31 ខែធ្នូ (ពាន់រៀល) - កំណត់សម្គាល់ 3	17,240,605	68,600,244	65,120,941	150,961,790

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

គ. ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារគឺជាហានិភ័យដែលមានការផ្លាស់ប្តូរតម្លៃទីផ្សារ - ឧទាហរណ៍ អត្រាការប្រាក់ អត្រាប្តូរប្រាក់ បណ្ណបរទេស និងតម្លៃមូលធន - នឹងមានផលប៉ះពាល់ដល់ប្រាក់ចំណូលរបស់ធនាគារ ឬតម្លៃនៃការកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុ។ គោលបំណងនៃការគ្រប់គ្រងហានិភ័យទីផ្សារ គឺដើម្បីគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យទីផ្សារតាមប៉ារ៉ាម៉ែត្រដែលអាចទទួលយកបាន ខណៈពេលដែលមានការបង្កើននូវប្រសិទ្ធភាពក្នុងការទទួលបានចំណូលមកវិញ។

(i). ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺសំដៅលើការខាតបង់នូវប្រាក់ចំណូលការប្រាក់សុទ្ធ ដោយសារតែការប្រែប្រួលនៃកម្រិតអត្រាការប្រាក់ និងការផ្លាស់ប្តូរនៅក្នុងសមាសភាពនៃទ្រព្យសកម្ម និងបំណុល។ ហានិភ័យអត្រាការប្រាក់ ត្រូវបានគ្រប់គ្រងតាមរយៈការត្រួតពិនិត្យយ៉ាងហ្មត់ចត់ លើចំណូលនៃការបណ្តាក់ទុន តម្លៃទីផ្សារ តម្លៃដើមនៃមូលនិធិ។ សក្តានុពលនៃការធ្លាក់ចុះចំណូលការប្រាក់សុទ្ធ បណ្តាលមកពីការប្រែប្រួលអត្រាការប្រាក់ដែលខុសប្រក្រតី បានត្រួតពិនិត្យដោយធៀបទៅនឹងកម្រិតអាចទទួលយកបាននៃហានិភ័យ។

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យតាមតម្លៃយោងនៃអត្រាការប្រាក់របស់ធនាគារ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់មួយណាដែលកើតឡើងមុន។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

គ. ហានិភ័យទីផ្សារ (ត)

(i). ហានិភ័យអត្រាការប្រាក់ (ត)

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យតាមតម្លៃយោងនៃអត្រាការប្រាក់របស់ធនាគារ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់មួយណាដែលកើតឡើងមុន។

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	រហូតដល់ 1ខែ ដុល្លារអាមេរិក	>1−3ខែ ដុល្លារអាមេរិក	>3−12ខែ ដុល្លារអាមេរិក	>1−5ឆ្នាំ ដុល្លារអាមេរិក	លើសពី 5ឆ្នាំ ដុល្លារអាមេរិក	ពុំមានការប្រាក់ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក	អត្រាការប្រាក់ %
ទ្រព្យសកម្មហិរញ្ញវត្ថុ								
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	-	-	-	-	-	14,471,927	14,471,927	ពុំមាន
ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា	11,070,017	10,073,046	30,095,484	-	27,590,000	201,114,465	279,943,012	0.19% - 1.30%
ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	13,560,976	-	15,265,230	-	-	24,185,788	53,011,994	0.10% - 4.00%
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	4,482,261	3,240,137	22,559,630	316,524,631	597,479,765	-	944,286,424	5.5% - 18.00%
មូលបត្រវិនិយោគ	-	-	-	-	-	15,353	15,353	ពុំមាន
ទ្រព្យសកម្មផ្សេងៗ	-	309,257	-	-	-	1,729,780	2,039,037	1.52%
	29,113,254	13,622,440	67,920,344	316,524,631	625,069,765	241,517,313	1,293,767,747	
បំណុលហិរញ្ញវត្ថុ								
ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	252,248,301	81,277,862	254,164,607	182,935,474	40,627	115,487	770,782,358	0.50% - 5.50%
ប្រាក់កម្ចី	-	1,495,463	26,968,757	40,289,073	-	-	68,753,293	6.00% - 8.00%
គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ	-	-	50,280,972	-	-	-	50,280,972	5.95%
បំណុលភតិសន្យា	223,029	654,107	2,206,652	10,379,259	356,234	-	13,819,281	4.50% - 8.30%
បំណុលផ្សេងៗ	-	-	-	-	-	6,406,098	6,406,098	ពុំមាន
	252,471,330	83,427,432	333,620,988	233,603,806	396,861	6,521,585	910,042,002	
គំលាតរំលោចការប្រាក់	(223,358,076)	(69,804,992)	(265,700,644)	82,920,825	624,672,904	234,995,728	383,725,745	
តម្លៃយោង (ពាន់រៀល) - កំណត់សម្គាល់ 3	(896,335,959)	(280,127,433)	(1,066,256,684)	332,761,271	2,506,812,364	943,037,856	1,539,891,415	
ខ្នង់ក្រៅតារាងតុល្យការ								
កិច្ចសន្យាឥណទាន	-	-	-	-	-	299,535	299,535	ពុំមាន
កិច្ចសន្យាធានាហិរញ្ញវត្ថុ	-	-	-	-	-	1,489,514	1,489,514	ពុំមាន
	-	-	-	-	-	1,789,049	1,789,049	
តម្លៃយោង (ពាន់រៀល) - កំណត់សម្គាល់ 3	-	-	-	-	-	7,179,454	7,179,454	

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

គ. ហានិភ័យទីផ្សារ (ត)

(i). ហានិភ័យអត្រាការប្រាក់ (ត)

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យតាមតម្លៃយោងនៃអត្រាការប្រាក់របស់ធនាគារ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់មួយណាដែលកើតឡើងមុន។ (ត)

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	រហូតដល់ 1ខែ ដុល្លារអាមេរិក	>1–3ខែ ដុល្លារអាមេរិក	>3–12ខែ ដុល្លារអាមេរិក	>1–5ឆ្នាំ ដុល្លារអាមេរិក	លើសពី 5ឆ្នាំ ដុល្លារអាមេរិក	ពុំមានការប្រាក់ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក	អត្រាការប្រាក់ %
ទ្រព្យសកម្មហិរញ្ញវត្ថុ								
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	-	-	-	-	-	17,960,933	17,960,933	ពុំមាន
ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា	-	93,689	99,689	-	93,233,167	120,102,882	213,529,427	1.18% - 1.40%
ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	3,345,477	-	22,282,695	-	-	10,891,352	36,519,524	0.10% - 4.00%
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	28,607,724	8,035,140	59,480,756	484,913,175	605,372,945	-	1,186,409,740	8.00% - 18.00%
មូលបត្រវិនិយោគ	-	-	-	-	-	15,353	15,353	ពុំមាន
ទ្រព្យសកម្មផ្សេងៗ	-	109,617	-	-	-	2,094,478	2,204,095	5%
	31,953,201	8,238,446	81,863,140	484,913,175	698,606,112	151,064,998	1,456,639,072	
បំណុលហិរញ្ញវត្ថុ								
ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	230,425,671	79,425,268	241,334,649	186,709,119	129,640	1,025	738,025,372	0.50% - 9.00%
ប្រាក់កម្ចី	4,970,210	4,968,266	21,868,114	68,684,775	-	-	100,491,365	4.60% - 8.50%
គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ	2,000,000	-	146,773,510	62,476,765	-	-	211,250,275	5.89% - 6.18%
បំណុលភតិសន្យា	262,687	779,420	2,551,431	10,905,083	902,635	-	15,401,256	4.50% - 8.39%
បំណុលផ្សេងៗ	-	-	-	-	-	5,637,605	5,637,605	ពុំមាន
	237,658,568	85,172,954	412,527,704	328,775,742	1,032,275	5,638,630	1,070,805,873	
សរុបគំលាតរំលោចការប្រាក់	(205,705,367)	(76,934,508)	(330,664,564)	156,137,433	697,573,837	145,426,368	385,833,199	
តម្លៃយោង (ពាន់រៀល) - កំណត់សម្គាល់ 3	(827,964,102)	(309,661,395)	(1,330,924,870)	628,453,168	2,807,734,694	585,341,131	1,552,978,626	
ខ្នង់ក្រៅតារាងតុល្យការ								
កិច្ចសន្យាឥណទាន	-	-	-	-	-	228,834	228,834	ពុំមាន
កិច្ចសន្យាធានាហិរញ្ញវត្ថុ	-	-	-	-	-	999,550	999,550	ពុំមាន
	-	-	-	-	-	1,228,384	1,228,384	
តម្លៃយោង (ពាន់រៀល) - កំណត់សម្គាល់ 3	-	-	-	-	-	4,944,246	4,944,246	

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

គ. ហានិភ័យទីផ្សារ (ត)

(i). ហានិភ័យអត្រាការប្រាក់ (ត)

ការប្រែប្រួលពិន្ទុមូលដ្ឋាន 100 នៅក្នុងអត្រាការប្រាក់នៅកាលបរិច្ឆេទរាយការណ៍ នឹងមានការកើនឡើង/(ថយចុះ) មូលធន និងចំណេញ ឬខាតតាមចំនួនដែលបានបង្ហាញដូចខាងក្រោម។ ការវិភាគសន្មតថារាល់បម្រែបម្រួលផ្សេងទៀត ជាពិសេសអត្រាប្តូរប្រេីយប័ណ្ណបរទេស នៅតែថេរ។

	របាយការណ៍ចំណេញ ឬខាត		មូលធន	
	មូលដ្ឋាន 100 កើនឡើង ដុល្លារអាមេរិក	មូលដ្ឋាន 100 ថយចុះ ដុល្លារអាមេរិក	មូលដ្ឋាន 100 កើនឡើង ដុល្លារអាមេរិក	មូលដ្ឋាន 100 ថយចុះ ដុល្លារអាមេរិក
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025				
ឧបករណ៍ហិរញ្ញវត្ថុ ដែលមានអត្រាអថេរ	29,428	733	29,428	733
ពាន់រៀល – កំណត់សម្គាល់ 3	118,036	2,940	118,036	2,940
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024				
ឧបករណ៍ហិរញ្ញវត្ថុ ដែលមានអត្រាអថេរ	(20,891)	(519)	(20,891)	(519)
ពាន់រៀល – កំណត់សម្គាល់ 3	(85,047)	(2,113)	(85,047)	(2,113)

(ii). ហានិភ័យលើការប្តូរប្រេីយប័ណ្ណបរទេស

ធនាគារដំណើរការក្នុងព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជាចម្បងជាប្រាក់ដុល្លារអាមេរិក រៀលខ្មែរ និងបាតថៃ។

ហានិភ័យលើការប្តូរប្រេីយប័ណ្ណបរទេស គឺជាហានិភ័យដែលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ មានការប្រែប្រួលបណ្តាលមកពីការប្រែប្រួលអត្រាប្តូរប្រេីយប័ណ្ណបរទេស។

គណៈគ្រប់គ្រងមានវិធានការ តាមដានយ៉ាងជិតដល់ និងគ្រប់គ្រងហានិភ័យលើការប្តូរប្រេីយប័ណ្ណបរទេសជារៀងរាល់ថ្ងៃ និងចាត់វិធានការទាន់ពេលវេលាតាមការចាំបាច់។ ស្ថានភាពចំហសុទ្ធត្រូវបានត្រួតពិនិត្យ និងអនុលោមតាមបទប្បញ្ញត្តិ និងគោលនយោបាយហានិភ័យផ្ទៃក្នុង។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

គ. ហានិភ័យទីផ្សារ (ត)

(i). ហានិភ័យលើការប្តូរប្រាក់បរទេស (ត)

ការប្រមូលផ្តុំហានិភ័យរូបិយប័ណ្ណ

តម្លៃយោងដុលនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ តាមប្រភេទនៃរូបិយប័ណ្ណមានដូចខាងក្រោម៖

	ប្រភេទនៃរូបិយប័ណ្ណ សមមូលដុល្លារអាមេរិក			
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	ដុល្លារអាមេរិក	រៀលខ្មែរ	បាតថៃ	សរុប
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ក្នុងដៃ	9,763,241	4,686,387	22,299	14,471,927
ប្រាក់បញ្ញើជាមួយធនាគារជាតិនៃកម្ពុជា	258,391,587	21,551,425	-	279,943,012
ប្រាក់បញ្ញើនៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនានា	46,944,122	6,061,171	6,701	53,011,994
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	834,064,564	108,041,773	2,180,087	944,286,424
មូលបត្រវិនិយោគ	15,353	-	-	15,353
ទ្រព្យសកម្មផ្សេងៗ	1,885,710	114,252	39,075	2,039,037
	1,151,064,577	140,455,008	2,248,162	1,293,767,747
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើរបស់អតិថិជន និង គ្រឹះស្ថានហិរញ្ញវត្ថុនានា	692,042,688	78,534,947	204,723	770,782,358
ប្រាក់កម្ចី	1,248,745	67,504,548	-	68,753,293
គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ	50,280,972	-	-	50,280,972
បំណុលភតិសន្យា	13,819,281	-	-	13,819,281
បំណុលផ្សេងៗ	6,231,883	171,002	3,213	6,406,098
	763,623,569	146,210,497	207,936	910,042,002
ស្ថានភាពទ្រព្យសកម្ម/(បំណុល)សុទ្ធ	387,441,008	(5,755,489)	2,040,226	383,725,745
សមមូលពាន់រៀល (កំណត់សម្គាល់ 3)	1,554,800,765	(23,096,777)	8,187,427	1,539,891,415
ខ្ទង់ក្រៅតារាងតុល្យការ				
កិច្ចសន្យាឥណទាន	299,535	-	-	299,535
កិច្ចសន្យាធានាហិរញ្ញវត្ថុ	1,489,514	-	-	1,489,514
	1,789,049	-	-	1,789,049

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

គ. ហានិភ័យទីផ្សារ (ត)

(ii). *ហានិភ័យរូបិយប័ណ្ណបរទេស (ត)*

ការប្រមូលផ្តុំហានិភ័យរូបិយប័ណ្ណ (ត)

តម្លៃយោងដុលទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ តាមប្រភេទនៃរូបិយប័ណ្ណមានដូចខាងក្រោម៖ (ត)

	ប្រភេទនៃរូបិយប័ណ្ណ សមមូលដុល្លារអាមេរិក			
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	ដុល្លារអាមេរិក	រៀលខ្មែរ	បាតថៃ	សរុប
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ក្នុងដៃ	12,086,409	5,584,852	289,672	17,960,933
ប្រាក់បញ្ញើជាមួយធនាគារជាតិនៃកម្ពុជា	192,082,862	21,446,565	-	213,529,427
ប្រាក់បញ្ញើនៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនានា	33,812,681	2,692,413	14,430	36,519,524
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	1,041,206,305	141,782,032	3,421,403	1,186,409,740
មូលបត្រវិនិយោគ	15,353	-	-	15,353
ទ្រព្យសកម្មផ្សេងៗ	2,015,021	115,733	73,341	2,204,095
	1,281,218,631	171,621,595	3,798,846	1,456,639,072
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើរបស់អតិថិជន និង គ្រឹះស្ថានហិរញ្ញវត្ថុនានា	660,392,660	76,948,019	684,693	738,025,372
ប្រាក់កម្ចី	5,501,948	94,989,417	-	100,491,365
គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ	211,250,275	-	-	211,250,275
បំណុលភតិសន្យា	15,401,256	-	-	15,401,256
បំណុលផ្សេងៗ	5,476,828	156,991	3,786	5,637,605
	898,022,967	172,094,427	688,479	1,070,805,873
ស្ថានភាពទ្រព្យសកម្ម/(បំណុល)សុទ្ធ	383,195,664	(472,832)	3,110,367	385,833,199
សមមូលពាន់រៀល (កំណត់សម្គាល់ 3)	1,542,362,548	(1,903,149)	12,519,227	1,552,978,626
តារាងតុល្យការខាងក្រៅ				
កិច្ចសន្យាឥណទាន	228,834	-	-	228,834
កិច្ចសន្យាធានាហិរញ្ញវត្ថុ	999,550	-	-	999,550
	1,228,384	-	-	1,228,384

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

គ. ហានិភ័យទីផ្សារ (ត)

(i). *ហានិភ័យរូបិយប័ណ្ណបរទេស (ត)*

ការវិភាគរំញោច

សន្មតថា ហានិភ័យអថេរផ្សេងទៀតនៅតែថេរ ការប្រែប្រួលនៃការប្តូររូបិយប័ណ្ណបរទេសសម្រាប់ធនាគារ នាកាលបរិច្ឆេទរាយការណ៍ត្រូវបានសង្ខេបដូចខាងក្រោម (ដោយបង្ហាញតែរូបិយប័ណ្ណចម្បងនៅក្នុងតារាង ខាងក្រោម។ សម្រាប់រូបិយប័ណ្ណផ្សេងទៀត ការលាតត្រដាងទាំងនេះត្រូវបានដាក់ជាក្រុម "ផ្សេងៗ")៖

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	
	-1% ការថយចុះ ដុល្លារអាមេរិក	+1% ការកើនឡើង ដុល្លារអាមេរិក	-1% ការថយចុះ ដុល្លារអាមេរិក	+1% ការកើនឡើង ដុល្លារអាមេរិក
ប្រាក់រៀលខ្មែរ	(58,136)	56,985	(4,776)	4,681
ប្រាក់បាតថៃ	20,608	(20,200)	31,418	(30,796)
សរុប	(37,528)	36,785	26,642	(26,115)
ពាន់រៀល – កំណត់សម្គាល់ 3	(150,600)	147,618	107,233	(105,113)

ឃ. ហានិភ័យសន្ទនីយភាព

"ហានិភ័យសន្ទនីយភាព" គឺជាហានិភ័យដែលធនាគារនឹងជួបផលលំបាកក្នុងការបំពេញកាតព្វកិច្ច ពាក់ព័ន្ធនឹង បំណុលហិរញ្ញវត្ថុរបស់ខ្លួន ដែលត្រូវបានទូទាត់តាមរយៈជាសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត។ ហានិភ័យសន្ទនីយភាព កើតឡើងពីភាពមិនស៊ីគ្នាទៅនឹងពេលវេលា និងចំនួនលំហូរសាច់ប្រាក់ដែលមាននៅ ក្នុងប្រតិបត្តិការ និងការវិនិយោគរបស់ធនាគារ។

ការគ្រប់គ្រងហានិភ័យសន្ទនីយភាព

ធនាគារ គ្រប់គ្រងសន្ទនីយភាពរបស់ខ្លួនតាមរយៈគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម បំណុលដែលទទួល ខុសត្រូវក្នុងការបង្កើតគោលនយោបាយសន្ទនីយភាព និងត្រួតពិនិត្យសន្ទនីយភាពជាប្រចាំ។ តម្រូវការ ទ្រព្យសកម្មងាយស្រួលអប្បបរមា ត្រូវបានបង្កើតឡើងដើម្បីធានាថា អនុបាតនៃទ្រព្យសកម្មងាយស្រួល និង បំណុលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវទទួលបានកម្រិតអប្បបរមាគ្រប់ពេលវេលា។

សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ នាយកដ្ឋានរតនាគារមានការត្រួតពិនិត្យ និងគ្រប់គ្រងសាច់ប្រាក់ដើម្បីធានាថា មានសាច់ប្រាក់គ្រប់គ្រាន់ដើម្បីបំពេញតម្រូវការទាន់ពេលវេលា។

តារាងខាងក្រោមសង្ខេបពីទ្រព្យសកម្ម និងបំណុលរបស់ធនាគារ ដោយផ្អែកលើឥណប្រតិទានតាមកិច្ចសន្យា ដែលនៅសល់។ លំហូរសាច់ប្រាក់ដែលបានរំពឹងទុកលើទ្រព្យសកម្ម និងបំណុលទាំងនេះ អាចខុសជាសារវន្តពីអ្វី ដែលបានបង្ហាញនៅក្នុងតារាង។ ឧទាហរណ៍ ប្រាក់បញ្ញើរបស់អតិថិជនមិនត្រូវបានរំពឹងថានឹងត្រូវដកបានភ្លាមៗ នោះទេ។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ឃ. ហានិភ័យសន្ទនីយភាព (ត)

ការគ្រប់គ្រងហានិភ័យសន្ទនីយភាព (ត)

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025	តម្លៃយោង ដុល្លារអាមេរិក	លំហូរចូល/ (លំហូរចេញ)សរុប ដុល្លារអាមេរិក	រហូតដល់ 1ខែ ដុល្លារអាមេរិក	>1−3ខែ ដុល្លារអាមេរិក	>3−12ខែ ដុល្លារអាមេរិក	>1−5ឆ្នាំ ដុល្លារអាមេរិក	លើសពី 5ឆ្នាំ ដុល្លារអាមេរិក	ពុំមានកាលវសាន្ត ដុល្លារអាមេរិក
ទ្រព្យសកម្មហិរញ្ញវត្ថុ								
សាច់ប្រាក់ក្នុងដៃ	14,471,927	14,471,927	14,471,927	-	-	-	-	-
ប្រាក់បញ្ញើជាមួយធនាគារជាតិនៃកម្ពុជា	279,943,012	279,943,012	156,524,805	10,073,046	30,095,484	-	83,249,677	-
ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	53,011,994	53,076,567	35,943,392	-	17,068,602	-	-	64,573
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	944,286,424	1,027,657,892	6,665,877	3,782,990	26,216,674	331,937,921	575,685,648	83,368,782
មូលបត្រវិនិយោគ	15,353	15,353	-	-	-	-	-	15,353
ទ្រព្យសកម្មផ្សេងៗ	2,039,037	2,051,588	455,898	1,298,069	30,046	255,024	-	12,551
	1,293,767,747	1,377,216,339	214,061,899	15,154,105	73,410,806	332,192,945	658,935,325	83,461,259
បំណុលហិរញ្ញវត្ថុ								
ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	770,782,358	770,782,358	252,248,301	81,277,862	254,164,607	-	183,091,588	-
ប្រាក់កម្ចី	68,753,293	68,753,293	-	1,495,463	21,984,955	45,272,875	-	-
គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ	50,280,972	50,280,972	-	-	50,280,972	-	-	-
បំណុលភតិសន្យា	13,819,281	17,662,147	289,468	578,935	2,605,209	10,769,397	3,419,138	-
បំណុលផ្សេងៗ	6,406,098	6,406,098	5,714,492	378,122	39,559	92,436	181,489	-
	910,042,002	913,884,868	258,252,261	83,730,382	329,075,302	56,134,708	186,692,215	-
អតិរេក/(ឱនភាព)សន្ទនីយភាពសុទ្ធ	383,725,745	463,331,471	(44,190,362)	(68,576,277)	(255,664,496)	276,058,237	472,243,110	83,461,259
សមមូលពាន់រៀល (កំណត់សម្គាល់ 3)	1,539,891,415	1,859,349,193	(177,335,923)	(275,196,600)	(1,025,981,622)	1,107,821,705	1,895,111,600	334,930,032
តារាងតុល្យការខាងក្រៅ								
កិច្ចសន្យាឥណទាន	299,535	301,590	301,590	-	-	-	-	-
កិច្ចសន្យាធានាហិរញ្ញវត្ថុ	1,489,514	1,490,145	1,490,145	-	-	-	-	-
	1,789,049	1,791,735	1,791,735	-	-	-	-	-
សមមូលពាន់រៀល (កំណត់សម្គាល់ 3)	7,179,454	7,190,233	7,190,233	-	-	-	-	-

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ឃ. ហានិភ័យសន្ទនីយភាព (ត)

ការគ្រប់គ្រងហានិភ័យសន្ទនីយភាព (ត)

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	តម្លៃយោង ដុល្លារអាមេរិក	លំហូរចូល/(លំហូរចេញ)សរុប ដុល្លារអាមេរិក	រហូតដល់ 1ខែ ដុល្លារអាមេរិក	>1−3ខែ ដុល្លារអាមេរិក	>3−12ខែ ដុល្លារអាមេរិក	>1−5ឆ្នាំ ដុល្លារអាមេរិក	លើសពី 5ឆ្នាំ ដុល្លារអាមេរិក	ពុំមានកាលវិសាន្ត ដុល្លារអាមេរិក
ទ្រព្យសកម្មហិរញ្ញវត្ថុ								
សាច់ប្រាក់ក្នុងដៃ	17,960,933	17,960,933	17,960,933	-	-	-	-	-
ប្រាក់បញ្ញើជាមួយធនាគារជាតិនៃកម្ពុជា	213,529,427	213,529,427	120,101,465	94,592	100,203	-	93,233,167	-
ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	36,519,524	36,569,362	14,254,847	-	22,264,677	-	-	49,838
ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន	1,186,409,740	1,223,915,775	2,338,671	3,515,412	21,270,018	485,804,325	673,482,211	37,505,138
មូលបត្រវិនិយោគ	15,353	15,353	-	-	-	-	-	15,353
ទ្រព្យសកម្មផ្សេងៗ	2,204,095	2,212,746	501,128	1,377,859	35,298	289,810	-	8,651
	1,456,639,072	1,494,203,596	155,157,044	4,987,863	43,670,196	486,094,135	766,715,378	37,578,980
បំណុលហិរញ្ញវត្ថុ								
ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	738,025,372	738,025,372	233,860,214	84,226,978	250,604,716	169,199,494	133,970	-
ប្រាក់កម្ចី	100,491,365	100,491,365	4,981,067	4,979,123	21,936,636	68,594,539	-	-
គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ	211,250,275	211,250,275	2,019,847	-	146,940,853	62,289,575	-	-
បំណុលភតិសន្យា	15,401,256	20,044,467	337,984	675,968	3,041,856	10,530,792	5,457,867	-
បំណុលផ្សេងៗ	5,637,605	5,637,605	4,586,178	528,777	102,071	212,130	208,449	-
	1,070,805,873	1,075,449,084	245,785,290	90,410,846	422,626,132	310,826,530	5,800,286	-
អតិរេក/(ឱនភាព)សន្ទនីយភាពសុទ្ធ	385,833,199	418,754,512	(90,628,246)	(85,422,983)	(378,955,936)	175,267,605	760,915,092	37,578,980
សមមូលពាន់រៀល (កំណត់សម្គាល់ 3)	1,552,978,626	1,685,486,911	(364,778,690)	(343,827,507)	(1,525,297,642)	705,452,110	3,062,683,245	151,255,395
តារាងតុល្យការខាងក្រៅ								
កិច្ចសន្យាឥណទាន	229,731	229,731	228,834	-	-	-	-	-
កិច្ចសន្យាធានាហិរញ្ញវត្ថុ	999,550	999,550	999,550	-	-	-	-	-
	1,229,281	1,229,281	1,228,384	-	-	-	-	-
សមមូលពាន់រៀល (កំណត់សម្គាល់ 3)	4,947,856	4,947,856	4,944,246	-	-	-	-	-

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ង. ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យនៃការបាត់បង់ផ្ទាល់ ឬប្រយោលដែលកើតមានឡើងពីការខ្វះខាត ឬការអនុវត្តមិនមានប្រសិទ្ធភាពនូវនីតិវិធីដំណើរការផ្ទៃក្នុង បុគ្គលិក ឬប្រព័ន្ធ ឬពីកត្តាខាងក្រៅ។ ហានិភ័យនេះត្រូវបានគ្រប់គ្រងតាមរយៈការបង្កើតប្រព័ន្ធដំណើរការគ្រប់គ្រងប្រតិបត្តិការ ការត្រួតពិនិត្យ និងការរាយការណ៍ឱ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្ម តាមរយៈការគ្រប់គ្រង និងត្រួតពិនិត្យពីគណៈគ្រប់គ្រងជាន់ខ្ពស់។ ទាំងនេះរួមមានហានិភ័យខាងផ្នែកច្បាប់ តាមច្បាប់នៃការអនុលោម (ផ្តល់អាក្រក់) តាមគណនេយ្យ និងការក្លែងបន្លំ។

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការរបស់ធនាគារ តម្រូវឱ្យបង្កើតនូវរចនាសម្ព័ន្ធតួនាទី និងវិធីសាស្ត្រនៃការគ្រប់គ្រងរបស់អង្គភាពឱ្យបានច្បាស់លាស់។ គោលការណ៍ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើនត្រូវបានអនុវត្ត រួមមានការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខា ប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់ ការរៀបចំនូវនីតិវិធី និងឯកសារយោងនានា ព្រមទាំងការអនុវត្តតាមបទប្បញ្ញត្តិ និងតម្រូវការតាមច្បាប់នានា។ ដំណើរការទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំឆ្នាំ ដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការ ដែលអាចកើតឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។

ច. ការគ្រប់គ្រងដើមទុន

(i). បទប្បញ្ញត្តិដើមទុន

គោលដៅរបស់ធនាគារក្នុងការគ្រប់គ្រងដើមទុន មានន័យទូលំទូលាយជាង "មូលធន" ដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា
- ការពារលទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរភាពអាជីវកម្ម ដូចនេះ ធនាគារអាចបន្តផ្តល់ផលប្រយោជន៍ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម។

គោលនយោបាយរបស់ធនាគារ គឺធានាឱ្យបាននូវមូលដ្ឋានដើមទុនរឹងមាំដើម្បីរក្សានូវទំនុកចិត្តទីផ្សារ និងដើម្បីធានាស្ថេរភាពនៃការអភិវឌ្ឍយូរអង្វែងរបស់អាជីវកម្ម។ ផលប៉ះពាល់ទៅលើកម្រិតដើមទុនលើភាគលាភរបស់ភាគទុនិក ក៏ត្រូវបានទទួលស្គាល់ ហើយធនាគារបានទទួលស្គាល់នូវតម្រូវការ ដើម្បីធានាបាននូវតុល្យភាពរវាងភាគលាភខ្ពស់ដែលអាចនឹងកើតមានឡើងជាមួយនឹងប្រាក់បម្រុងកម្រិតខ្ពស់ និងអត្ថប្រយោជន៍ និងការធានាដែលផ្តល់ដោយស្ថានភាពដើមទុនល្អ។

ដើមទុនតាមបទប្បញ្ញត្តិ ត្រូវបានគណនាឡើងដោយផ្អែកតាមសេចក្តីណែនាំដែលចេញផ្សាយ ដោយធនាគារជាតិនៃកម្ពុជា ដែលអាចមានភាពខុសគ្នាទៅលើគោលការណ៍សំខាន់ខ្លះៗ បើប្រៀបធៀបទៅនឹងគោលការណ៍ដែលបានទទួលស្គាល់ជាទូទៅ ដែលស្ថាប័នហិរញ្ញវត្ថុនៅប្រទេសដទៃបានអនុវត្ត។ ដូច្នេះ ព័ត៌មានអំពីដើមទុនខាងលើមិនសមស្របសម្រាប់អ្នកប្រើប្រាស់ដែលមិនបានទទួលព័ត៌មានអំពីសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ច. ការគ្រប់គ្រងដើមទុន (ត)

(ii) ការគ្រប់គ្រងហានិភ័យមូលធន

ហានិភ័យមូលធនត្រូវបានវាស់វែង និងត្រួតពិនិត្យដោយប្រើដែនកំណត់ដែលបានគណនាស្របតាមលក្ខខណ្ឌតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា។

នៅថ្ងៃទី22 ខែកុម្ភៈ ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជា បានចេញប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុន (Capital Buffer) សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ យោងតាមមាត្រា 22 នៃប្រកាសនេះ គ្រឹះស្ថានទាំងអស់ត្រូវគោរពតាមបទប្បញ្ញត្តិទាក់ទងនឹងការរក្សាទ្រនាប់ដើមទុនយ៉ាងហោចណាស់ឱ្យបាន 50% នៃដើមទុនសរុបគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2019 និងអនុវត្តឱ្យបានយ៉ាងពេញលេញ គិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2020។

នៅថ្ងៃទី7 ខែមីនា ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបានកំណត់អនុបាតនៃទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital Buffer) ចំនួន 0% រហូតដល់មានការជូនដំណឹងជាថ្មី។

បន្ទាប់មកនៅថ្ងៃទី9 ខែមករា ឆ្នាំ2023 ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណ៍ណែនាំបន្ថែមស្តីពីការអនុវត្តប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលគ្រឹះស្ថានត្រូវបំពេញទ្រនាប់ដើមទុនខនស៊ើវេសិន តាមកម្រិតអនុបាត 1.25% និង 2.5% នៅត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 និងនៅត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 រៀងគ្នា។ ចំពោះអនុបាតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (countercyclical capital buffer) គ្រឹះស្ថានត្រូវរក្សាក្នុងកម្រិត 0% ដដែល។

នៅថ្ងៃទី21 ខែសីហា ឆ្នាំ2024 ធនាគារជាតិនៃកម្ពុជាបានចេញលិខិតលេខ ធ7-024-1718 ឆ.ត អនុញ្ញាតឱ្យស្ថាប័នហិរញ្ញវត្ថុរក្សាអនុបាតនៃទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital Buffer) ចំនួន 1.25% រហូតដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025។

ទោះយ៉ាងណា នៅថ្ងៃទី7 ខែមករា ឆ្នាំ2025 ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីណែនាំ លេខ ធ37-025-023 ស.ឆ.ណ. បន្ថែមទៀត ដើម្បីផ្តល់ជាជម្រើសដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើក្នុងការអនុវត្តក្របខ័ណ្ឌអនុបាតភាពគ្រប់គ្រាន់នៃដើមទុនថ្មី ឬក្របខ័ណ្ឌអនុបាតសាធនភាព។ ក្នុងករណី៖

- ស្ថាប័នជ្រើសរើសអនុវត្តក្របខ័ណ្ឌអនុបាតភាពគ្រប់គ្រាន់នៃដើមទុនថ្មី ស្ថាប័នត្រូវចាប់ផ្តើមអនុវត្តក្របខ័ណ្ឌថ្មីនេះ ដែលមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទនៃប្រកាសស្តីពី អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ចំពោះទម្រង់របាយការណ៍ថ្មី ស្ថាប័នត្រូវបញ្ជូនរបាយការណ៍ប្រចាំខែ លើមូលដ្ឋានឯកត្ត ជូនធនាគារជាតិនៃកម្ពុជា មិនឱ្យយឺតជាងថ្ងៃទី20 នៃខែបន្ទាប់ ចំណែករបាយការណ៍ប្រចាំត្រីមាស លើមូលដ្ឋានរួមបញ្ចូល (ប្រសិនបើមាន) មិនឱ្យយឺតជាងថ្ងៃទី20 នៃខែទីមួយ នៃត្រីមាសបន្ទាប់ រហូតដល់មានការជូនដំណឹង។

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ច. ការគ្រប់គ្រងដើមទុន (ត)

(ii) ការគ្រប់គ្រងហានិភ័យមូលធន (ត)

- ស្ថាប័នជ្រើសរើសអនុវត្តអនុបាតសាធនភាពតាមទម្រង់ចាស់ ស្ថាប័នត្រូវគោរពតាមលក្ខខណ្ឌទាំងអស់នៃក្របខ័ណ្ឌ និងទម្រង់របាយការណ៍ចាស់។ ក្នុងពេលដំណាលគ្នានេះ ស្ថាប័នត្រូវរៀបចំរបាយការណ៍តាមក្របខ័ណ្ឌអនុបាតភាពគ្រប់គ្រាន់នៃដើមទុនថ្មី(ទម្រង់ថ្មី) និងបញ្ជូនបាយការណ៍ជូនធនាគារជាតិនៃកម្ពុជា រួមជាមួយនឹងរបាយការណ៍អនុបាតសាធនភាព (ទម្រង់ចាស់)។

តារាងខាងក្រោមសង្ខេបសមាសភាពនៃដើមទុនបទប្បញ្ញត្តិ៖

	ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025		ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ 3)
ដើមទុនថ្នាក់ទី1				
ដើមទុន	275,895,100	1,103,580,400	275,895,100	1,103,580,400
ប្រាក់ចំណេញរក្សាទុក	132,183,582	530,452,715	150,075,395	604,053,465
ប្រាក់ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុចុងក្រោយដែលបានរងសវនកម្ម	(5,631,119)	(22,586,417)	(2,956,665)	(12,036,582)
សរុបរង-ក	402,447,563	1,611,446,698	423,013,830	1,695,597,283
ដក៖ ទ្រព្យសកម្មអរូបី	(5,372,701)	(21,560,649)	(6,501,491)	(26,168,501)
ដក៖ ឥណទានផ្តល់ដល់សម្ព័ន្ធញាតិ	(57,649)	(231,345)	(33,258)	(133,863)
	397,017,213	1,589,654,704	416,479,081	1,669,294,919
ដើមទុនបន្ថែមថ្នាក់ទី2				
សំវិធានធនទូទៅ	8,666,669	34,779,343	11,293,200	45,455,130
សំវិធានធនសម្រាប់ការប្រាក់បង្គរត្រូវទទួល (*)	-	-	2,179,920	8,774,178
ដក៖ មូលធនដែលដាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា	(15,353)	(61,612)	(15,353)	(61,796)
	8,651,316	34,717,731	13,457,767	54,167,512
សរុប	405,668,529	1,624,372,435	429,936,848	1,723,462,431

31. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

ច. ការគ្រប់គ្រងដើមទុន (ត)

(iii). ការបែងចែកដើមទុន

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់ គឺត្រូវបានគ្រប់គ្រងដោយកម្រិតភាគលាភដែលទទួលបានពីការបែងចែកនោះ។ ដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាពនីមួយៗ ត្រូវផ្អែកទៅតាមដើមទុនដែលកំណត់ដោយច្បាប់។

32. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុរួមមានទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការ។ តម្លៃសមស្រប គឺជាថ្លៃដែលត្រូវទទួលដើម្បីលក់ទ្រព្យសកម្ម ឬបានទូទាត់ ដើម្បីផ្ទេរបំណុលទៅតាមលំដាប់លំដោយនៅក្នុងប្រតិបត្តិការ រវាងអ្នកចូលរួមក្នុងទីផ្សារនៅកាលបរិច្ឆេទនៃការវាស់វែងចម្បង ឬប្រសិនអវត្តមានទីផ្សារដែលមានការរីកចម្រើនបំផុតដែលធនាគារបានទទួលនៅកាលបរិច្ឆេទនោះ។ ព័ត៌មានដែលបានបង្ហាញនៅទីនេះ តំណាងឱ្យការប៉ាន់ស្មាននៃតម្លៃសមស្របនាកាលបរិច្ឆេទរាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុ។

តម្លៃទីផ្សារដែលបានដកស្រង់ និងអាចអង្កេតបាន ហើយអាចរកបាន ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងលើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ។ នៅពេលដែលតម្លៃទីផ្សារដែលបានដកស្រង់ និងអាចសង្កេតបាន មិនអាចប្រើប្រាស់បាននោះ តម្លៃសមស្របត្រូវបានប៉ាន់ស្មានដោយផ្អែកលើវិធីសាស្ត្រ និងការសន្មតជាច្រើនទាក់ទងទៅនឹងលក្ខណៈហានិភ័យនៃឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ ដែលមានអត្រាអប្បហារ ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់នាពេលអនាគត និងកត្តាផ្សេងៗទៀត។

ព័ត៌មាននៃតម្លៃសមស្របសម្រាប់ទ្រព្យសកម្ម និងបំណុលមិនមែនហិរញ្ញវត្ថុ មិនត្រូវបានរាប់បញ្ចូលទេ ពីព្រោះវាមិនស្ថិតក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក 7៖ *ការលាតត្រដាងព័ត៌មានអំពីឧបករណ៍ហិរញ្ញវត្ថុ* ដែលតម្រូវឱ្យមានការបង្ហាញព័ត៌មាននៃតម្លៃសមស្រប។ នេះរួមបញ្ចូលទាំងការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ និងទ្រព្យ និងបរិក្ខារ។

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានដូចជាសាច់ប្រាក់ និងមូលនិធិរយៈពេលខ្លី សមតុល្យនៅធនាគារជាតិ និងប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា ទ្រព្យសកម្មផ្សេងៗ បំណុលផ្សេងៗ និងប្រាក់កម្ចីរយៈពេលខ្លីមិនមានលក្ខណៈជាសារវន្ត ចំពោះការផ្លាស់ប្តូរអត្រាប្រាក់ចំណេញក្នុងទីផ្សារ ដោយសារតែឧបករណ៍ហិរញ្ញវត្ថុទាំងនេះមានរយៈពេលកំណត់ជាក់លាក់។ តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុទាំងនេះ នៅកាលបរិច្ឆេទរាយការណ៍មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា។

32. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ (ត)

វិធីសាស្ត្រ និងការសន្មត ដែលបានប្រើប្រាស់ដោយធនាគារក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុគឺ៖

ក. សាច់ប្រាក់ក្នុងដៃ និងប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា ធនាគារនានា និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

តម្លៃសមស្របនៃសាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា ធនាគារនានា និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ជាមួយធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត គឺមានតម្លៃប្រហាក់ប្រហែលនឹងសមតុល្យដុលរបស់វា ដោយសាររយៈពេលខ្លីនៃគណនីទាំងនេះ។

ខ. ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន

តម្លៃសមស្របនៃឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន គឺផ្អែកលើប្រតិបត្តិការទីផ្សារដែលអាចអង្កេតបាន។ នៅពេលដែលមិនមានប្រតិបត្តិការទីផ្សារដែលអាចកត់សម្គាល់បាន តម្លៃប៉ាន់ស្មានត្រូវបានប៉ាន់ប្រមាណដោយប្រើ ម៉ូឌែលវាយតម្លៃ ដូចជាវិធីសាស្ត្រអប្បហារលំហូរសាច់ប្រាក់។ ធាតុចូលដែលយកមក ប្រើប្រាស់នៅក្នុងវិធីសាស្ត្រវាយតម្លៃរួមមាន ការខាតបង់លើឥណទានពេញមួយអាយុកាលដែលបានរំពឹងទុក អត្រាការប្រាក់ អត្រាប្រាក់បង់មុន ទីផ្សារគោល និងទីផ្សារបន្ទាប់បន្សំ។

ការបញ្ចូលទៅក្នុងម៉ូឌែលអាចរួមបញ្ចូលទាំងធាតុចូលពីភាគីទីបី និងព័ត៌មានដែលទទួលបានពីអ្នកចូលរួមពីទីផ្សារផ្សេងៗ ដែលរួមបញ្ចូលទាំងធាតុចូលដំបូង និងបន្ទាប់នៃប្រតិបត្តិការដែលបានអង្កេត។ តម្លៃយោងរបស់វាប្រហាក់ប្រហែលទៅនឹងតម្លៃសមស្របនាកាលបរិច្ឆេទរាយការណ៍។

គ. ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

តម្លៃសមស្របនៃប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ដែលមានកាលវសានតិចជាង 1ឆ្នាំ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា ដោយសារប្រាក់បញ្ញើទាំងនេះមានរយៈពេលខ្លី។ តម្លៃសមស្របនៃប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ដែលមានកាលវសានលើសពី 1ឆ្នាំ ត្រូវបានគេរំពឹងថា មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា ដោយសារធនាគារបានផ្តល់អត្រាការប្រាក់ប្រហាក់ប្រហែលគ្នា ទៅនឹងឧបករណ៍ដែលមានកាលវសាន និងលក្ខខណ្ឌស្រដៀងគ្នាដែរ។

តម្លៃសមស្របដែលបានប៉ាន់ស្មាននៃប្រាក់បញ្ញើដែលគ្មានកាលកំណត់ រាប់ទាំងគណនីចរន្តដែលគ្មានការប្រាក់ និងប្រាក់បញ្ញើសន្សំ គឺជាចំនួនទឹកប្រាក់ដែលត្រូវសងនាកាលបរិច្ឆេទរាយការណ៍។

32. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ (ត)

ឃ. ប្រាក់កម្ចី និងបំណុលភតិសន្យា

តម្លៃសមស្របនៃប្រាក់កម្ចី និងបំណុលភតិសន្យាត្រូវបានប៉ាន់ស្មានដោយការធ្វើអប្បហារលំហូរសាច់ប្រាក់នាពេលអនាគតដែលបានរំពឹងទុក ដោយប្រើអត្រាការប្រាក់ទីផ្សារទូទៅ ចំពោះប្រាក់កម្ចីដែលមានលក្ខណៈហានិភ័យប្រហាក់ប្រហែលគ្នា។ យ៉ាងណាមិញ នាកាលបរិច្ឆេទរាយការណ៍ មានតែអត្រាការប្រាក់ដែលបានចុះកិច្ចសន្យាហើយត្រូវបានបញ្ជាក់ និងផ្តល់ដោយម្ចាស់បំណុលតែប៉ុណ្ណោះ ដែលអាចរកបាន ជំនួសឱ្យអត្រាការប្រាក់ទីផ្សារទូទៅ។ ធនាគារ ជឿជាក់ថាអត្រាការប្រាក់ដែលបានចុះកិច្ចសន្យា មិនមានភាពខុសគ្នាជាសារវន្តពីអត្រាការប្រាក់ទីផ្សារទូទៅនោះឡើយ ដោយសំអាងថា មិនមានការកែប្រែលើអត្រាការប្រាក់នោះទេ ដោយយោងតាមការពិចារណារបស់ម្ចាស់ប្រាក់កម្ចី មកលើហានិភ័យឥណទានរបស់ធនាគារ នាកាលបរិច្ឆេទរាយការណ៍។ អាស្រ័យហេតុនេះ តម្លៃសមស្របរបស់ប្រាក់កម្ចី មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វានាកាលបរិច្ឆេទរាយការណ៍។

ង. ទ្រព្យសកម្មផ្សេងៗ និងបំណុលផ្សេងៗ

តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានសន្មតថាមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា ដោយសារគណនីទាំងនេះមិនមានតម្លៃប្រែប្រួលជាសារវន្តទៅតាមអត្រាការប្រាក់ទីផ្សារទេ ហើយវាមានកាលវិសានខ្លី។

ហានានុក្រមតម្លៃសមស្រប

ស.រ.ហ.អ.ក 7 បញ្ជាក់ពីចំណាត់ថ្នាក់នៃបច្ចេកទេសវាយតម្លៃដោយផ្អែកលើ ថាតើទិន្នន័យនៃបច្ចេកទេសវាយតម្លៃទាំងនោះអាចអង្កេតបាន ឬមិនអាចអង្កេតបាន។ ទិន្នន័យដែលអាចអង្កេតបាន ឆ្លុះបញ្ចាំងពីទិន្នន័យទីផ្សារដែលទទួលបានពីប្រភពឯករាជ្យ និងទិន្នន័យដែលមិនអាចអង្កេតបាន ឆ្លុះបញ្ចាំងពីការសន្មតទីផ្សាររបស់ធនាគារ។ ចំណាត់ថ្នាក់នៃតម្លៃសមស្របមានដូចខាងក្រោម៖

- កម្រិត 1 - តម្លៃដកស្រង់ (មិនបានធ្វើនិយ័តភាព) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា។ កម្រិតនេះរាប់បញ្ចូលទាំងមូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជី និងឧបករណ៍បំណុល។
- កម្រិត 2 - ទិន្នន័យក្រៅពីតម្លៃដែលបានដកស្រង់រាប់បញ្ចូលក្នុងកម្រិត 1 ដែលអាចអង្កេតបានចំពោះទ្រព្យសកម្ម ឬបំណុល ដោយផ្ទាល់ (ឧទាហរណ៍ តម្លៃ) ឬដោយប្រយោល (ឧទាហរណ៍ កើតចេញពីតម្លៃ)។
- កម្រិត 3 - ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន (ធាតុចូលដែលមិនអាចអង្កេតបាន)។ កម្រិតនេះរួមបញ្ចូលទាំងឧបករណ៍មូលធន និងឧបករណ៍បំណុលដែលមានសមាសធាតុមិនអាចអង្កេតបានជាសារវន្ត។

32. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ (ត)

ង. ទ្រព្យសកម្មផ្សេងៗ និងបំណុលផ្សេងៗ (ត)

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់ធនាគារ មិនត្រូវបានវាស់វែងតាមតម្លៃសមស្របនោះទេ។ ដោយសារតម្លៃសមស្របពុំអាចវាយតម្លៃបាន ដូច្នេះតម្លៃសមស្របមិនមានសម្រាប់ទ្រព្យសកម្ម និងបំណុលមួយចំណែកធំរបស់ធនាគារឡើយ។ ដូច្នេះហើយ តម្លៃសមស្រប ត្រូវបានសន្មតដោយគណៈគ្រប់គ្រងយោងតាមទម្រង់នៃទ្រព្យសកម្ម និងបំណុលទាំងនោះ។ តាមមតិរបស់គណៈគ្រប់គ្រង តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលបង្ហាញក្នុងតារាងតុល្យការ គឺជាតម្លៃប៉ាន់ស្មានដ៏សមហេតុផលសម្រាប់តម្លៃសមស្រប។

33. គោលនយោបាយគណនេយ្យសារវន្ត

គោលនយោបាយគណនេយ្យសារវន្ត ដែលបានបង្ហាញនៅខាងក្រោមនេះ ត្រូវបានអនុវត្តដោយសង្គតិភាពនៅគ្រប់កាលបរិច្ឆេទដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ លើកលែងតែមានការបង្ហាញផ្សេងពីនេះ។ តម្រូវការថ្មីដែលកំពុងមានប្រសិទ្ធិភាពនាពេលបច្ចុប្បន្ន ពុំមានឥទ្ធិពលសំខាន់ទៅលើរបាយការណ៍ហិរញ្ញវត្ថុនៃធនាគារទេ។

ក. មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើមដំបូង លើកលែងតែមានការលើកឡើងផ្សេងពីនេះ។

ខ. រូបិយប័ណ្ណបរទេស

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណ ត្រូវបានប្តូរទៅជារូបិយប័ណ្ណមុខងារ ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។

ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុ ដែលជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជារូបិយប័ណ្ណមុខងារដោយប្រើអត្រាប្តូរប្រាក់ នាកាលបរិច្ឆេទរាយការណ៍។ ចំណេញ ឬខាតបង់ពីការប្តូររូបិយប័ណ្ណបរទេស គឺជាភាពខុសគ្នារវាងថ្លៃដើមដែលត្រូវបានរំលស់ជារូបិយប័ណ្ណមុខងារនៅដើមឆ្នាំ ដែលត្រូវបានធ្វើនិយ័តកម្មសម្រាប់ឱនភាពតម្លៃការប្រាក់ និងការទូទាត់មានប្រសិទ្ធភាពក្នុងឆ្នាំ ហើយនិងថ្លៃរំលស់ជារូបិយប័ណ្ណបរទេសដែលបានប្តូរដោយប្រើអត្រាប្តូរប្រាក់ភ្លាមៗនៅចុងការិយបរិច្ឆេទ។

ទ្រព្យសកម្ម និងបំណុលដែលមិនមែនជារូបិយវត្ថុ ដែលត្រូវបានវាស់វែងតាមតម្លៃសមរម្យជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជារូបិយប័ណ្ណមុខងារនៅអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទដែលតម្លៃត្រូវបានកំណត់។ ធាតុមិនមែនជារូបិយវត្ថុដែលត្រូវបានវាស់វែងផ្អែកលើតម្លៃប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

(i). *ការទទួលស្គាល់ និងការវាស់វែងដំបូង*

ធនាគារទទួលស្គាល់ជាលើកដំបូងនូវឥណទាន និងបុរេប្រទាន ការវិនិយោគ និងប្រាក់កម្ចី នៅកាលបរិច្ឆេទដែលកើតមានប្រតិបត្តិការ។ ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទ ដែលធនាគារក្លាយជាភាគីកិច្ចសន្យា។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប (សម្រាប់ឧបករណ៍ដែលមិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL")) បូកនឹងថ្លៃដើមប្រតិបត្តិការ ដែលកើតមកពីការទិញ ឬលក់ ទ្រព្យ និងបំណុលទាំងនោះ។ តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុនៅពេលទទួលស្គាល់ដំបូង ជាទូទៅគឺជាថ្លៃប្រតិបត្តិការ។

(ii). *ការចាត់ចំណាត់ថ្នាក់*

ទ្រព្យសកម្មហិរញ្ញវត្ថុ

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែងរំលស់ថ្លៃដើម FVOCI ឬ FVTPL។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើវាបំពេញទៅនឹងលក្ខខណ្ឌដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្ម ដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរទឹកប្រាក់ សម្រាប់ទូទាត់ប្រាក់ដើម និងការប្រាក់ ("SPPI")។

ឧបករណ៍បំណុល ត្រូវបានវាស់វែងនៅ FVOCI លុះត្រាតែវាបានបំពេញនឹងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលផ្តល់នូវកាលបរិច្ឆេទជាក់លាក់ ចំពោះលំហូរសាច់ប្រាក់សម្រាប់ទូទាត់ប្រាក់ដើម និងការប្រាក់ ("SPPI")។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii). ការចាត់ចំណាត់ថ្នាក់ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

សម្រាប់ការទទួលស្គាល់ការវិនិយោគលើមូលធនជាលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរ ធនាគារត្រូវតែជ្រើសរើសការបង្ហាញ ការប្រែប្រួលនាពេលបន្ទាប់តាមរយៈលទ្ធផលលម្អិតផ្សេងៗ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកលើការវិនិយោគនីមួយៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងៗទៀត ត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL។

លើសពីនេះ សម្រាប់ការទទួលស្គាល់ជាលើកដំបូង ធនាគារអាចនឹងកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមរំលស់ថ្លៃដើម ឬតាម FVOCI ប្រសិនបើវាស់វែងតាម FVTPL នឹងលុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតឡើង។

ការវាយតម្លៃគំរូអាជីវកម្ម

ធនាគារ ធ្វើការវាយតម្លៃអំពីគោលបំណងនៃគំរូអាជីវកម្ម លើទ្រព្យសកម្មក្នុងកម្រិតសំណុំឥណទាននីមួយៗ ព្រោះគំរូនេះបង្ហាញយ៉ាងច្បាស់ពីវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មានទៅគណៈគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់សំណុំឥណទាន និងអនុវត្តនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឱ្យស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនឹងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឱ្យមានលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម។
- វិធីសាស្ត្រក្នុងការវាយតម្លៃលទ្ធផលនៃសំណុំឥណទាន និងវិធីរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ធនាគារ
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលនៃគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលគណៈគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់សំណងផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់នោះ និងការរំពឹងទុកអំពីសកម្មភាពលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានចាត់ទុកថាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទូទៅ អំពីរបៀបដែលធ្វើឱ្យសម្រេចបាននូវគោលបំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii). ការចាត់ចំណាត់ថ្នាក់ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ការវាយតម្លៃគ្មិវអាជីវកម្ម (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់ការជួញដូរ ឬចាត់ចែង ហើយដែលលទ្ធផលត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនសម្រាប់ទាំងការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ឡើយ។

ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" គឺជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ជាលើកដំបូង។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ការចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសន្ទនីយភាព និងចំណាយរដ្ឋបាល)រួមទាំងប្រាក់ចំណេញ។

ដើម្បីវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ ធនាគារ ត្រូវពិចារណាលើលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ។ ដោយរួមបញ្ចូលការវាយតម្លៃថាតើ ទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលអាចធ្វើឱ្យខុសពីលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់។

ក្នុងការវាយតម្លៃ ធនាគារពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាភាពដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេលនៃលំហូរសាច់ប្រាក់
- លក្ខខណ្ឌពិសេស
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យារពេលសង
- លក្ខខណ្ឌដែលកម្រិតធនាគារ ក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជាឥណទានដែលមិនអាចប្រមូលមកវិញបាន) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីតម្លៃពេលវេលានៃសាច់ប្រាក់ (ឧទាហរណ៍ ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់)។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii). ការចាត់ចំណាត់ថ្នាក់ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ឥណទានដែលមិនអាចប្រមូលមកវិញបាន

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយធនាគារ ដែលត្រូវបានការពារដោយទ្រព្យដាក់ធានារបស់អតិថិជន ក៏មានកំហិតដល់ធនាគារក្នុងការទាមទារសាច់ប្រាក់មកវិញដែរ (ឥណទានដែលមិនអាចប្រមូលមកវិញបាន)។ ក្នុងករណីនេះ ធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទាននោះអាចប្រមូលមកវិញដែរឬទេ។ ជាទូទៅ ធនាគារពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃការបង់សងកម្ចីដែរ ឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា
- សមត្ថភាព និងឆន្ទៈរបស់អតិថិជន ក្នុងការទូទាត់សងតាមកិច្ចសន្យា ទោះបីមានឱនភាពនៃតម្លៃលើទ្រព្យបញ្ចាំក៏ដោយ
- ថាតើអតិថិជនគឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់ធនាគារទៅលើការបាត់បង់ទ្រព្យសកម្ម ទាក់ទងនឹងឥណទានដែលមិនអាចប្រមូលមកវិញបាន
- ថាតើទ្រព្យដាក់ធានាគឺជាទ្រព្យទាំងអស់ដែលអតិថិជនមាន ឬគ្រាន់តែជាផ្នែកមួយនៃទ្រព្យសកម្មផ្សេងៗទៀតរបស់អតិថិជន និង
- ថាតើធនាគារទទួលបានអត្ថប្រយោជន៍ពីទ្រព្យសកម្មនេះ ឬទេ។

ការចាត់ចំណាត់ថ្នាក់ឡើងវិញ

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែងតែក្នុងអំឡុងពេលដែលធនាគារផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

(iii). ការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យទាំងអស់ និងភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាកម្មសិទ្ធិ ហើយវាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(iii). ការឈប់ទទួលស្គាល់ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ចំពោះការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i) តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលទទួលយក) និង (ii) ចំណេញ ឬខាតដែលបានទទួលស្គាល់ក្នុង OCI ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

បំណុលហិរញ្ញវត្ថុ

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតអាណត្តិ។

(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះធនាគារវាយតម្លៃថាតើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះ មានភាពខុសគ្នាខ្លាំង ឬទេ។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម ហិរញ្ញវត្ថុដើមត្រូវបានចាត់ទុកថាផុតអាណត្តិ។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវឈប់ទទួលស្គាល់ (សូមមើល(iii)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្របបូកនឹងថ្លៃចំណាយប្រតិបត្តិការ។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានរាប់បញ្ចូលដូចខាងក្រោម៖

- ថ្លៃសេវាដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលទទួលបានមករិញលើថ្លៃចំណាយប្រតិបត្តិការដែលកើតឡើង ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និង
- ថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ចំណេញ ឬខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើទ្រព្យសកម្មដែលឈប់ទទួលស្គាល់។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(v). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជូបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមាលើលក្ខខណ្ឌនៃកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើធនាគារ មានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឱ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ ទ្រព្យសកម្មនោះ ត្រូវបានយកមកពិចារណាជាមុន ថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជីមុនពេលធ្វើការកែប្រែ ឬទេ (សូមមើលខាងក្រោមសម្រាប់គោលនយោបាយ ការលុបចេញពីបញ្ជី)។ វិធីសាស្ត្រនេះ បានជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណ ហើយក្នុងករណីនេះមានន័យថា លក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ទ្រព្យ ជាទូទៅមិនអាចអនុវត្តបាននោះទេ។

ប្រសិនបើការកែតម្រូវទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ឬ FVOCI មិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេនោះ នោះធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវក្នុងចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាអថេរអត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបានដែលជាផ្នែកមួយនៃការកែតម្រូវទាក់ទងនឹងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានធ្វើការកែតម្រូវត្រូវបានរំលស់ផ្នែកលើរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវនោះ។

ប្រសិនបើការកែតម្រូវនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជូបការលំបាកផ្នែកហិរញ្ញវត្ថុ នោះចំណេញឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពតម្លៃនៃទ្រព្យសកម្ម។ ក្នុងករណីផ្សេងទៀតត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

បំណុលហិរញ្ញវត្ថុ

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវ ហើយលំហូរសាច់ប្រាក់នៃបំណុលដែលបានកែតម្រូវនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលមិនត្រូវបានទទួលស្គាល់និងតម្លៃតបស្នង ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ តម្លៃតបស្នងរួមមាន ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុលរួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ង). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

បំណុលហិរញ្ញវត្ថុ (ត)

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះ មិនធ្វើឱ្យមានការឈប់ទទួលស្គាល់ទេ នោះរំលស់ថ្លៃដើមនៃបំណុលត្រូវគណនាឡើងវិញដោយធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃការចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមាន ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុ ដែលបានកែតម្រូវដោយគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ។

(ច). ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែធនាគារមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

(ឆ). ការវាស់វែងតម្លៃសមស្រប

'តម្លៃសមស្រប' គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតារវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារដែលមានជាអាទិភាពបំផុត ដែលធនាគារអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុលឆ្លុះបញ្ចាំងពីហានិភ័យការមិនអនុវត្តកាតព្វកិច្ច។

ធនាគារវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុលកើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះធនាគារត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ហ). ការវាស់វែងតម្លៃសមស្រប (ត)

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឱ្យ ឬបានទទួល។ ប្រសិនបើធនាគារកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្ម ចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះទិន្នន័យដែលមិនអាចអង្កេតបានពាក់ព័ន្ធនឹងការវាស់វែង ត្រូវបានសន្មតថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្របដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នា រវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឱ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

ប្រសិនបើទ្រព្យសកម្ម ឬបំណុលដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប មានតម្លៃលក់ និងតម្លៃទិញនោះ ធនាគារវាស់វែងទ្រព្យសកម្ម និងស្ថានភាពវែងតាមតម្លៃលក់ ហើយវាស់វែងបំណុល និងស្ថានភាពខ្លីតាមតម្លៃទិញ។

សំណុំទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមានហានិភ័យទីផ្សារ និងហានិភ័យឥណទាន ដែលត្រូវបានចាត់ចែងដោយធនាគារ តាមមូលដ្ឋានចំនួនសុទ្ធដែលមានហានិភ័យទីផ្សារ ឬហានិភ័យឥណទានត្រូវបានវាស់វែងតាមមូលដ្ឋាននៃតម្លៃ ដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្មដែលមានអាយុកាលវែង (ឬការទូទាត់សងក្នុងការផ្ទេរទ្រព្យសកម្មសុទ្ធដែលមានអាយុកាលខ្លី) សម្រាប់ហានិភ័យជាក់លាក់។ ការកែតម្រូវត្រឹមកម្រិតទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ មានន័យថា ការកែតម្រូវតម្លៃលក់-ទិញ ឬការកែតម្រូវហានិភ័យឥណទាន ដែលឆ្លុះបញ្ចាំងពីការវាស់វែងតាមមូលដ្ឋានតម្លៃសុទ្ធ គឺត្រូវបានបែងចែកតាមទ្រព្យសកម្ម និងបំណុលនីមួយៗ តាមមូលដ្ឋានការកែតម្រូវហានិភ័យដែលពាក់ព័ន្ធ នៃឧបករណ៍ហិរញ្ញវត្ថុនីមួយៗ នៃទ្រព្យសកម្ម និងបំណុលនោះ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់។

ធនាគារទទួលស្គាល់ការផ្ទេររវាងកម្រិតនៃហានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ

ធនាគារទទួលស្គាល់សំវិធានធនលើការខាតបង់ឥណទានរំពឹងទុក ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាឧបករណ៍បំណុល
- កិច្ចសន្យាធានាហិរញ្ញវត្ថុដែលបានបោះផ្សាយ និង
- កិច្ចសន្យាឥណទានដែលបានបោះផ្សាយ។

ពុំមានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងការវិនិយោគមូលធនឡើយ។

ធនាគារ វាស់វែងសំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹងការរំពឹងទុកលើការខាតបង់ឥណទានពេញមួយអាយុកាល លើកលែងគណនីខាងក្រោម ដែលត្រូវវាស់វែងតាមការរំពឹងទុកលើការខាតបង់ឥណទានរយៈពេល 12ខែ៖

- ការវិនិយោគលើមូលបត្របំណុលដោយមានការធានា ត្រូវបានកំណត់ថាមានហានិភ័យឥណទានទាបនាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីភតិសន្យាត្រូវទទួល) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។

ធនាគារ ចាត់ទុកការវិនិយោគមូលបត្របំណុលថាមានហានិភ័យឥណទានទាប នៅពេលដែលចំណាត់ថ្នាក់ហានិភ័យឥណទានស្មើនឹងនិយមន័យជាសកលនៃ "ចំណាត់ថ្នាក់វិនិយោគ"។ ធនាគារមិនអនុវត្ត លើការលើកលែងហានិភ័យឥណទានទាបចំពោះឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតទេ។

ការរំពឹងទុកលើការខាតបង់ឥណទាន 12ខែ គឺជាផ្នែកនៃការរំពឹងទុកលើការខាតបង់ឥណទាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល 12ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាមការរំពឹងទុកលើការខាតបង់ឥណទាន 12ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី1"។

ការរំពឹងទុកលើការខាតបង់ឥណទានពេញមួយអាយុកាល គឺជាការរំពឹងទុកលើការខាតបង់ឥណទាន ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេលនៃអាយុកាលរំពឹងទុក នៃឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុ ដែលបានទទួលស្គាល់តាមការរំពឹងទុកលើការខាតបង់ឥណទានពេញមួយអាយុកាល ប៉ុន្តែមិនមែនជាឥណទានដែលមានឱនភាពនៃតម្លៃ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី2"។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារវាយតម្លៃថាតើហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬទេ។ នៅពេលដែលហានិភ័យឥណទានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការបាត់បង់ត្រូវបានវាស់វែង តាមតម្លៃស្មើនឹងអាយុកាលនៃការរំពឹងទុកលើការខាតបង់ឥណទាន។

នៅពេលកំណត់ថាតើហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង និងនៅពេលប៉ាន់ស្មានលើការរំពឹងទុកលើការខាតបង់ឥណទាន នោះធនាគារពិចារណាលើព័ត៌មានដែលសមហេតុសមផល និងព័ត៌មានគាំទ្រដែលពាក់ព័ន្ធ និងអាចរកបានដោយមិនចាំបាច់ចំណាយ ឬប្រឹងប្រែងខ្ពស់។ ព័ត៌មានទាំងនេះរួមបញ្ចូលព័ត៌មានបរិមាណ និងព័ត៌មានគុណភាព និងការវិភាគ ដោយផ្អែកលើបទពិសោធន៍របស់ធនាគារ និងការវាយតម្លៃឥណទាន ព្រមទាំងបញ្ចូលព័ត៌មានប្រមើលមើលអនាគត។

ប្រសិនបើហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬប្រសិនបើគុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុមានភាពប្រសើរឡើង ដែលបណ្តាលឱ្យគ្មានការកើនឡើងជាសារវន្តនៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការបាត់បង់ត្រូវបានវាស់វែងតាមតម្លៃស្មើនឹងការរំពឹងទុកលើការខាតបង់ឥណទាន 12ខែ។

រយៈពេលអតិបរមាដែលត្រូវយកមកពិចារណា ពេលធ្វើការប៉ាន់ស្មានលើការរំពឹងទុកលើការខាតបង់ឥណទាន គឺជារយៈពេលកិច្ចសន្យាអតិបរមាដែលធនាគារប្រឈមនឹងហានិភ័យឥណទាន។

ការកំណត់នៃការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន

ធនាគារវាយតម្លៃថាតើមានហានិភ័យឥណទានបានកើនឡើងជាសារវន្ត ឬទេ ចាប់តាំងពីការទទួលស្គាល់លើកដំបូង នៅកាលបរិច្ឆេទរាយការណ៍។ ការកំណត់ពីការកើនឡើងនៃហានិភ័យឥណទានផ្អែកជាសំខាន់លើចរិតលក្ខណៈនៃឧបករណ៍ហិរញ្ញវត្ថុ និងអតិថិជន និងតំបន់ភូមិសាស្ត្រ។

ធនាគារពិចារណាថាការកើនឡើងនៃហានិភ័យឥណទានជាសារវន្ត កើតឡើងនៅពេលទ្រព្យសកម្មមានការខកខានសងមិនតិចជាងរយៈពេលចំនួន 30ថ្ងៃសម្រាប់ហ្វាស៊ីលីធីរយៈពេលវែង និងច្រើនជាង ឬស្មើ 15ថ្ងៃសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី។ ចំនួនថ្ងៃខកខានសងត្រូវបានកំណត់ដោយការរាប់ចំនួនថ្ងៃ ចាប់តាំងពីកាលបរិច្ឆេទផុតកំណត់ដំបូងបង្អស់ ដែលការបង់សងទាំងអស់មិនទាន់បានទទួល។

ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មិនមានការកើនឡើងលើហានិភ័យឥណទានជាសារវន្ត ទាក់ទងនឹងការទទួលស្គាល់លើកដំបូងទេនោះ សំវិធានធននៃការបាត់បង់លើឧបករណ៍ហិរញ្ញវត្ថុនឹងត្រូវវាស់វែងតាមការរំពឹងទុកលើការខាតបង់ឥណទាន 12ខែ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ឃ). ឱនភាពនៃតម្លៃ (ត)

និយមន័យនៃការខកខានសង

ធនាគារចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុង ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- អ្នកខ្ចីបានហួសកាលកំណត់សងស្មើ ឬលើសពី 90ថ្ងៃ សម្រាប់ហ្វាស៊ីលីធីរយៈពេលវែង ឬច្រើនជាង ឬស្មើ 31ថ្ងៃ សម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី ទៅលើកាតព្វកិច្ចហ្វាស៊ីលីធីចំពោះធនាគារ ឬ
- វាមានភាពច្បាស់លាស់ដែលថាអ្នកខ្ចី នឹងរៀបចំទ្រព្យសកម្មឡើងវិញក្រោយពីក្ស័យធនដោយសារអ្នកខ្ចីពុំមានលទ្ធភាពសងកាតព្វកិច្ចឥណទានបាន។

ការវាស់វែងលើការពឹងទុកលើការខាតបង់ឥណទាន

ការពឹងទុកលើការខាតបង់ឥណទាន គឺជាការប៉ាន់ស្មានប្រូបាប៊ីលីតេមធ្យមនៃការបាត់បង់ឥណទាន។ ការពឹងទុកលើការខាតបង់ឥណទាន ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ពោលគឺ ភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលជំពាក់ធនាគារស្របតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលធនាគារពឹងទុកថានឹងទទួលបាន)
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងទុកនាពេលអនាគត
- កិច្ចសន្យាឥណទានដែលនៅសល់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នា រវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជំពាក់ធនាគារ ប្រសិនបើអ្នកកាន់កាប់កិច្ចសន្យាឥណទានបានដកឥណទានប្រើ និងលំហូរសាច់ប្រាក់ដែលធនាគារពឹងទុកថានឹងទទួលបាន និង
- កិច្ចសន្យាធានាវ៉ាប់រងហិរញ្ញវត្ថុ៖ ការចំណាយដែលរំពឹងទុកដើម្បីសងម្ចាស់កម្មសិទ្ធិដកនឹងចំនួនទឹកប្រាក់ដែលធនាគារពឹងថានឹងទទួលបានមកវិញ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ឃ). ឱនភាពនៃតម្លៃ (ត)

ការវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន (ត)

នៅពេលធ្វើអប្បហារលំហូរសាច់ប្រាក់នាពេលអនាគត អត្រាអប្បហារខាងក្រោមត្រូវបានប្រើប្រាស់៖

- ទ្រព្យសកម្មហិរញ្ញវត្ថុក្រៅពីការទិញ ឬថយចុះខ្សោយឥណទានទ្រព្យសកម្មហិរញ្ញវត្ថុ និងភតិសន្យាដែលត្រូវទទួល៖ អត្រាការប្រាក់ប្រសិទ្ធភាពដើម ឬប្រហាក់ប្រហែល
- ការទិញ ឬថយចុះខ្សោយឥណទានទ្រព្យសកម្ម៖ អត្រាការប្រាក់ប្រសិទ្ធភាពកែតម្រូវឥណទាន
- ភតិសន្យាត្រូវទទួល ៖ អត្រាអប្បហារប្រើប្រាស់ក្នុងការវាស់វែងភតិសន្យាត្រូវទទួល
- កិច្ចសន្យាឥណទានដែលនៅសល់៖ អត្រាការប្រាក់ប្រសិទ្ធភាព ឬប្រហាក់ប្រហែលនឹងត្រូវអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលជាលទ្ធផលមកពីកិច្ចសន្យាឥណទាន និង
- កិច្ចសន្យាធានារ៉ាប់រងហិរញ្ញវត្ថុបានបោះផ្សាយ៖ អត្រាដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃនៃពេលវេលា និងហានិភ័យដែលជាក់លាក់ចំពោះលំហូរសាច់ប្រាក់។

ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ

សមាសធាតុសំខាន់ៗ ក្នុងការវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន គឺបានមកពីអថេរដូចខាងក្រោម៖

- លទ្ធភាពនៃការខកខានសង (“PD”)
- ការបាត់បង់ដែលបណ្តាលមកពីការខកខានសង (“LGD”) និង
- ទំហំនៃការខកខានសង (“EAD”)

ECL សម្រាប់សមតុល្យក្នុងដំណាក់កាលទី1 ត្រូវបានគណនាដោយផលគុណនៃ PD 12ខែ នឹង LGD នឹង EAD ។ ECL ពេញអាយុកាល ត្រូវបានគណនាដោយផលគុណនៃ PD ពេញអាយុកាល នឹង LGD នឹង EAD។

LGD គឺជាឥរិយាបទនៃភាពអាចបាត់បង់ប្រសិនបើមានការខកខានសង។ ធនាគារប៉ាន់ស្មានលក្ខខណ្ឌ LGD យោងតាមប្រវត្តិនៃអត្រាការប្រមូលត្រលប់ពីអតិថិជនខកខានសង។ គំរូ LGD ត្រូវបានពិចារណាលើ រចនាសម្ព័ន្ធអទិភាពនៃការទាមទារសំណងវិស័យដែលអតិថិជនស្ថិតនៅចំណាយលើការប្រមូលពីទ្រព្យបញ្ចាំ ដែលជាផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ (ត)

EAD តំណាងឱ្យតម្លៃសមតុល្យនៅពេលមានការខកខានសង។ ធនាគារទាញយក EAD ពីសមតុល្យបច្ចុប្បន្នរបស់អតិថិជន និងភាពអាចប្រែប្រួលលើសមតុល្យបច្ចុប្បន្នពីការបង់សង ដែលអនុញ្ញាតតាមកិច្ចសន្យា និងកើតចេញពីការបង់រំលស់។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺតម្លៃយោងដុលនៅពេលមានការខកខានសង។ សម្រាប់កាតព្វកិច្ចឱ្យខ្ចី EAD គឺសមតុល្យអនាគតដែលអាចដកប្រើប្រាស់តាមកិច្ចសន្យា ដែលត្រូវបានប៉ាន់ស្មានតាមការសង្កេតពីប្រវត្តិ និងការព្យាករណ៍នាពេលខាងមុខ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុខ្លះ EAD ត្រូវបានកំណត់ដោយគំរូនៃសមតុល្យដែលអាចកើតឡើងនៅពេលវេលាផ្សេងគ្នាដោយប្រើបច្ចេកទេសស្ថិតិ។

ដូចការរៀបរាប់ខាងលើ ដោយផ្អែកលើការប្រើប្រាស់ PD 12ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី1 ធនាគារវាស់វែងលើការរំពឹងទុកលើការខាតបង់ឥណទាន ដោយពិចារណាលើហានិភ័យនៃការខូចខាតលើរយៈពេលពេញលេញនៃកិច្ចសន្យា (រួមបញ្ចូលទាំងរយៈពេលពន្យារប្រសិនបើមាន) ដែលមានហានិភ័យលើឥណទាន ទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយ ធនាគារពិចារណាលើរយៈពេលដែលវែងជាង។ រយៈពេល ដែលវែងបំផុត គឺគិតត្រឹមថ្ងៃដែលធនាគារមានសិទ្ធិដើម្បីទាមទារការសងត្រឡប់នៃឥណទាន ឬបញ្ចប់កិច្ចសន្យាផ្តល់ឥណទាន ឬការធានា។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមរំលស់ថ្លៃដើម និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាតាម FVOCI មានឱនភាពនៃតម្លៃ ឬទេ (ដែលត្រូវបានកំណត់ជា "ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី3")។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថា "មានឱនភាពនៃតម្លៃ" នៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើនបានកើតឡើង ដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគតដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកើតមានឡើង។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទានដល់អតិថិជន ដែលធនាគារមិនយល់ព្រម
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី ឬ
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន (ត)

ឥណទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អតិថិជន ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ លុះត្រាតែមានភស្តុតាងបញ្ជាក់ថា ហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានសូចនាករផ្សេងទៀតដែលនាំឱ្យមានឱនភាពនៃតម្លៃ។ បន្ថែមលើនេះ ឥណទានដែលហួសកាលកំណត់សង 90ថ្ងៃ ឬលើសពីនេះ ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ ទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ។

ការបង្ហាញសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

សំវិធានធននៃការខាតបង់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមតម្លៃរំលស់៖ ជាការកាត់ចេញពីតម្លៃយោងដុលនៃទ្រព្យសកម្ម
- កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានារ៉ាប់រងហិរញ្ញវត្ថុ៖ ជាទូទៅគឺជាសំវិធានធន
- នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងសមាសភាគដែលបានប្រើប្រាស់ និងនៅសល់ ហើយធនាគារមិនអាចកំណត់ ECL លើសមាសភាគកិច្ចសន្យាឥណទានដាច់ដោយឡែកពីសមាសភាគកិច្ចសន្យាឥណទានដែលបានប្រើប្រាស់៖ ធនាគារត្រូវបង្ហាញសំវិធានធននៃការខាតសម្រាប់ទាំងពីរសមាសភាគ។ ចំនួនទឹកប្រាក់រួមបញ្ចូលគ្នា ត្រូវបានបង្ហាញជាការកាត់ចេញពីចំនួនដុលនៃសមាសភាគដែលបានប្រើប្រាស់។ ចំនួនដែលសំវិធានធនលើការខាតបង់លើសពីចំនួនដុលនៃសមាសភាគ ដែលបានប្រើប្រាស់ត្រូវបង្ហាញជាសំវិធានធន និង
- ឧបករណ៍បំណុលវាស់វែងតាម FVOCI៖ មិនមានសំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដោយសារតែតម្លៃយោងស្មើទៅនឹងតម្លៃសមស្រប យ៉ាងណាមិញសំវិធានធននៃការខាតបង់ត្រូវបានបង្ហាញ និងទទួលស្គាល់នៅក្នុងមូលធន។

ការលុបចោល

ឥណទាន និងបុរេប្រទានត្រូវបានលុបចេញពីបញ្ជី (មួយផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង។ ករណីនេះមានជាទូទៅ នៅពេលធនាគារកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្មនីមួយៗ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii). ឱនភាពនៃតម្លៃ (ត)

ការលុបចោល (ត)

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុងខ្ទង់ "ការខាតបង់ឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ" នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។ ក្នុងករណីដែលទឹកប្រាក់ប្រមូលបានមកវិញមានភាពជាសារវន្ត ការប្រមូលបាននេះនឹងត្រូវបញ្ចូលក្នុង "ចំណូលផ្សេងៗ" ដាច់ដោយឡែក។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជី នៅតែតម្រូវឱ្យមានសកម្មភាពទាមទារសងមកវិញ ដើម្បីអនុលោមតាមនីតិវិធីរបស់ធនាគារក្នុងការប្រមូលទឹកប្រាក់ដែលនៅជំពាក់។

(viii) កំណែទម្រង់គោលការណ៍អត្រាការប្រាក់

ប្រសិនបើមូលដ្ឋាននៃការកំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដែលវាស់វែងតាមរំលស់ថ្លៃដើមមានការប្រែប្រួលដែលជាលទ្ធផលនៃកំណែទម្រង់អត្រាការប្រាក់ នោះធនាគារនឹងធ្វើបច្ចុប្បន្នភាពលើអត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនេះ។ ការផ្លាស់ប្តូរមូលដ្ឋានសម្រាប់កំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺត្រូវបានតម្រូវដោយកំណែទម្រង់អត្រាការប្រាក់ ប្រសិនបើលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ការផ្លាស់ប្តូរនេះចាំបាច់ជាលទ្ធផលផ្ទាល់នៃកំណែទម្រង់នេះ និង
- មូលដ្ឋានថ្មីសម្រាប់កំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺសមមូលនឹងមូលដ្ឋានមុន – ពោលគឺមូលដ្ឋានភ្លាមៗមុនពេលមានការផ្លាស់ប្តូរ។

ប្រសិនបើការផ្លាស់ប្តូរត្រូវបានធ្វើឡើងចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ បន្ថែមពីលើការផ្លាស់ប្តូរមូលដ្ឋាន សម្រាប់កំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យាដែល តម្រូវដោយកំណែទម្រង់អត្រាការប្រាក់ នោះធនាគារនឹងធ្វើបច្ចុប្បន្នភាពអត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមុនសិនដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលទាមទារដោយកំណែទម្រង់អត្រាការប្រាក់។ បន្ទាប់ពីនោះ ធនាគារនឹងអនុវត្តគោលនយោបាយគណនេយ្យសម្រាប់ការកែប្រែដែលបានកំណត់ខាងលើ ចំពោះចំណាយបន្ថែម។

ឃ. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ និងសមតុល្យក្នុងធនាគារ ប្រាក់បញ្ញើចរន្ត និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវិសាន្តនៅពេលតម្កល់ដំបូងរយៈពេល 3ខែ ឬតិចជាង ចាប់ពីកាលបរិច្ឆេទនៃការទិញ ដែលត្រូវប្រឈមនឹងហានិភ័យដែលមិនសារវន្តនៃការផ្លាស់ប្តូរតម្លៃសមស្របរបស់ពួកវា ហើយត្រូវបានប្រើប្រាស់ដោយធនាគារក្នុងការគ្រប់គ្រងកិច្ចសន្យារយៈពេលខ្លីរបស់ខ្លួន។

សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើមក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ង. ដើមទុន

ភាគហ៊ុនធម្មតា ត្រូវបានចាត់ថ្នាក់ជាមូលធន។ ថ្លៃដើមផ្ទាល់ក្នុងការបោះផ្សាយភាគហ៊ុន ត្រូវបានទទួលស្គាល់ដោយកាត់ចេញពីមូលធន បន្ទាប់ពីដកពន្ធរួច។ភាគហ៊ុនដទៃទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬបំណុលផ្អែកលើសមាសធាតុសេដ្ឋកិច្ចនៃឧបករណ៍ទាំងនោះ។ ការបែងចែកទៅអ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធន ត្រូវបានទូទាត់ដោយផ្ទាល់ពីមូលធន។

ច. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានបង្កើតលើភាពខុសគ្នា រវាងសំវិធានធន ស្របតាម ស.រ.ទ.ហ.អ.ក និងសំវិធានធនតាមបទប្បញ្ញត្តិ ស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរណែនាំ លេខ ធ7-018-001 ស.រ.ធ.ណ ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ស្របតាមប្រការ 73 គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាមប្រការ 49 ដល់ប្រការ 71 ជាមួយនឹងសំវិធានធន ដែលគណនាតាមប្រការ 72 និងត្រូវកត់ត្រាដូចខាងក្រោម៖

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ 72 ទាបជាងសំវិធានធនដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាអនុលោមតាម ស.រ.ទ.ហ.អ.ក និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ 72 ខ្ពស់ជាងសំវិធានធនដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាម ស.រ.ទ.ហ.អ.ក និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងមូលធននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ទុនបម្រុងតាមបទប្បញ្ញត្តិ មិនត្រូវបានបញ្ចូលក្នុងការគណនាមូលធនផ្ទាល់សុទ្ធរបស់ធនាគារឡើយ។

ឆ. ការរួមបញ្ចូលគ្នាអាជីវកម្មក្រោមការគ្រប់គ្រងរួម និងទុនបម្រុងពីការរួមបញ្ចូលគ្នា

ការរួមបញ្ចូលគ្នានៃការគ្រប់គ្រងពាណិជ្ជកម្មទូទៅត្រូវបានរាប់បញ្ចូលក្នុងការប្រើប្រាស់ "វិធីសាស្ត្រប្រមូលផ្តុំផលប្រយោជន៍"។ វិធីសាស្ត្រនៃការប្រមូលផ្តុំផលប្រយោជន៍ជាទូទៅត្រូវបានចាត់ទុកថាមានពាក់ព័ន្ធដូចខាងក្រោម៖

- ទ្រព្យសកម្ម និងបំណុលរបស់អង្គភាពរួមបញ្ចូលគ្នាត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុតាមបរិមាណជាក់ស្តែង។ គ្មានការកែសម្រួលណាមួយត្រូវបានធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពីតម្លៃសមស្រប ឬទទួលស្គាល់ទ្រព្យសកម្ម ឬបំណុលថ្មីណាមួយឡើយ នៅកាលបរិច្ឆេទនៃការរួមបញ្ចូលគ្នាដែលនឹងត្រូវធ្វើឡើងក្រោមវិធីសាស្ត្រនៃការទិញ។ ការកែតម្រូវតែមួយគត់ដែលត្រូវបានធ្វើឡើងគឺការកែតម្រូវទាំងនោះដើម្បីសម្របសម្រួលគោលនយោបាយគណនេយ្យ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ឆ. ការរួមបញ្ចូលគ្នាអាជីវកម្មក្រោមការគ្រប់គ្រងរួម និងទុនបម្រុងពីការរួមបញ្ចូលគ្នា (ត)

- គ្មានតម្លៃកេរ្តិ៍ឈ្មោះ 'ថ្មី' ត្រូវបានទទួលស្គាល់ជាលទ្ធផលនៃការរួមបញ្ចូលគ្នានោះទេ។ តម្លៃកេរ្តិ៍ឈ្មោះតែមួយគត់ដែលត្រូវបានទទួលស្គាល់គឺតម្លៃកេរ្តិ៍ឈ្មោះ ដែលមានស្រាប់ណាមួយទាក់ទងនឹងអង្គភាពរួមបញ្ចូលគ្នា។ ភាពខុសគ្នាណាមួយរវាងការពិចារណាដែលបានបង់ ឬផ្ទេរ និងភាគហ៊ុន 'ទទួលបាន' ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងមូលធនដែលជាទុនបម្រុងរួមបញ្ចូលគ្នា។
- របាយការណ៍ចំណេញ ឬខាត បង្ហាញពីលទ្ធផលនៃការរួមបញ្ចូលគ្នារបស់អង្គភាពពេញមួយឆ្នាំ ដោយមិនគិតពីពេលដែលរួមបញ្ចូលគ្នាឡើយ។

ជ. ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របបូកនឹងចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ ហើយបន្ទាប់មកកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

ឈ. ប្រាក់តម្កល់តាមបទប្បញ្ញត្តិ

ប្រាក់តម្កល់តាមបទប្បញ្ញត្តិ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមា និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ញ. ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន

"ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមបញ្ចូលឥណទាន និងបុរេប្រទាន ដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម។ ឥណទាន និងបុរេប្រទានត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

ដ. ទ្រព្យសកម្មផ្សេងទៀត

ទ្រព្យសកម្មផ្សេងទៀតត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពនៃតម្លៃ ប្រសិនបើមាន។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ប. ទ្រព្យ និងបរិក្ខារ

(i). ការទទួលស្គាល់ និងការវាស់វែង

ធាតុនៃទ្រព្យ និងបរិក្ខារត្រូវបានវាស់វែងតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ។

ចំណាយថ្លៃដើម រួមបញ្ចូលទាំងការចំណាយដោយផ្ទាល់ទៅលើការទិញទ្រព្យ និងការចំណាយដោយផ្ទាល់ផ្សេងៗទៀត ក្នុងការនាំយកទ្រព្យសកម្មទៅក្នុងលក្ខខណ្ឌដែលអាចប្រើប្រាស់ដែលបានគ្រោងទុក និងថ្លៃដើមនៃការរុះរើ និងផ្លាស់ប្តូរទីកន្លែង និងការស្តារទីតាំងដែលពួកគេស្ថិតនៅ។ ថ្លៃដើមនៃទ្រព្យកម្មដែលបានសាងសង់ដោយខ្លួនឯង ត្រូវរួមបញ្ចូលទាំងថ្លៃដើមសម្ភារ និងកម្លាំងពលកម្មផ្ទាល់ផងដែរ។ ចំពោះទ្រព្យសកម្មដែលមានលក្ខណៈគ្រប់គ្រាន់ ការចំណាយលើប្រាក់កម្ចីត្រូវបានធ្វើមូលធនកម្មស្របតាមគោលនយោបាយគណនេយ្យលើថ្លៃដើមប្រាក់កម្ចី។ ថ្លៃដើមក៏អាចរួមបញ្ចូលទាំងការផ្ទេរមូលធន ដែលជាចំណេញ ឬខាតណាមួយផងដែរលើការការពារហានិភ័យលំហូរសាច់ប្រាក់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះរូបិយប័ណ្ណបរទេសទាក់ទងនឹងការទិញទ្រព្យ និងបរិក្ខារ។

ការទិញសូហ្វវែរដែលមានសារៈសំខាន់ចំពោះមុខងារដែលទាក់ទងនឹងបរិក្ខារ ត្រូវបានធ្វើមូលធនកម្មជាផ្នែកមួយនៃបរិក្ខារនោះ។

ប្រសិនបើផ្នែកជាសារវន្តណាមួយនៃទ្រព្យ និងបរិក្ខារទាំងនោះ មានអាយុកាលប្រើប្រាស់ខុសពីគ្នា ផ្នែកទាំងនោះត្រូវបានដាក់ជាផ្នែកដោយឡែក (សមាសធាតុចម្បង) នៃទ្រព្យ និងបរិក្ខារ។

(ii). ចំណាយបន្ទាប់

ចំណេញ ឬខាតពីការលក់នៃទ្រព្យ និងបរិក្ខារណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ជាចំណូលផ្សេងៗ "ចំណូលផ្សេងៗ" និង "ចំណាយផ្សេងៗ" នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

ថ្លៃដើមនៃការផ្លាស់ប្តូរធាតុមួយផ្នែកនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលនៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដល់ធនាគារ ហើយតម្លៃរបស់វាអាចធ្វើការវាស់វែងបានដោយភាពអាចជឿជាក់បាន។ តម្លៃយោងនៃធាតុដែលបានជំនួសនោះ ត្រូវឈប់ទទួលស្គាល់ជាចំណេញ ឬខាត។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃផ្សេងៗ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត នៅក្នុងរបាយការណ៍ចំណេញ ឬខាត ក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ប. ទ្រព្យ និងបរិក្ខារ (ត)

(ញ). រំលស់

ថ្លៃដើមនៃការផ្លាស់ប្តូរធាតុមួយផ្នែកនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលនៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដល់ធនាគារ ហើយតម្លៃរបស់វាអាចធ្វើការវាស់វែងបានដោយភាពជឿជាក់។ តម្លៃយោងនៃធាតុដែលបានជំនួសនោះ ត្រូវបានឈប់ទទួលស្គាល់ជាចំណេញ ឬខាត។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃផ្សេងៗ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត នៅក្នុងរបាយការណ៍ចំណេញ ឬខាត ក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

រំលស់ គឺផ្អែកទៅលើថ្លៃដើមនៃទ្រព្យសកម្ម ដកតម្លៃកាកសំណល់របស់វា។ សមាសធាតុសំខាន់ៗ នៃទ្រព្យសកម្មនីមួយៗ ត្រូវបានវាយតម្លៃ ហើយប្រសិនបើសមាសធាតុមួយមានអាយុកាលប្រើប្រាស់ខុសគ្នាពីទ្រព្យសកម្មដែលនៅសល់ សមាសធាតុនោះត្រូវបានធ្វើឡើងដាច់ដោយឡែក។

រំលស់ ត្រូវបានទទួលស្គាល់ថាជាការចំណាយនៅក្នុងរបាយការណ៍ចំណេញ ឬខាតលើមូលដ្ឋានរំលស់ថេរលើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មាននៃសមាសធាតុនីមួយៗ នៃទ្រព្យ និងបរិក្ខារ។

រំលស់ ត្រូវបានទទួលស្គាល់ចាប់ពីកាលបរិច្ឆេទដែលទ្រព្យ និងបរិក្ខារត្រូវបានតម្លើង និងអាចប្រើប្រាស់បាន ឬទ្រព្យសកម្មដែលបានសាងសង់ ចាប់ពីការិយបរិច្ឆេទដែលទ្រព្យសកម្មនោះត្រូវបានបញ្ចប់ និងអាចប្រើប្រាស់បាន។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន មានដូចខាងក្រោម៖

ការកែលម្អទ្រព្យជួល	លើសពី 1ឆ្នាំ ដល់ 10ឆ្នាំ
យានយន្ត	3ឆ្នាំ ដល់ 10ឆ្នាំ
បរិក្ខារកុំព្យូទ័រ	3ឆ្នាំ ដល់ 10ឆ្នាំ
គ្រឿងសង្ហារឹម និងគ្រឿងបំពាក់	3ឆ្នាំ ដល់ 5ឆ្នាំ
បរិក្ខារ	3ឆ្នាំ ដល់ 10ឆ្នាំ

វិធីសាស្ត្ររំលស់ លើអាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានវាយតម្លៃនាចុងការិយបរិច្ឆេទនៃរបាយការណ៍ និងធ្វើនិយ័តភាពប្រសិនបើសមស្រប។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ឧ. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានថ្លៃដើមអាជ្ញាបណ្ណកុំព្យូទ័រដែលបានទិញ និងថ្លៃដើមពាក់ព័ន្ធផ្សេងទៀត ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ អាជ្ញាបណ្ណកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។

ទ្រព្យសកម្មអរូបី ត្រូវបានដករំលស់ទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានចន្លោះពី 3ឆ្នាំ ទៅ 15ឆ្នាំ តាមវិធីសាស្ត្ររំលស់ថេរ។

ថ្លៃដើមពាក់ព័ន្ធនឹងការបង្កើត ឬថែទាំកុំព្យូទ័រសូហ្វវែរ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលកើតឡើង។

ឈ. ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ត្រូវបានវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

ណ. ភតិសន្យា

នៅពេលចាប់ផ្តើមកិច្ចសន្យា ធនាគារធ្វើការវាយតម្លៃថាតើកិច្ចសន្យាមួយមានទម្រង់ជាភតិសន្យាដែរ ឬទេ។ កិច្ចសន្យាជាទម្រង់មានភតិសន្យា ប្រសិនបើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់មួយក្នុងរយៈពេលកំណត់មួយ ជាថ្នូរនឹងតម្លៃតបស្នង។

ដើម្បីវាយតម្លៃថាតើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ ធនាគារធ្វើការវាយតម្លៃថាតើ៖

- កិច្ចសន្យាមានជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ ឬទេ ដែលនេះអាចបញ្ជាក់យ៉ាងជាក់លាក់ ឬប្រយោល ហើយគួរមានលក្ខណៈរូបវន្តដោយឡែក ឬតំណាងសមត្ថភាពផលិតសារវន្តរបស់ទ្រព្យសកម្មនោះ។ ប្រសិនបើអ្នកផ្គត់ផ្គង់មានសិទ្ធិផ្តល់ទ្រព្យសកម្មជំនួសជាសារវន្តក្នុងរយៈពេលប្រើប្រាស់នោះទ្រព្យសកម្មមិនមែនមានលក្ខណៈជាទ្រព្យសកម្មជាក់លាក់នោះទេ
- ធនាគារ មានសិទ្ធិទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចជាសារវន្ត ពីការប្រើប្រាស់ទ្រព្យសកម្ម ក្នុងរយៈពេលនៃការប្រើប្រាស់ និង

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ណ. ភតិសន្យា (ត)

- ធនាគារមានសិទ្ធិបញ្ជាការប្រើប្រាស់ទ្រព្យសកម្ម។ ធនាគារមានសិទ្ធិនេះ នៅពេលដែលធនាគារមានសិទ្ធិសម្រេចចិត្តដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរអំពីរបៀប និងគោលបំណងក្នុងការប្រើប្រាស់ទ្រព្យសកម្ម។ ក្នុងករណីដែលការសម្រេចចិត្តទាំងអស់អំពីរបៀប និងគោលបំណងនៃការប្រើប្រាស់ ទ្រព្យសកម្មត្រូវបានកំណត់ជាមុន នោះធនាគារមានសិទ្ធិបញ្ជាការប្រើប្រាស់ទ្រព្យសកម្ម ប្រសិនបើ៖
  - ធនាគារមានសិទ្ធិធ្វើប្រតិបត្តិការលើទ្រព្យសកម្ម ឬ
  - ធនាគារបានរៀបចំទ្រព្យសកម្មទៅតាមវិធីដែលកំណត់ជាមុនពីរបៀប និងគោលបំណងដែលទ្រព្យសកម្មនោះនឹងត្រូវបានប្រើប្រាស់។

(i) ធនាគារជាភតិករ:

នៅពេលចាប់ផ្តើម ឬនៅលើការកែប្រែកិច្ចសន្យាដែលមានសមាសធាតុភតិសន្យា ធនាគារបែងចែកតម្លៃតបស្នងនៅក្នុងកិច្ចសន្យាចំពោះសមាសធាតុភតិសន្យានីមួយៗ ដោយផ្អែកតាមតម្លៃឯកតានីមួយៗ។ ទោះជាយ៉ាងណា សម្រាប់ការជួលសាខា និងទីស្នាក់ការការិយាល័យ ធនាគារបានជ្រើសរើសមិនបំបែកសមាសធាតុដែលមិនជួល និងរួមបញ្ចូលជាការជួល និងសមាសធាតុដែលមិនជួលជាសមាសធាតុនៃការជួលតែមួយ។

ធនាគារ ទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យា នៅកាលបរិច្ឆេទចាប់ផ្តើមជួល។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានវាស់វែងដំបូងតាមថ្លៃដើម ដែលរួមមានចំនួនទឹកប្រាក់ដំបូងនៃបំណុលភតិសន្យា ដែលត្រូវបានកែតម្រូវសម្រាប់ការបង់ថ្លៃជួលណាមួយ ដែលបានធ្វើឡើងនៅ ឬមុនកាលបរិច្ឆេទចាប់ផ្តើមបូករួមនឹងការចំណាយដោយផ្ទាល់ដំបូង ដែលបានកើតឡើង និងការប៉ាន់ស្មាននៃចំណាយដើម្បីរុះរើ និងដកចេញនូវការកែលម្អដែលបានធ្វើឡើងនៅតាមសាខា ឬទីស្នាក់ការការិយាល័យ។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានដករំលស់ តាមវិធីសាស្ត្ររំលស់ថេរ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមភតិសន្យារហូតដល់ចុងបញ្ចប់នៃអាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬនៅចុងកាលបរិច្ឆេទនៃភតិសន្យាមួយណាកើតមុន។ អាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកំណត់តាមមូលដ្ឋានដូចគ្នានឹងទ្រព្យ និងបរិក្ខារ។ បន្ថែមលើនេះ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកាត់បន្ថយជាប្រចាំទៅតាមការខាតបង់ឱនភាពនៃតម្លៃ និងកែតម្រូវសម្រាប់ការវាស់វែងឡើងវិញលើបំណុលភតិសន្យា។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់សម្រាប់អំឡុងការិយបរិច្ឆេទបច្ចុប្បន្ន មានដូចខាងក្រោម៖

- អគារ 2 – 10ឆ្នាំ
- ការជួលទីតាំង ATM 2 – 5ឆ្នាំ

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ណ. ភតិសន្យា (ត)

(i) ធនាគារជាភតិករ: (ត)

បំណុលភតិសន្យាត្រូវបានវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនទាន់បានបង់ នៅពេលចាប់ផ្តើមភតិសន្យា និងត្រូវបានធ្វើអប្បហារដោយប្រើអត្រាការប្រាក់ជាក់ស្តែងនៅក្នុងភតិសន្យា ឬករណីដែលអត្រាការប្រាក់នោះមិនអាចកំណត់បានភ្លាមៗត្រូវធ្វើទៅតាមអត្រាការប្រាក់កម្ចីបន្ថែមរបស់អ្នកជួល។ ជាទូទៅធនាគារប្រើអត្រាការប្រាក់កម្ចីបន្ថែមជាអត្រាអប្បហារ។

ការទូទាត់ភតិសន្យាដែលបញ្ចូលនៅក្នុងការវាស់វែងបំណុលភតិសន្យារួមមាន៖

- ការទូទាត់ភតិសន្យាថេររួមទាំងការទូទាត់ក្នុងទម្រង់ថេរ
- ការប្រែប្រួលនៃការទូទាត់ភតិសន្យាអថេរ ដោយផ្អែកលើសន្ទស្សន៍ ឬអត្រា នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា
- ចំនួនដែលរំពឹងថានឹងត្រូវទូទាត់ ក្រោមការធានាតម្លៃនៅសល់ និង
- តម្លៃទិញក្រោមជម្រើសនៃការទិញ ដែលធនាគារមានហេតុផលជាក់លាក់ក្នុងការអនុវត្តការទូទាត់ភតិសន្យានៅក្នុងអំឡុងពេលដែលមានជម្រើសក្នុងការបន្ត ប្រសិនបើធនាគារមានហេតុផលជាក់លាក់ក្នុងការបន្ត និងការពិន័យលើការបញ្ចប់ភតិសន្យាមុនកាលកំណត់ លើកលែងតែធនាគារមានហេតុផលច្បាស់លាស់ថានឹងមិនបញ្ចប់ភតិសន្យាមុនកាលកំណត់។

បំណុលភតិសន្យា ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញនៅពេលមានការកែប្រែរយៈពេលនៃភតិសន្យា ការផ្លាស់ប្តូរលើការវាយតម្លៃសម្រាប់ជម្រើសក្នុងការទិញទ្រព្យសកម្ម ការប្រែប្រួលការទូទាត់ភតិសន្យានាពេលអនាគត ដែលកើតឡើងពីការប្រែប្រួលនៃសន្ទស្សន៍ ឬអត្រាណាមួយ ឬប្រសិនបើមានការកែប្រែចំនួនប៉ាន់ស្មានដែលរំពឹងថានឹងត្រូវទូទាត់ លើការធានាតម្លៃដែលនៅសល់។

នៅពេលដែលបំណុលភតិសន្យាត្រូវបានវាស់វែងតាមវិធីសាស្ត្រនេះ ការកែតម្រូវ ត្រូវបានធ្វើឡើងលើតម្លៃយោងនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬក៏ទទួលស្គាល់ក្នុងចំណេញឬខាត បើសិនជាសិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានបញ្ចុះរហូតដល់មានតម្លៃសូន្យ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ណ. ភតិសន្យា (ត)

(i) ធនាគារជាភតិក: (ត)

ភតិសន្យាមានរយៈពេលខ្លី និងភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាប

ភតិសន្យារយៈពេលខ្លី គឺជាភតិសន្យាមួយដែល នៅថ្ងៃចាប់ផ្តើមកិច្ចសន្យា មានរយៈពេលជួល 12ខែ ឬតិចជាងនេះ។ ភតិសន្យាណាមួយដែលផ្តល់ជម្រើសក្នុងការទិញមិនត្រូវបានចាត់ទុកថា ជាភតិសន្យារយៈពេលខ្លីនោះទេ។

ភតិសន្យានៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃកិច្ចសន្យាជួល មិនអាចត្រូវបានចាត់ទុកថាជាភតិសន្យាទ្រព្យសម្បត្តិដែលមានតម្លៃទាប បានទេ ប្រសិនបើលក្ខណៈរបស់ទ្រព្យសម្បត្តិនោះ បង្ហាញថា នៅពេលវាថ្មី ទ្រព្យសម្បត្តិនោះជាទូទៅ មិនមែនជាទ្រព្យសម្បត្តិដែលមានតម្លៃទាប នោះទេ។ ឧទាហរណ៍ ភតិសន្យាជួល រថយន្ត មិនអាចចាត់ទុកថា ជាកិច្ចសន្យាជួលទ្រព្យសម្បត្តិដែលមានតម្លៃទាបបានទេ ព្រោះរថយន្តថ្មីជាទូទៅ មិនមែនជាទ្រព្យសម្បត្តិដែលមានតម្លៃទាប នោះឡើយ។

ធនាគារទទួលស្គាល់ចំណាយលើការជួលទាំងនេះតាមមូលដ្ឋានរំលស់ថេរ ទៅតាមរយៈពេលនៃភតិសន្យា។

(ii) ធនាគារជាភតិបតី

ចាប់ពីថ្ងៃដំបូង ឬថ្ងៃដែលធ្វើការកែប្រែកិច្ចសន្យាដែលរួមមានធាតុផ្សំនៃភតិសន្យា ធនាគារបែងចែកសមាសភាគភតិសន្យាក្នុងកិច្ចសន្យានីមួយៗ ផ្អែកលើតម្លៃដាច់ដោយឡែករបស់វា។

នៅពេលដែលធនាគារដើរតួជាភតិបតី កំណត់ថាវាជាភតិសន្យាតាំងពីថ្ងៃដំបូង ថាតើការភតិសន្យានីមួយៗជាភតិសន្យាហិរញ្ញវត្ថុ ឬភតិសន្យាប្រតិបត្តិការ។

ដើម្បីធ្វើចំណាត់ថ្នាក់ភតិសន្យានីមួយៗ ធនាគារធ្វើការវាយតម្លៃជារួមថាតើភតិសន្យាផ្ទេរហានិភ័យ និងផលតបស្នងជាសារវន្តទាំងអស់ដែលកើតឡើងដោយចៃដន្យទៅកាន់ម្ចាស់នៃទ្រព្យសកម្មឬអត់។ ប្រសិនបើជាករណីនេះ នោះវាគឺជាភតិសន្យាហិរញ្ញវត្ថុ។ បើមិនដូច្នោះទេ វាជាភតិសន្យាប្រតិបត្តិការ។ ជាផ្នែកមួយនៃការវាយតម្លៃនេះ ធនាគារពិចារណាលើសូចនាករមួយចំនួនដូចជាថាតើភតិសន្យាគឺជាចំណែកដ៏សំខាន់នៃជីវិតសេដ្ឋកិច្ចនៃទ្រព្យសកម្ម។

នៅពេលធនាគារជាអន្តការីភតិបតី នោះធនាគារត្រូវទទួលស្គាល់ចំណែកនៅក្នុងភតិសន្យាមេ និងអនុភតិសន្យាដាច់ដោយឡែកពីគ្នា។ ធនាគារ វាយតម្លៃចំណាត់ថ្នាក់អនុភតិសន្យាដោយយោងទៅតាមសិទ្ធិប្រើប្រាស់ទ្រព្យសកម្មដែលកើតចេញពីភតិសន្យាមេ មិនមែនដោយយោងទៅលើទ្រព្យសកម្មនោះទេ។ ប្រសិនបើភតិសន្យាមេ គឺជាការជួលរយៈពេលខ្លីដែលធនាគារអនុវត្តការលើកលែងដែលបានពិពណ៌នាខាងលើ នោះធនាគារចាត់ថ្នាក់ការជួលបន្តជាកិច្ចសន្យាភតិសន្យាប្រតិបត្តិការ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ណ. ភតិសន្យា (ត)

(i) ធនាគារជាភតិបតី (ត)

ប្រសិនបើកិច្ចសន្យាមួយមានធាតុភតិសន្យា និងមិនមែនភតិសន្យា និងមិនជួល នោះធនាគារអនុវត្ត ស.រ.ហ.អ.ក 15 ដើម្បីបែងចែកចំណូលនៅក្នុងកិច្ចសន្យា។

ធនាគារអនុវត្តនូវលក្ខខណ្ឌតម្រូវនៃការឈប់ទទួលស្គាល់ និងឱនភាពនៃតម្លៃតាម ស.រ.ហ.អ.ក 9 ទៅលើការវិនិយោគសុទ្ធទៅលើភតិសន្យា។ ធនាគារពិនិត្យយ៉ាងទៀតទាត់បន្ថែម លើតម្លៃកាកសំណល់ដែលមិនមានការធានាដែលបានប៉ាន់ប្រមាណដែលត្រូវបានប្រើក្នុងការគណនាការវិនិយោគដុលនៅក្នុងភតិសន្យា។

ធនាគារ ទទួលស្គាល់ការទូទាត់ភតិសន្យាដែលទទួលបានពីភតិសន្យាប្រតិបត្តិការជាប្រាក់ចំណូលតាមវិធីសាស្ត្រថេរក្នុងរយៈពេលជួលជាផ្នែកនៃ 'ប្រាក់ចំណូលប្រតិបត្តិការផ្សេងៗ'។

ត. ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដកថ្លៃដើមប្រតិបត្តិការបន្ថែមដោយផ្ទាល់ និងវាស់វែងបន្ទាប់តាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

ថ. អត្ថប្រយោជន៍និយោជិត

(i). អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លីត្រូវបានចំណាយ នៅពេលដែលសេវាកម្មត្រូវបានផ្តល់ជូន។ ចំនួនដែលរំពឹងទុកថានឹងត្រូវចំណាយ ត្រូវបានទទួលស្គាល់ជាបំណុល ប្រសិនបើធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយ ដែលជាលទ្ធផលនៃការងារដែលបានបំពេញរួចមកហើយដោយនិយោជិត ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបានដោយភាពជឿជាក់។

(ii). អត្ថប្រយោជន៍និយោជិតរយៈពេលវែង

កាតព្វកិច្ចរបស់ធនាគារចំពោះអត្ថប្រយោជន៍និយោជិតរយៈពេលវែង គឺជាចំណាយលើអត្ថប្រយោជន៍ ដែលនិយោជិតត្រូវទទួលបាន ពីការបំពេញការងារក្នុងការិយបរិច្ឆេទបច្ចុប្បន្ន និងកន្លងផុតទៅ។ អត្ថប្រយោជន៍និយោជិតរយៈពេលវែង ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន។ ការវាស់វែងសារជាថ្មីត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត នៅក្នុងការិយបរិច្ឆេទដែលចំណាយនេះបានកើតឡើង។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ទ. សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរសាច់ប្រាក់ ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ អប្បហារនៅសល់ត្រូវបានទទួលស្គាល់ជាថ្លៃដើមហិរញ្ញប្បទាន។

ធ. ការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាព

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួលតាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុនោះ ឱ្យមកស្មើនឹង៖

- តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- រំលស់តម្លៃដើមរបស់បំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យដែលបានទិញ ឬទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃនៅពេលទិញ ធនាគារធ្វើការប៉ាន់ស្មានលើលំហូរសាច់ប្រាក់នាពេលអនាគត ដោយពិចារណារាល់លក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវឧខាតបង់ឥណទានដែលរំពឹងទុកនោះទេ (ECL)។ សម្រាប់ទ្រព្យសកម្មដែលទិញ ឬទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានឱនភាពនៃតម្លៃនៅពេលទិញ អត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវហានិភ័យឥណទាន ត្រូវបានគណនាដោយប្រើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគតរួមបញ្ចូលទាំងការខាតបង់ឥណទានដែលរំពឹងទុក (ECL)។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ អត្រាការប្រាក់តាមកិច្ចសន្យាត្រូវបានប្រើប្រាស់ជំនួសឱ្យអត្រាការប្រាក់ប្រសិទ្ធភាព នៅពេលដែលគណៈគ្រប់គ្រងវាយតម្លៃនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់មិនមែនជាផ្នែកដែលជាសារវន្តនៃអត្រាការប្រាក់ប្រសិទ្ធភាព ហើយគណៈគ្រប់គ្រងយល់ឃើញថា មិនមានផលប៉ះពាល់ជាសារវន្តដល់របាយការណ៍ហិរញ្ញវត្ថុ។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការចោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ធ. ការប្រាក់ (ត)

រំលស់ថ្លៃដើម និងតម្លៃយោងដុល

"រំលស់ថ្លៃដើម"របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូង ដកការទូទាត់សងប្រាក់ដើម បូក ឬដករំលស់បង្គរ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់ជាលើកដំបូង និងចំនួននៅពេលដល់កាលកំណត់ និងត្រូវធ្វើនិយ័តភាពចំពោះសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ។

"តម្លៃយោងដុល" របស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជារំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលកែតម្រូវសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក។

ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាលើកដំបូង។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាព ត្រូវបានប្រើផ្អែកលើតម្លៃយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មមិនត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ) ឬរំលស់ថ្លៃដើមនៃបំណុល។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវធ្វើការកែប្រែឡើងវិញ ដោយការប៉ាន់ស្មានឡើងវិញនូវលំហូរសាច់ប្រាក់របស់ឧបករណ៍ហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់ប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររបស់អត្រាការប្រាក់ទីផ្សារ។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ត្រូវធ្វើការកែប្រែឡើងវិញ សម្រាប់ការកែតម្រូវតម្លៃសមស្របនៃឧបករណ៍ការពារ នៅកាលបរិច្ឆេទដែលរំលស់ត្រូវបានចាប់ផ្តើមកែតម្រូវ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ បន្ទាប់ពីបានទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ផ្អែកលើរំលស់ថ្លៃដើម របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពនៃតម្លៃ នោះការគណនាការប្រាក់ត្រូវផ្អែកលើមូលដ្ឋានតម្លៃដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ ចាប់តាំងពីទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលត្រូវបានកែតម្រូវនូវហានិភ័យ ផ្អែកលើរំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ការគណនាចំណូលការប្រាក់នេះ មិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញនោះទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ធ. ការប្រាក់ (ត)

ការបង្ហាញ

ចំណូលពីការប្រាក់ ត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម។

ចំណាយលើការប្រាក់ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលបំណុលហិរញ្ញវត្ថុ ដែលបានវាស់វែងតាមរំលស់ថ្លៃដើម។

ន. កម្រៃ និងជើងសា

ចំណូល និងចំណាយកម្រៃ និងជើងសា ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃ និងជើងសាផ្សេងទៀត – រួមទាំងកម្រៃសេវាកម្មគណនេយ្យ ត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម។

កិច្ចសន្យាជាមួយអតិថិជន ដែលទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អាចមានវិសាលភាពដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក 9 និងដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក 15។ ក្នុងករណីនេះ ជាដំបូងធនាគារត្រូវអនុវត្ត ស.រ.ហ.អ.ក 9 ដើម្បីបែងចែក និងវាស់វែងផ្នែកនៃកិច្ចសន្យា ដែលចាត់ចូលនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក 9 ហើយបន្ទាប់មកអនុវត្ត ស.រ.ហ.អ.ក 15 ចំពោះផ្នែកដែលនៅសេសសល់។

ប. ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

នៅកាលបរិច្ឆេទរបាយការណ៍នីមួយៗធនាគារពិនិត្យមើល តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ធនាគារ (ក្រៅពីទ្រព្យសម្បត្តិវិនិយោគ និងពន្ធពន្យារជាទ្រព្យសកម្ម) ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ ឬទេ ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង នោះការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។

សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ប. ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារទៅនឹងតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬក្រុមនៃឯកតាបង្កើតសាច់ប្រាក់ លើសពីតម្លៃដែលអាចប្រមូលមកវិញបាន។

ទ្រព្យសកម្មរបស់ធនាគារមិនបង្កើតលំហូរសាច់ប្រាក់ដាច់ដោយឡែកទេ ហើយត្រូវបានប្រើប្រាស់ដោយក្រុមនៃឯកតាបង្កើតសាច់ប្រាក់ច្រើនជាងមួយ។ ទ្រព្យសកម្មរបស់ធនាគារត្រូវបានបែងចែកទៅឱ្យក្រុមនៃឯកតាបង្កើតសាច់ប្រាក់ដោយផ្អែកលើមូលដ្ឋានសមហេតុផល និងសង្គតភាព និងត្រូវបានធ្វើតេស្តលើឱនភាពនៃតម្លៃដែលជាផ្នែកមួយនៃការធ្វើតេស្តរបស់ក្រុមនៃឯកតាបង្កើតសាច់ប្រាក់ ដែលទ្រព្យសកម្មរបស់ធនាគារត្រូវបានគេបែងចែក។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត។ ការខាតបង់លើឱនភាពនៃតម្លៃនៃឯកតាបង្កើតសាច់ប្រាក់ ត្រូវបានបែងចែកដោយកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មដទៃទៀត នៅក្នុងឯកតាបង្កើតសាច់ប្រាក់ លើមូលដ្ឋានសមាមាត្រ។

ការខាតបង់លើឱនភាពនៃតម្លៃរបស់មូលនិធិពាណិជ្ជកម្មមិនអាចកត់ត្រាបញ្ច្រាសបានទេ។ សម្រាប់ទ្រព្យសកម្មផ្សេងទៀត ការខាតបង់លើឱនភាពនៃតម្លៃអាចកត់ត្រាបញ្ច្រាសបានវិញតែក្នុងកម្រិតមួយដែលតម្លៃយោងនៃទ្រព្យសកម្ម មិនលើសពីតម្លៃយោងដែលបានកំណត់សុទ្ធនៃរំលស់ ប្រសិនបើគ្មានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់។

ផ. ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត លើកលែងតែពន្ធនេះទាក់ទងទៅនឹងធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬលទ្ធផលលម្អិតផ្សេងៗ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ជ. ពន្ធលើប្រាក់ចំណេញ (ត)

ធនាគារបានកំណត់ថា ការប្រាក់ និងការដាក់ពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណេញ រួមបញ្ចូលបំណកស្រាយពន្ធមិនច្បាស់លាស់ មិនបំពេញទៅនឹងនិយមន័យនៃពន្ធលើប្រាក់ចំណេញ ដូច្នេះហើយវាត្រូវបានកត់ត្រាក្រោមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ស.គ.អ.ក 37 *សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព* ហើយត្រូវបានទទួលស្គាល់ថាជាការចំណាយដែលពាក់ព័ន្ធ "ការចំណាយផ្សេងៗ"។

(i). *ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ*

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ រួមមានពន្ធដែលត្រូវបង់ ឬទទួល លើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។

(ii). *ពន្ធពន្យារ*

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន។ ការកាត់បន្ថយនោះត្រូវកត់ត្រាបញ្ច្រាសមកវិញនៅពេលដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមានលក្ខណៈប្រសើរឡើង។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ន នៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធនៅកាលបរិច្ឆេទរាយការណ៍។

នាកាលបរិច្ឆេទរាយការណ៍ ការវាស់វែងពន្ធពន្យារឆ្លុះបញ្ចាំងនូវពន្ធដែលធនាគាររំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុល អាចកាត់កងបានតែក្នុងករណីវាបានបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ។

33. គោលនយោបាយគណនេយ្យសារវន្ត (ត)

ព. បំណុលយថាភាព

ក្នុងករណីដែលមិនតម្រូវឱ្យមានការហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបាន នោះកាតព្វកិច្ចមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះទេ ហើយវាត្រូវបានបង្ហាញថាជាបំណុលយថាភាព លើកលែងតែលទ្ធភាពនៃលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើរតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន ប៉ុន្តែអត្ថិភាពនៃកាតព្វកិច្ច នឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគត មួយ ឬច្រើន ក៏ត្រូវបានបង្ហាញថាជាបំណុលយថាភាពដែលអាចកើតមានឡើង លុះត្រាតែលទ្ធភាពនៃការហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើរតែគ្មាន។

ក. ទ្រព្យសកម្មយថាភាព

ក្នុងករណីដែលមិនមានលទ្ធភាពហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបាន នោះទ្រព្យសកម្មមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុឡើយ ហើយវាត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាភាព លើកលែងតែលទ្ធភាពនៃលំហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើរតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន ប៉ុន្តែអត្ថិភានៃទ្រព្យសកម្មនឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើន ក៏ត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាភាពដែលអាចកើតមានឡើង លុះត្រាតែលទ្ធភាពនៃការហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើរតែគ្មាន។

34. ស្តង់ដាថ្មី ឬវិសោធនកម្ម និងការបកស្រាយមិនទាន់បានអនុវត្ត

ស្តង់ដាគណនេយ្យថ្មី និងវិសោធនកម្មមួយចំនួន ទាក់ទងនឹងស្តង់ដាគណនេយ្យដែលមានស្រាប់បានចូលជាធរមាន សម្រាប់ការិយបរិច្ឆេទចាប់ផ្តើមបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2025 ដែលការអនុវត្តមុនកាលកំណត់ត្រូវបានអនុញ្ញាត។ យ៉ាងណាមិញ ធនាគារមិនទាន់បានអនុវត្តនូវស្តង់ដាគណនេយ្យថ្មី ឬស្តង់ដាដែលបានធ្វើវិសោធនកម្មទាំងនេះក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះនៅឡើយទេ។

ក. ការធ្វើចំណាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ (វិសោធនកម្មលើ ស.រ.ហ.អ.ក 9 និង ស.រ.ហ.អ.ក 7)

នៅខែឧសភា ឆ្នាំ2024 ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (IASB) បានចេញផ្សាយ *វិសោធនកម្មលើការធ្វើចំណាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ* ដែលបានធ្វើវិសោធនកម្មលើ ស.រ.ហ.អ.ក 9 និង ស.រ.ហ.អ.ក 7។

34. ស្តង់ដាថ្មី ឬវិសោធនកម្ម និងការបកស្រាយមិនទាន់បានអនុវត្ត (ត)

ក. ការធ្វើចំណាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ (វិសោធនកម្មលើ ស.រ.ហ.អ.ក 9 និង ស.រ.ហ.អ.ក 7) (ត)

លក្ខខណ្ឌតម្រូវនឹងចូលជាធរមាន សម្រាប់ការិយបរិច្ឆេទចាប់ផ្តើមបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2026 ដែលការអនុវត្តមុនកាលកំណត់ ត្រូវបានអនុញ្ញាត ហើយពាក់ព័ន្ធនឹង៖

- ការទទួលស្គាល់ និងការលុបចេញពីការទទួលស្គាល់ រួមទាំងគោលការណ៍គណនេយ្យនៃការទូទាត់បំណុលហិរញ្ញវត្ថុដោយប្រើប្រព័ន្ធទូទាត់អេឡិចត្រូនិក និង
- ការវាយតម្លៃកិច្ចសន្យា តាមលក្ខណៈលំហូរសាច់ប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ រួមទាំងលក្ខណៈពិសេសដែលភ្ជាប់ដោយនិរន្តរភាព។

ធនាគារកំពុងស្ថិតក្នុងដំណើរការវាយតម្លៃផលប៉ះពាល់នៃការធ្វើវិសោធនកម្មថ្មីនេះ។

ខ. ស.រ.ហ.អ.ក 18 ការធ្វើបទបង្ហាញ និងការលាតត្រដាងលើរបាយការណ៍ហិរញ្ញវត្ថុ

ស.រ.ហ.អ.ក 18 នឹងជំនួសឱ្យ ស.គ.អ.ក 1 ការបង្ហាញ នៃរបាយការណ៍ហិរញ្ញវត្ថុ និងអនុវត្តសម្រាប់ការិយបរិច្ឆេទចាប់ផ្តើមនៅ ឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2027។ ស្តង់ដាថ្មីណែនាំនូវតម្រូវការថ្មីសំខាន់ៗដូចខាងក្រោម។

- អង្គភាពត្រូវបានតម្រូវឱ្យចាត់ថ្នាក់ចំណូល និងចំណាយទាំងអស់ជាប្រាំប្រភេទក្នុងរបាយការណ៍ចំណេញឬខាត ពោលគឺប្រតិបត្តិការ ការវិនិយោគ ហិរញ្ញប្បទាន ប្រតិបត្តិការដែលឈប់ដំណើរការ និងពន្ធលើប្រាក់ចំណេញ។ អង្គភាពក៏ត្រូវបានតម្រូវឱ្យបង្ហាញនូវផលបូករងនៃប្រាក់ចំណេញប្រតិបត្តិការដែលបានកំណត់ថ្មីផងដែរ។ ប្រាក់ចំណេញសុទ្ធរបស់អង្គភាពនឹងមិនផ្លាស់ប្តូរទេ។
- វិធីសាស្ត្រវាយតម្លៃលទ្ធផលដែលបានកំណត់ដោយអ្នកគ្រប់គ្រង (MPMs) ត្រូវបានលាតត្រដាងក្នុងកំណត់សម្គាល់តែមួយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- គោលការណ៍ពង្រឹងការណែនាំ ត្រូវបានផ្តល់ឱ្យសម្រាប់កំណត់ព័ត៌មានជាក្រុម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

លើសពីនេះ អង្គភាពទាំងអស់ត្រូវបានតម្រូវឱ្យប្រើប្រាស់ផលបូករងនៃប្រាក់ចំណេញប្រតិបត្តិការ ជាចំណុចចាប់ផ្តើមសម្រាប់របាយការណ៍លំហូរសាច់ប្រាក់ នៅពេលបង្ហាញលំហូរសាច់ប្រាក់ប្រតិបត្តិការក្រោមវិធីសាស្ត្រប្រយោល។ ធនាគារ កំពុងស្ថិតក្នុងដំណើរការវាយតម្លៃផលប៉ះពាល់នៃស្តង់ដាថ្មី ជាពិសេសទាក់ទងទៅនឹងរចនាសម្ព័ន្ធនៃរបាយការណ៍ចំណេញ ឬខាត របាយការណ៍លំហូរសាច់ប្រាក់ និងការលាតត្រដាងបន្ថែម ដែលតម្រូវតាមវិធីសាស្ត្រវាយតម្លៃលទ្ធផលដែលបានកំណត់ដោយអ្នកគ្រប់គ្រង។ ធនាគារ ក៏កំពុងវាយតម្លៃផលប៉ះពាល់លើរបៀបដែលព័ត៌មានត្រូវបានដាក់ជាក្រុមនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងធាតុដែលបច្ចុប្បន្នកំណត់ថា "ផ្សេងៗ"។

34. ស្តង់ដាថ្មី ឬវិសោធនកម្ម និងការបកស្រាយមិនទាន់បានអនុវត្ត (ត)

គ. ស្តង់ដាគណនេយ្យផ្សេងៗ

ការធ្វើវិសោធនកម្មស្តង់ដា និងការបកស្រាយទាំងនេះមិនបានរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សាខាធនាគារនោះឡើយ៖

កាលបរិច្ឆេទចូលជាធរមាន	ស្តង់ដាគណនេយ្យថ្មី ឬវិសោធនកម្ម
ថ្ងៃទី1 ខែមករា ឆ្នាំ2026	កិច្ចសន្យាដែលយោងតាមអគ្គិសនីអាស្រ័យលើធម្មជាតិ - (វិសោធនកម្មលើ ស.រ.ហ.អ.ក 9 និង ស.រ.ហ.អ.ក 7)
ថ្ងៃទី1 ខែមករា ឆ្នាំ2026	ការកែលម្អប្រចាំឆ្នាំចំពោះស្តង់ដាគណនេយ្យ ស.រ.ទ.ហ.អ.ក - កំណែទម្រង់លើកទី11
ថ្ងៃទី1 ខែមករា ឆ្នាំ2027	ស.រ.ហ.អ.ក 19 ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលពុំមានទំនួលខុសត្រូវជាសាធារណៈ៖ ការបង្ហាញ

35. ការអនុញ្ញាតកម្មវត្ថុក្រោមការគ្រប់គ្រងរួម និងទុនបម្រុងរួមបញ្ចូលគ្នា

នៅថ្ងៃទី22 ខែកក្កដា ឆ្នាំ2019 ធនាគារបានចុះកិច្ចព្រមព្រៀងទុនបម្រុងរួមបញ្ចូលគ្នាជាមួយភាគទុនិកតែមួយគត់នៃ Woori Finance Cambodia Plc. (“WFC”) គឺ ធនាគារ អ៊ូរី កូរ៉េ។

ការរួមបញ្ចូលគ្នានេះ ត្រូវបានធ្វើឡើងដើម្បីបង្កើនទីផ្សាររបស់ធនាគារ នៅក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុ។ យោងតាមកិច្ចព្រមព្រៀងទុនបម្រុងរួមបញ្ចូលគ្នា WFC នឹងត្រូវរំលាយបន្ទាប់ពីការរួមបញ្ចូលគ្នា។

នៅថ្ងៃទី3 ខែមករា ឆ្នាំ2020 ធនាគារជាតិនៃកម្ពុជា បានអនុម័តលើការរួមបញ្ចូលគ្នារវាងធនាគារ និង WFC ហើយត្រូវបានអនុម័តជាបន្តបន្ទាប់ដោយ MOC នៅថ្ងៃទី10 ខែកុម្ភៈ ឆ្នាំ2020 ដែលជាកាលបរិច្ឆេទកំណត់នៃការរួមបញ្ចូលគ្នា។

កិច្ចព្រមព្រៀងរួមបញ្ចូលគ្នា រួមមានការបោះផ្សាយភាគហ៊ុនរបស់ធនាគារដែលបានបង់គ្រប់ចំនួន និងជាភាគហ៊ុនមិនអាចវាយតម្លៃបានដែលមាន ចំនួន 15,895,100 ដុល្លារអាមេរិក ឬ 635,804 ភាគហ៊ុន ដែលមានតម្លៃហ៊ុនស្មើ 25 ដុល្លារអាមេរិកក្នុងមួយហ៊ុន ដែលជាការកំណត់ដោយម្ចាស់ភាគហ៊ុនរបស់ WFC។

35. ការទិញអាជីវកម្មក្រោមការគ្រប់គ្រងរួម និងទុនបម្រុងរួមបញ្ចូលគ្នា (ត)

ព័ត៌មានលម្អិតនៃ ទ្រព្យសកម្មដែលបានទិញ និងបំណុលដែលទទួលស្គាល់ ជាប្រាក់ដុល្លារអាមេរិកនៅ កាលបរិច្ឆេទនៃការរួមបញ្ចូលគ្នាមានដូចខាងក្រោម៖

ទ្រព្យសកម្ម	ដុល្លារអាមេរិក
សាច់ប្រាក់ក្នុងដៃ	398,033
សមតុល្យនៅធនាគារជាតិកម្ពុជា	657,604
សមតុល្យនៅធនាគារនានា	10,046,794
ឥណទានផ្តល់ដល់អតិថិជន	105,055,190
ទ្រព្យ និងបរិក្ខារ	1,225,700
ទ្រព្យសកម្មអរូបី	90,622
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	1,423,721
ពន្ធពន្យារជាទ្រព្យសកម្ម	274,552
ទ្រព្យសកម្មផ្សេងៗ	156,236
	119,328,452
បំណុល	
បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	(1,116,849)
ប្រាក់កម្ចី	(93,656,564)
បំណុលភតិសន្យា	(1,383,572)
បំណុលផ្សេងៗ	(337,963)
	(96,494,948)
ទ្រព្យសកម្មសុទ្ធ	**22,833,504**

រាល់ទ្រព្យសកម្ម និងបំណុលទាំងអស់របស់ WFC ត្រូវបានអនុវត្តតាមតម្លៃកត់ត្រាសុទ្ធដែលយោងតាមចុះបញ្ជីរបស់ធនាគារទទួលបានការអនុម័តពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី10 ខែកុម្ភ: ឆ្នាំ2020 ដែលជាកាលបរិច្ឆេទកំណត់នៃការរួមបញ្ចូលគ្នា។

35. ការធិញ្ញអាជីវកម្មក្រោមការគ្រប់គ្រងរួម និងទុនបម្រុងរួមបញ្ចូលគ្នា (ត)

ភាពលម្អៀងរវាងតម្លៃនៃភាគហ៊ុនដែលបានបោះផ្សាយដោយធនាគារ ជាថ្នូរនឹងតម្លៃនៃទ្រព្យសកម្មសុទ្ធដែលបានទិញទាក់ទងនឹងការរួមបញ្ចូលគ្នានៃ WFC មានចំនួន 5,956,500 ដុល្លារអាមេរិក ត្រូវបានទទួលស្គាល់ថាជាទុនបម្រុងរួមបញ្ចូលគ្នាក្រោមវិធីសាស្ត្រការប្រាក់បូកបញ្ចូលគ្នា (pooling-of-interest method)។

	ដុល្លារអាមេរិក
ទ្រព្យសកម្មសុទ្ធនៅថ្ងៃដែលរួមបញ្ចូលគ្នា	22,833,504
ការបោះផ្សាយនៃដើមទុនជារួមសម្រាប់រួមបញ្ចូលគ្នានាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020	(15,895,100)
ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020	(981,904)
ទុនបម្រុងពីការរួមបញ្ចូលគ្នានាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020	**5,956,500**